សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# របបគតិយុត្តនៃកិច្ចសន្យាម៉ៅការ

ស្រាវជ្រាវពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវឡើងដោយ
និស្សិតឈ្មោះ កញ្ញា **ឡាច ហង់នីសារ**
កញ្ញា **វ៉ាន់ វិន្ធុញា**

សាស្ត្រាចារ្យណែនាំ
លោក **ជិន ចណ្ណារ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២២

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ វ៉ាន វិនុប្លា និង ឡាច ហង់នីសារ ជានិស្សិតថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ជំនាន់ទី២២ នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចក្នុងឆ្នាំសិក្សា ២០១៨-២០២២ ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ៖**

**លោកឪពុក អ្នកម្តាយ** ជាទីគោរព និងស្រលាញ់នៃកូនដែលបានផ្តល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅ ជួយទំនុកបំរុងដល់រូបកូនៗទាំងស្មារតី និង សម្ភារៈគ្រប់បែបយ៉ាង ជាពិសេសរួមទាំងការផ្តល់នូវដំបូន្មានដ៏ល្អៗរបស់លោកដល់រូបកូនទាំងពីរចាប់តាំងពីពេលកូននៅជាកុមារភាព រហូតដល់កូនធំពេញវ័យ និងបានទទួលការបណ្តុះបណ្តាលតាំងពីថ្នាក់បឋមសិក្សារហូតដល់ថ្នាក់ឧត្តមសិក្សា។ លោកទាំងពីរបានព្យាយាមប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តរបស់ខ្លួនក្នុងការជួយទំនុកបំរុងតម្រង់ទិស អោយកូនៗមានអនាគតភ្លឺស្វាងរីកចម្រើនទៅមុខ និងអភិវឌ្ឍខ្លួនអោយក្លាយជាសិស្សល្អ កូនល្អ និងពលរដ្ឋល្អនៅក្នុងសង្គមជាតិនាថ្ងៃអនាគត ។

**សូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ៖**

**ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ លុយ ចណ្ណា** សាកលវិទ្យាធិការ ព្រមទាំងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស លោកលោកស្រីសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលមានសមត្ថភាពខ្ពង់ខ្ពស់ និងបានជួយតម្រង់ទិសពួកយើងចាប់តាំងពី ឆ្នាំសិក្សាថ្នាក់មូលដ្ឋានរហូតបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះប្រកបដោយក្រមវិជ្ជាជីវៈ ។

**លោកសាស្ត្រាចារ្យ ជិន វណ្ណារ៉ា** ដែលលោកបានខិតខំដឹកនាំបង្ហាត់បង្ហាញនូវគំនិត និងវិធីសាស្ត្រល្អៗទាក់ទងនឹងប្រធានបទរួមទាំង បានចំណាយពេលវេលាដ៏មានតម្លៃ របស់លោកការជួយផ្តល់ជាគំនិតយោបល់ និង ដំបូន្មានល្អៗ ក៏ដូចជាឯកសារសម្រាប់ជាប្រយោជន៍ដល់យើងខ្ញុំទាំងពីរ នាក់ក្នុងការធ្វើអោយសារណាមួយនេះកាន់តែមានភាពល្អប្រសើរឡើងតាំងពីដើមរហូតដល់បញ្ចប់កិច្ចការស្រាវជ្រាវមួយនេះ ។ ស្នាដៃដែលកើតចេញពីការស្រាវជ្រាវមួយនេះពិតជាមិនអាចមានអត្ថិភាពឡើយប្រសិនបើគ្មានការជ្រោមជ្រែងពីលោក ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់ សូមធ្វើការថ្លែងអំណរអរគុណនឹងដឹងគុណម្តងទៀតដល់អ្នកមានគុណទាំងពួងដូចដែលបានរៀបរាប់ខាងលើ សូមឱ្យបានជួបតែសេចក្តីសុខប្រកបតែនឹងពុទ្ធពរទាំង៤ប្រការគឺ អាយុ វណ្ណៈសុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

## អារម្ភកថា

ជាកិច្ចចាប់ផ្តើម នាងខ្ញុំឈ្មោះ វ៉ាន វិនុព្ភា និងនាងខ្ញុំឈ្មោះឡាច ហង់នីសារជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលមានឱកាសបានសរសេរសារណាបញ្ចប់ការសិក្សមួយនេះ។ យើងខ្ញុំទាំងពីរសូមធ្វើការស្វាគមន៍យ៉ាងកក់ក្តៅដល់ប្រិយមិត្តអ្នកអានគ្រប់ទិសទី ជាពិសេសនិស្សិតជាទីរាប់អានសាស្ត្រាចារ្យជាទីគោរព។

សារណានេះមានចំណងជើងថា "**បទដ្ឋានគតិយុត្តនៃកិច្ចសន្យាម៉ៅការ**" ដែលមានគោលបំណងឲ្យអ្នកអានបានយល់ដឹងស៊ីជម្រៅអំពី បទដ្ឋានទូទៅនៃកិច្ចសន្យាម៉ៅការ ព្រមទាំងលក្ខខណ្ឌ និងរបៀបផ្សេងៗ នៅក្នុងការធ្វើការព្រមព្រៀងចុះកិច្ចសន្យាម៉ៅការផ្សេងៗ ដែលកើតមានឡើងនាពេលបច្ចុប្បន្ននេះ។ ប្រធានបទមួយនេះក៏កើតចេញពីចម្ងល់និងការចង់ដឹងឱ្យកាន់តែស៊ីជម្រៅរបស់យើងទាំងពីររូប ទៅលើកិច្ចសន្យានានា ដែលពួកយើងសង្កត់ធ្ងន់ទៅលើកិច្ចសន្យាម៉ៅការសាងសង់។ កិច្ចការស្រាវជ្រាវមួយនេះ ផ្តោតសំខាន់ទៅលើការអនុវត្តនីតិវិធី ការការពារទៅលើអនីតិជនដែលធ្វើយ៉ាងណាធានាដល់ឧត្តមប្រយោជន៍របស់អនីតិជន។ នេះជាការកើតចេញពីសមិទ្ធផលនៃការខិតខំស្រាវជ្រាវ និងរៀបចំចងក្រងឡើង ដោយផ្អែកលើក្រមរដ្ឋប្បវេណី និងបទដ្ឋានគតិយុត្តនានា ដើម្បីឲ្យប្រធានបទនេះប្រកបដោយសុក្រឹតភាព ហើយម្យ៉ាងវិញទៀត វាក៏ជួយឲ្យនិស្សិតបានសិក្សាផ្នែកមួយជ្រុងនៃបច្ចុប្បន្នភាពនៃច្បាប់នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសាស្ត្រាចារ្យ **ខិន ចន្ទណ្ណារ៉ា** ជាសាស្ត្រាចារ្យមហាវិទ្យាល័យនីតិសាស្ត្រ នៃសកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានជួយជំរុញទឹកចិត្ត និងបង្ហាត់បង្ហាញ ឆ្លៀតពេលវេលាក្នុងការណែនាំដល់រូបខ្ញុំទាំងពីររហូតអាចបញ្ចប់ការសរសេរសារណានេះ។ នៅក្នុងអត្ថបទស្រាវជ្រាវនេះ យើងខ្ញុំទាំងពីរនាក់បានចំណាយពេលវេលាយ៉ាងច្រើនក្នុងការស្វែងរកឯកសារពាក់ព័ន្ធផ្សេងៗដែលមានស្រាប់នៅក្នុងបណ្ណាល័យ និងតាមគេហទំព័រផ្សេងៗ ដើម្បីចងក្រងជាសៀវភៅសារណានេះឡើង។ យើងខ្ញុំស្វាគមន៍ទទួលមតិរិះគន់ជានិច្ចពីគ្រប់មជ្ឈដ្ឋាន ដើម្បីធ្វើជាទុនក្នុងការស្ថាបនាឲ្យសារណានេះកាន់តែមានអត្ថន័យត្រឹមត្រូវ និងកាន់តែប្រសើរថែមមួយកម្រិតទៀត។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរសូមជូនពរដល់លោកសាស្ត្រាចារ្យ ក៏ដូចជាមិត្តនិស្សិត និងអ្នកអានជួបតែសុខដុមរមនា និងជោគជ័យគ្រប់ភារកិច្ច។ យើងខ្ញុំសង្ឃឹមថាយុវជន យុវនារីខ្មែរនឹងខិតខំសិក្សារៀនសូត្រ ធ្វើការសិក្សាស្រាវជ្រាវ ដើម្បីក្លាយជាធនធានមនុស្សប្រកបដោយសក្តានុពលក្នុងការចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ..................................................... ១

១. លំនាំបញ្ហានៃការស្រាវជ្រាវ ..................................................... ២

២. ចំណោទបញ្ហាស្រាវជ្រាវ ..................................................... ២

៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ ..................................................... ២

៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ ..................................................... ៣

៥. សារៈសំខាន់នៃការស្រាវជ្រាវ ..................................................... ៣

៦. វិធីសាស្រ្តនៃការសិក្សាស្រាវជ្រាវ ..................................................... ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..................................................... ៣

**ជំពូកទី១**

**ការបង្កើតកិច្ចសន្យាម៉ៅការ**

**ផ្នែកទី១៖ ការព្រមព្រៀងក្នុងការបង្កើតកិច្ចសន្យា** ..................................................... ៤

១. ការព្រមព្រៀង ..................................................... ៤

១.១. ការព្រមព្រៀងដោយឆន្ទៈ ..................................................... ៤

១.១.១. សំណើ ..................................................... ៥

១.១.២. ស្វីការ ..................................................... ៥

១.២. វិការៈនៃការព្រមព្រៀង ..................................................... ៥

១.២.១. ការភាន់ច្រឡំ ..................................................... ៦

១.២.២. ការឆបោក ..................................................... ៦

១.២.៣. ព័ត៌មានមិនពិត ..................................................... ៧

១.២.៤. ការរំលោភបំពានលើស្ថានភាព ..................................................... ៧

១.២.៥. ការគម្រាមកំហែង ..................................................... ៨

១.២.៦. អំពីកេងយកចំណេញហួសហេតុ ..................................................... ៨

១.២.៧. ការបង្ហាញឆន្ទៈមិនពិត ..................................................... ៨

**ផ្នែកទី២ សមត្ថភាពចុះកុងត្រា** ..................................................... ៨

១. អនីតិជន ........................................................................................................ ៩
១.១. សិទ្ធិលុបចោលសកម្មភាពរបស់អនីតិជន ................................................................ ៩
១.២. ការអនុញ្ញាតឱ្យចាត់ចែងទ្រព្យសម្បត្តិសម្រាប់អនីតិជន ............................................ ១០
១.៣. អនីតិជនដែលត្រូវបានអនុញ្ញាតឱ្យប្រកបអាជីវកម្ម ................................................ ១០
២. ជននៅក្រោមអាណាព្យាបាលទូទៅ ........................................................................ ១០
៣. ជននៅក្រោមហិតូបត្ថម្ភ ...................................................................................... ១១
**ផ្នែកទី៣ កម្មវត្ថុនៃការបង្កើតកិច្ចសន្យា** ................................................................ ១៣
១. កម្មវត្ថុនៃកិច្ចសន្យាម៉ៅការសាងសង់........................................................................ ១៣
១.១. រយៈពេលនៃការអនុវត្តការងារសាងសង់ ................................................................ ១៣
១.២. ករណីប្រធានសក្តិ ............................................................................................ ១៤
១.៣. ការកែប្រែ ការរុះរើ ឬការសាងសង់ឡើងវិញ ........................................................ ១៤
១.៤. ទឹកប្រាក់នៃការសាងសង់ លក្ខខណ្ឌ និងរយៈពេលនៃការបង់ប្រាក់ .............................. ១៤
២. កិច្ចសន្យាម៉ៅការចាក់បំពេញដី ............................................................................ ១៥
៣. កិច្ចសន្យាម៉ៅការចាក់ថ្ម...................................................................................... ១៥
៣.១ កម្មវត្ថុនៃកិច្ចសន្យា ........................................................................................ ១៦
៣.២. ការកំណត់ពេលវេលា ...................................................................................... ១៦
៣.៣. ដំណើរការការងារ ប្រភេទថ្ម និងបរិមាណ .............................................................. ១៦
៣.៤. អំពីតម្លៃ និងការទូទាត់ប្រាក់ .............................................................................. ១៦

## ជំពូកទី២

## ភាតព្វកិច្ចរបស់ភាគី

**ផ្នែកទី១ ភាតព្វកិច្ចរបស់អ្នកម៉ៅការ** .................................................................. ១៨
១. ករណីយកិច្ចសម្រេចដោយគ្មានវិការៈ .................................................................... ១៨
១.១. ការទទួលខុសត្រូវរបស់អ្នកម៉ៅការ ក្នុងករណីការងារមានវិការៈ .................................. ១៩
១.១.១. ការទាមទារឲ្យអនុវត្តពេញលេញរបស់ម្ចាស់ការ .................................................. ២០
១.១.២. ការជួសជុលវិការៈដោយម្ចាស់ការ........................................................................ ២០
១.១.៣. សិទ្ធិរំលាយរបស់ម្ចាស់ការ .............................................................................. ២១
១.១.៤. សិទ្ធិទាមទារឲ្យបន្ថយតម្លៃរបស់ម្ចាស់ការ ............................................................ ២២

១.១.៥. សិទ្ធិទាមទារសំណងនៃការខូចខាតរបស់ម្ចាស់ការ ......... ២២
១.១.៦. ក្នុងករណីដែលវិការៈកើតមានឡើងដោយសម្ភារៈ ឬការបញ្ជារបស់ម្ចាស់ការ ......... ២៣
២. ករណីយកិច្ចវត្ថុដែលជាកម្មវត្ថុនៃការងារ ......... ២៣
**ផ្នែកទី ២ ភាតព្វកិច្ចរបស់ម្ចាស់ការ** ......... ២៤
១. ករណីយកិច្ចបង់កម្រៃ ......... ២៤
២. ករណីយកិច្ចទទួលវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា ......... ២៥

## ជំពូកទី៣
## ការបញ្ចប់កិច្ចសន្យាម៉ៅការ

**ផ្នែកទី១ សិទ្ធិរំលាយកិច្ចសន្យា** ......... ២៦
១. សិទ្ធិរំលាយកិច្ចសន្យា ដែលបាបនកំណត់ក្នុងច្បាប់ ......... ២៦
២. សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់ក្នុងកិច្ចសន្យា ......... ២៦
៣. សិទ្ធិរំលាយកិច្ចសន្យា ដោយផ្អែកទៅលើបញ្ញត្តិពិសេស ......... ២៧
**ផ្នែកទី២ លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា** ......... ២៧
១. សិទ្ធិរំលាយរបស់ម្ចាស់ការ នៅក្នុងពេលដែលការងារមិនទាន់បានសម្រេច ......... ២៨
២. ការរំលាយកិច្ចសន្យា មូលហេតុអនុវត្តការងារយឺតយ៉ាវ ......... ២៨
៣. ការរំលាយកិច្ចសន្យា ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច ......... ២៩
៤. ការរំលាយកិច្ចសន្យា ដោយការក្ស័យធនរបស់ម្ចាស់ការ ......... ២៩
៥. ការព្រមព្រៀងរបស់ភាគី ......... ៣០
៦. វិការៈនៅក្នុងកិច្ចសន្យា ......... ៣០
**ផ្នែកទី៣៖ ការអនុវត្តភាតព្វកិច្ចត្រឹមត្រូវ និងដល់កាលកំណត់នៃកិច្ចសន្យា** ......... ៣១
១. កិច្ចសន្យាអស់សុពលភាព ......... ៣១
២. កាតព្វកិច្ចត្រូវបានបំពេញចប់សព្វគ្រប់ ......... ៣១
**សេចក្តីសន្និដ្ឋាន** ......... ៣៣
**អនុសាសន៍** ......... ៣៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាគឺជាប្រទេសមួយដែលធ្លាប់បានធ្លាក់ខ្លួនចូលទៅក្នុងភ្នក់ភ្លើងសង្គ្រាមហើយ វិស័យគតិយុត្តនៅកម្ពុជាត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង ក្នុងភ្លើងនៃសង្គ្រាមស៊ីវិល មានការបែកបាក់ផ្ទៃក្នុង និងជម្ងឺរាំរ៉ៃនៃការជ្រៀតជ្រែកពីសំណាក់មហាអំណាចមកលើអធិបតេយ្យភាពរបស់កម្ពុជា។ រហូតដល់ថ្ងៃទី២៨ តុលា ឆ្នាំ១៩៨៨ ជាអំឡុងពេលគាប់ប្រសើរ កម្ពុជាបានបង្កើតឲ្យមាន ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យាបន្ថែមទៀត ក្នុងទិសដៅដើម្បីការពារផលប្រយោជន៍ក្នុងទំនាក់ទំនងសង្គម ក៏ដូចជាការចូលរួមចំណែកក្នុងការពង្រឹងដល់ការបកស្រាយ និងបំពេញបន្ថែមលើវិធាន និងក្បួនច្បាប់ដែលមានស្រាប់។ ក្រឹត្យច្បាប់លេខ ៣៨ ក៏បានបញ្ញត្តិកាន់តែមានភាពច្បាស់លាស់ ដោយចង្អុលបង្ហាញយ៉ាងជាក់លាក់ជាងវិធានមុនៗ ចំពោះនិយមន័យនៃកិច្ចសន្យា និងនីតិវិធីនៃការបង្កើតកិច្ចសន្យាដោយមាន សុពលភាព ជាក់ស្តែងក្នុងមាត្រា ១ ចែងថា កិច្ចសន្យា គឺជាឆន្ទៈព្រមព្រៀងរវាងបុគ្គលពីរនាក់ ឬច្រើននាក់ ដើម្បីបង្កើត កែប្រែ ឬរំលត់កាតព្វកិច្ចមួយ ឬ ច្រើនដែលទាក់ទិននឹងខ្លួន។ ឆន្ទៈព្រមព្រៀងនៅទីនេះមានន័យថា ជាការព្រមព្រៀងពិតប្រាកដ និងដោយសេរីគ្មានការបង្ខិតបង្ខំ។ ម្យ៉ាងទៀត ទោះបីជាមានក្រឹត្យច្បាប់លេខ ៣៨នេះ ក៏ដោយ ក៏ទំនាក់ទំនងការងារ ដែលស្ថិតក្រោមវិធានដើមខាងលើ នៅមានភាពស្រពិចស្រពិល និងអរូបីនៅឡើយ ដែលនេះកំណត់ថាជាចន្លោះប្រហោងនៃច្បាប់ ដោយសារនៅពេលតាក់តែងច្បាប់មិនទាន់មានអ្នកណាគិតដល់ចំណុចនៃបញ្ហា រហូតដល់កើតមានជម្លោះនៅពេលច្បាប់នេះចូលជាធរមាន ទាំងការបកស្រាយមិនស្របគ្នា និងភាពមិនស៊ីសង្វាក់គ្នា។ ជាសមិទ្ធិផល ដែលកើតចេញពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល និងអ្នកផ្តួចផ្តើម យើងសង្កេតឃើញថាច្បាប់ថ្មីៗត្រូវបានបង្កើតឡើងជាហូរហែរ ដើម្បីគ្រប់គ្រងទំនាក់ទំនងការងាររវាង ថៅហ្វាយនាយ និងកូនចៅ និងធានានីត្យានុភាពនៃការងារសមស្របតាមគោលនយោបាយរបស់រដ្ឋាភិបាល។ ក្រោយពីការបោះឆ្នោតឆ្នាំ ១៩៩៣ ដើម្បីធានានិរន្តរភាពនៃកិច្ចអភិវឌ្ឍន៍ឲ្យរីកចម្រើនលូតលាស់ឈានទ្បើង និងមានភាពសម្បូររុងរឿងជានិរន្តន៍ ប្រទេសកម្ពុជាបានអនុវត្តយករបបនយោបាយប្រជាធិបតេយ្យ សេរីពហុបក្ស ក្នុងនាមជាប្រទេសនីតិរដ្ឋ ដែលថានាសិទ្ធិមនុស្ស ធានាការគោរពច្បាប់ ធានាសេចក្តីថ្លៃថ្នូរបុគ្គល និងភាពស្មើគ្នារវាងបុរស និងស្ត្រីនៅចំពោះមុខច្បាប់។ យ៉ាងណាមិញ ទោះបីជាសិទ្ធិ និងសេរីភាព(សិទ្ធិមនុស្ស) ត្រូវបានធានាដោយច្បាប់ក៏ដោយ ក៏ការអនុវត្តសិទ្ធិ និងសេរីភាពទាំងនោះ ស្ថិតនៅក្នុងការកម្រិត និងទំហំដែលច្បាប់កំណត់ដដែរ។ តួយ៉ាងក្នុងការបង្កើតកិច្ចសន្យាក៏ដូចគ្នា ទោះបីជាមានគោលការណ៍ស្វ័យភាពនៃបុគ្គលឯកជនកំណត់ដោយក្រមរដ្ឋប្បវេណី ថាការគោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គលឯកជន និងអនុញ្ញាតអោយបុគ្គលម្នាក់ៗ មានសិទ្ធិ

សេរីភាពក្នុងការបង្កើតទំនាក់ទំនងគតិយុត្តតាមឆន្ទៈរបស់ខ្លួន ដោយសេរី និងឆន្ទៈដោយស្ម័គ្រចិត្តតាមរយៈកិច្ចសន្យានោះ មិនត្រូវផ្ទុយនឹងបញ្ញត្តិដែលអនុវត្តដោយបង្ខំ ឬផ្ទុយនឹងគោលការណ៍រក្សាការពារឯករាជ្យ និងអធិបតេយ្យភាព ឬ បូរណភាពទឹកដី ឬប៉ះពាល់ដល់ឯកភាពនយោបាយ ការគ្រប់គ្រងរដ្ឋបាលប្រទេសជាតិ ឬផ្ទុយនឹងសណ្តាប់ធ្នាប់សារធាណៈ និងទំនៀមទម្លាប់ល្អរបស់សង្គមឡើយ បើមិនដូច្នេះនឹងត្រូវបានមោឃៈភាពដោយច្បាប់ ឬដោយភាគីនៃកិច្ចសន្យា។ ប៉ុន្តែកាលបើកិច្ចសន្យា ធ្វើឡើងផ្ទុយនឹងវិធានក្រមរដ្ឋប្បវេណី ឬផ្ទុយនឹងខ្លឹមសារច្បាប់ដែលទាមទារឲ្យមានទំនាក់ទំនងនៃកិច្ចសន្យាម៉ៅការនេះ នៅតែអាចទទួលស្គាល់ការអនុវត្តបានដដែរ ហោយផេតុថាជាជម្រើសរបស់គូភាគី ហើយផាគីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការប្រតិបត្តិកិច្ចសន្យា។ ជារួម កិច្ចសន្យា គឺជាច្បាប់ឯកជនរបស់គូភាគី ដែលបង្កើតឡើងផ្អែកលើតម្រូវការ ឆន្ទៈ និងជម្រើសរបស់គូភាគីដើម្បីបំពេញសេចក្តីត្រូវការក្នុងទំនាក់ទំនងប្រចាំថ្ងៃរបស់ខ្លួន។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយនៅក្នុងសង្គមកម្ពុជាបច្ចុប្បន្ន សម្បូរទៅដោយទំនាស់ ឬវិវាទនៃទំនាក់ទំនងក្នុងពេលបំពេញការងារ ដែលតែងតែកើតមានឡើងមិនចេះចប់មិនចេះហើយ ដោយបង្កឲ្យមានលក្ខណៈស្មុគស្មាញជាច្រើនជុំវិញទិដ្ឋភាពស្នូលសំខាន់ៗដូចជា៖ អំពីបញ្ហាប្រភេទនៃកិច្ចសន្យាម៉ៅការ បញ្ហាលក្ខខណ្ឌ ប្រាក់ឈ្នួល អត្ថប្រយោជន៍បន្ថែម និងបញ្ហាសុវត្ថិភាពការងារបានកើតជាភាពចាំបាច់សំខាន់ដាច់ខាត ដែលទាមទារអោយមានយន្តការដោះស្រាយដ៏ល្អមួយ ដើម្បីឈានដល់ការកាត់បន្ថយ និងលុបបំបាត់បញ្ហាទាំងនោះ។ ដូច្នេះ ការតាក់តែង និងជ្រើសរើសចងក្រងយកអត្ថបទមួយនេះឡើង ជាក់ច្បាស់ណាស់នឹងអាច ចូលរួមចំណែកយ៉ាងធំធេង ដល់ការបង្ការ ការទប់ស្កាត់ និងការដោះស្រាយវិវាទ ប្រកបដោយយុត្តិធម៌ សុក្រឹត្យភាព តម្លាភាព និងប្រសិទ្ធភាពខ្ពស់ ហើយនេះជាលក្ខណៈពិសេសមួយដែលជំរុញអោយមាននិងលេចចេញជារូបរាងនៃសារណារស្រាវជ្រាវនេះឡើង។

## ៣. គោលបំណងនៃការសិក្សាស្រាវជ្រាវ

ចំពោះគោលបំណងនៃការស្រាវជ្រាវទៅលើប្រធានបទ កិច្ចសន្យាម៉ៅការនេះ គឺដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍន៍ទៅលើវិស័យការងារ ស្វែងរកនូវមូលហេតុដែលតែងតែបង្កឡើងលេចចេញជាបញ្ហា និងផ្តល់ជាដំណោះស្រាយ ផ្តល់ជាយោបល់ ឬអនុសាសន៍ សមស្របនិងជួយកែលំអឡើងវិញចំពោះបញ្ហាដែលបានកើតមានឡើង។

## ៤. ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ក្នុងវិសាលភាពគ្របដណ្តប់នៃកិច្ចការស្រាវជ្រាវនេះ ផ្តោតសំខាន់តែទៅលើទំហំនៃរបបគតិយុត្ត និង ទំនាក់ទំនងសិទ្ធិ និងកាតព្វកិច្ចរវាងភាគីម្ចាស់ការ និងភាគីអ្នកម៉ៅការដែលកើតចេញពីសុពលភាពគតិយុត្ត របស់កិច្ចសន្យាម៉ៅការតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

តាមរយៈការសិក្សាស្រាវជ្រាវនៅក្នុងប្រធានបទនេះ គឺបានផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដល់យើង ខ្ញុំ ដែលជាអ្នកសិក្សាស្រាវជ្រាវ ឱ្យបានយល់ដឹងកាន់តែច្បាស់ និងស៊ីជម្រៅ ។ ជាពិសេស សារណាមួយនេះ នឹង អាចជាទុនសម្រាប់ប្អូនៗ និស្សិតជំនាន់ក្រោយ យកទៅធ្វើការសិក្សាស្វែងយល់ ក៏ដូចជាអនុញ្ញាតឱ្យនិស្សិត អាចយល់ដឹងកាន់តែស៊ីជម្រៅអំពីបទដ្ឋានគិតយុត្តនៃកិច្ចសន្យាម៉ៅការផងដែរ។ កិច្ចការស្រាវជ្រាវនេះ ក៏ បានរួម ចំណែកក្នុងការផ្តល់នូវចំណេះដឹងខាងវិស័យច្បាប់ និងជាជំនួយដល់ការសិក្សាស្រាវជ្រាវផ្សេងៗបន្ត ទៀត ។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ក្នុងការសរសេរសារណានេះ យើងខ្ញុំបានសិក្សាស្រាវជ្រាវដោយផ្អែកលើឯកសារគតិយុត្តនានា និង ឯក សារដែលចម្បងនោះគឺ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ ។ យើងខ្ញុំបាន ធ្វើការសិក្សា ស្រាវជ្រាវដោយដោយធ្វើការប្រមូលនូវព័ត៌មានទាំងឡាយ ក៏ដូចជាឯកសារពាក់ព័ន្ធទៅនឹង ប្រធានបទនៃ សារ ណានេះ ដើម្បីឱ្យសារណាមួយនេះកាន់តែមានភាពត្រឹមត្រូវ ច្បាស់លាស់ និងមាន ប្រសិទ្ធភាពខ្ពស់។ សារណា នេះ ត្រូវបានរៀបរៀងឡើងដោយប្រើប្រាស់នូវ វិធីសាស្ត្របែបពិពណ៌នា និងវិភាគ។ ខ្លឹមសារក្នុងសារណា នេះ ក៏ដូចជាព័ត៌មានទាំងឡាយដែលទទួលបាន ហើយត្រូវបានជ្រើសរើស គឺសុទ្ធសឹងតែដកស្រង់ចេញពី ប្រភព ល្អៗ ដូចជាការបកស្រាយរបស់សាស្ត្រាចារ្យដែលមានបទពិសោធន៍ នៅក្នុងវិស័យនេះផ្ទាល់ផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីងាយស្រួលក្នុងការសិក្សាស្រាវជ្រាវ និង ក្នុងការធ្វើបទបង្ហាញអំពីអត្ថន័យនៃ “បទដ្ឋានគតិយុត្ត នៃ កិច្ចសន្យាម៉ៅការ” យើងខ្ញុំបានចែកខ្លឹមសារសារណាចេញជាបីជំពូកដែលក្នុងមួយជំពូកៗមាន ជាផ្នែកៗ។ ជាដំបូង ផ្តើមពីជំពូកទី១ ការបង្កើតកិច្ចសន្យា។ ឯជំពូកទី២ បកស្រាយពី កាតព្វកិច្ចរបស់ភាគី។ រីឯចុង ក្រោយ គឺជំពូក៣ ការបញ្ចប់កិច្ចសន្យាម៉ៅការ។ លើសពីនេះទៀត នៅក្នុងផ្នែកចុងបញ្ចប់នៃសារណា យើង ខ្ញុំបានរៀបចំ នូវសេចក្តីសន្និដ្ឋាន រួមជាមួយនឹងអនុសាសន៍ផងដែរ។

# ជំពូកទី១
# ការបង្កើតកិច្ចសន្យាម៉ៅការ

## ជំពូកទី១ ការបង្កើតកិច្ចសន្យាម៉ៅការ

ការបង្កើតកិច្ចសន្យាគឺជាការបង្កើតដើម្បីអោយមានអានុភាព ឬលក្ខខណ្ឌសុពលភាព។ កិច្ចសន្យាម៉ៅការសំដៅលើកិច្ចសន្យាមួយ ដែលភាគីម្ខាងមានករណីយកិច្ចសម្រេចការងារដែលបានព្រមព្រៀង ហើយភាគីម្ខាង ទៀតមានករណីយកិច្ចផ្តល់កម្រៃចំពោះលទ្ធផលនៃការងារដែលបានធ្វើនោះ។ កិច្ចសន្យាម៉ៅការពុំមានទាមទារលក្ខខណ្ឌពិសេសណាមួយទេ គឺឱ្យតែគូភាគី មានការព្រមព្រៀង ជាការគ្រប់គ្រាន់នឹងបង្កើតកិច្ចសន្យាបានហើយ[1] ។

### ផ្នែកទី១ ការព្រមព្រៀងក្នុងការបង្កើតកិច្ចសន្យា

យោងតាមអត្ថន័យនៃកិច្ចសន្យា គឺជាកិរិយាដែលបុគ្គលពីរនាក់ ឬច្រើននាក់មានឆន្ទៈត្រូវគ្នាព្រមបង្កើត កែ ប្រែ ឬរលត់នូវកាតព្វកិច្ច ។

កិច្ចសន្យាបង្កើត និងមានអានុភាពទៅបានលុះត្រាតែសំណើ និងស្វីការត្រូវគ្នា ។ ប៉ុន្តែ ចំពោះករណីដែលកិច្ចសន្យាដែលភាគីម្ខាងទទួលករណីយកិច្ចធ្វើអនុប្បទាននូវកម្មសិទ្ធិលើអចលនវត្ថុ ឬករណីកិច្ចធ្វើលទ្ធកម្មនូវកម្មសិទ្ធិលើអចលនវត្ថុអាចនឹងមានអានុភាពទៅបានលុះត្រាតែបានធ្វើលិខិតយថាភូត។

យោងតាមមាត្រា៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីបានបញ្ញត្តិថា លិខិតយថាភូតក្នុងន័យនេះសំដៅទៅលើលិខិតយថាភូតដែលធ្វើឡើងដោយសារការី ឬលិខិតដែលមានមន្ត្រីមានសមត្ថកិច្ចធ្វើឡើងដើម្បីធ្វើនីតិវិធីនៃការចុះបញ្ជី ។

#### ១. ការព្រមព្រៀង

កិច្ចសន្យា ត្រូវមានអានុភាពគតិយុត្តិដោយការព្រមព្រៀងរបស់ភាគីនៃកិច្ចសន្យា។ ធាតុផ្សំនៃការព្រមព្រៀងនេះ គឺជាការបង្ហាញឆន្ទៈរបស់ភាគីទាំងពីរ។ ការបង្ហាញឆន្ទៈបានដល់ភាគីម្ខាងទៀតដែលទទួលការបង្ហាញឆន្ទៈនោះចាំបាច់មានសមត្ថភាពក្នុងការវិនិច្ឆ័យ។ ហេតុដូច្នេះ ប្រសិនបើភាគីម្ខាងទៀត គឺជាអនីតិជន ការបង្ហាញឆន្ទៈត្រូវធ្វើឡើងចំពោះអ្នកតំណាងដែលច្បាប់បានកំណត់ ។

#### ១.១ ការព្រមព្រៀងដោយឆន្ទៈ

យោងតាមមាត្រា៣៣៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តថា អ្នកធ្វើសំណើ គឺជាការសុំបង្កើតកិច្ចសន្យាដែលធ្វើឡើងដោយមានឆន្ទៈភ្ជាប់ខ្លួនជាមួយនឹងចំណងគតិយុត្ត ក្នុងករណីដែលមានស្វីការរបស់ភាគីម្ខាងទៀតចំពោះសំណើនេះ។ ការព្រមព្រៀងដោយកិច្ចសន្យា គឺការសំដែងឆន្ទៈនូវភាគីដែលដាក់សំណើ និងភាគីទទួល សំណើ។ ស្វីការ គឺជាការបង្ហាញឆន្ទៈដែលអ្នកទទួលសំណើ យល់ព្រមចំពោះសំណើនោះ។

[1] យោងតាមមាត្រា៣៣៦ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

**១.១.១ សំណើ**

សំណើ គឺជាការបង្ហាញឆន្ទៈជាឯកតោភាគី ដើម្បីសុំបង្កើតកិច្ចសន្យាដែលភ្ជាប់មកជាមួយនូវចំណង គតិយុត្តក្នុងករណីដែលភាគីម្ខាងទៀតបានផ្តល់ស្វីការតបចំពោះសំណើនោះ។ សំណើអាចធ្វើឡើងដោយមាន កំណត់អំឡុងពេល ឬគ្មានកំណត់ អំឡុងពេលសម្រាប់ស្វីការបាន។ អនុភាពនៃសំណើត្រូវកើតឡើងនៅពេល ដែលសំណើនោះបានដល់ភាគីម្ខាងទៀត។ ប៉ុន្តែអានុភាពត្រូវបាត់ បង់ទៅវិញនៅពេលដែលដំណឹងអំពីការដក សំណើវិញបានដល់ភាគីម៉្យាងទៀត ក្នុងពេលជាមួយគ្នានិងពេលសំណើដល់ ឬដល់មុនពេលសំណើដល់។ សំណើដែលមានកំណត់អំឡុងពេលសម្រាប់ស្វីការ ត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិ បើអ្នកស្នើមិនទទួល ដំណឹងអំពីស្វីការក្នុងរយៈពេលកំណត់នោះ នៅពេលដែលផុតអំឡុងពេលសម្រាប់ស្វីការ ឬពេលអ្នកស្នើបាន ចំពោះសំណើមិនកំណត់អំឡុងពេលសម្រាប់ស្វីការ ត្រូវបាត់បង់អានុភាពនៅពេលដែលគូភាគីទទួលសំណើ មិនបានយល់ព្រមភ្លាមៗ ក្នុងស្ថានភាពដែលគូភាគីកំពុងនិយាយគ្នាហើយអាច ឆ្លើយតបភ្លាមៗបាន។ អ្នកស្នើ មិនអាចដកសំណើវិញ ក្នុងអំឡុងពេលសមរម្យបានទេ ប្រសិនបើគូភាគីធ្វើសំណើដែលមិននិយាយគ្នា។ លុះត្រាតែអ្នកស្នើជូនដំណឹងអំពីការដកវិញបានទៅដល់ ភាគីម្ខាងទៀតមុនពេលភាគីនោះជូនដំណឹងអំពីស្វីការ ទើបការដកសំណើនោះមានអានុភាព។ កិច្ចសន្យាត្រូវបានកើតឡើងនៅពេលដែលអ្នកទទួលសំណើរយល់ព្រម ចំពោះអ្នកស្នើ។

**១.១.២ ស្វីការ**

ស្វីការ គឺជាការបង្ហាញឆន្ទៈ យល់ព្រមរបស់អ្នកទទួលសំណើដល់អ្នកស្នើ។ នៅពេលដែល ស្វីការបាន ដល់អ្នកស្នើស្វីការនោះត្រូវមានអានុភាពហើយការជូនដំណឹងអំពីការដកស្វីការវិញមាន លក្ខណៈដូចសំណើ ដែរ។ បើស្វីការបានដាក់លក្ខខណ្ឌ ឬកែប្រែសារជាតុផ្សេងៗ នៃសំណើស្វីការនោះក្លាយជាសំណើថ្មី។ ប៉ុន្តែបើ លក្ខខណ្ឌ ឬការកែប្រែនោះមិនធ្វើឲ្យមានការកែប្រែសារជាតុរបស់សំណើទេ ស្វីការនោះមាន សុពលភាពក្នុង ករណីដែលអ្នកស្នើមិនបានតវ៉ាភ្លាមៗ។

## ១.២. វិការៈនៃការព្រមព្រៀង

វិការៈ គឺជាការប្រែប្រួលចាកពីភាពប្រក្រតី។ វិការៈ ក្នុងការបង្ហាញឆន្ទៈគឺជាការបង្ហាញឆន្ទៈដែលខុស ពីភាពប្រក្រតីបណ្តាលឲ្យកិច្ចសន្យាអាចត្រូវបានភាគីណាមួយ ឬគូភាគីមានសិទ្ធិលុបចោល ឬអាចលុបចោល បានបាន ដោយហេតុថាការបង្ហាញឆន្ទៈមានវិការៈ។

វិការៈក្នុងការបង្ហាញឆន្ទៈស្តែងឡើង ក្នុងករណីមានការភាន់ច្រលំ ការឆបោក ព័ត៌មានមិនពិត ការ រំលោភបំពានលើស្ថានភាព ការគម្រាមកំហែង អំពីកេងយកចំណេញហួសហេតុ និងការបង្ហាញឆន្ទៈ មិនពិត។

**១.២.១ ការភាន់ច្រឡំ**

ការភាន់ច្រឡំ មានន័យថានៅក្នុងករណីដែលអ្នកបង្ហាញឆន្ទៈបានធ្វើការបង្ហាញឆន្ទៈដែលមានលក្ខណៈខុសគ្នាទៅនឹងឆន្ទៈពិតរបស់ខ្លួន ហើយគេក៏មិនបានដឹងអំពីភាពខុសគ្នានេះ នៅពេលដែលគេធ្វើការបង្ហាញឆន្ទៈឡើយ។ ការភាន់ច្រឡំអំពីចំណុចសំខាន់ៗនៃកិច្ចសន្យា កិច្ចសន្យាដែលបានបង្កើតឡើងហើយអាចលុបចោលបាន ប្រសិនបើកិច្ចសន្យាមនោះ ត្រូវបានធ្វើឡើងដោយភាគីម្ខាង មានការភាន់ច្រឡំទៅលើចំណុចសំខាន់ៗនៃកិច្ចសន្យា និងខណៈដែលភាគីម្ខាងទៀតបានស្ថិតក្នុងស្ថានភាពដែលអាចដឹងបានអំពីការភាន់ច្រឡំ។ ការភាន់ច្រឡំទៅលើចំណុចនៃកិច្ចសន្យា ដែលភាគីយល់ឃើញថាសំខាន់ កិច្ចសន្យាដែលបានបង្កើតឡើងហើយអាចលុបចោលបាន ប្រសិនបើកិច្ចសន្យានោះ មានការភាន់ច្រឡំទៅលើចំណុចនៃកិច្ចសន្យាដែលភាគីយល់ឃើញថាសំខាន់ ឬចំណុចដែលខ្លួនយល់ឃើញថា សំខាន់ក្នុងការបង្កើតកិច្ចសន្យា ខណៈដែលភាគីម្ខាងទៀតបានស្ថិតនៅក្នុងស្ថានភាពដែលអាចដឹងបានអំពីការភាន់ច្រឡំ នេះនិងការភាន់ច្រឡំរបស់អ្នកបង្ហាញឆន្ទៈ។ ការភាន់ច្រឡំដោយភាគីសងខាង នៅក្នុងករណីនៃការភាន់ច្រឡំដោយភាគីទាំងសងខាងអ្នកបង្ហាញឆន្ទៈអាចលុបចោលកិច្ចសន្យាបានទោះបីជាភាគីម្ខាងទៀត មិនបានដឹងអំពីការភាន់ច្រឡំនេះក៏ដោយ ។ នៅក្នុងករណីនេះគូភាគីទាំងសងខាងមានការភាន់ច្រឡំដូច្នេះ ភាពចាំបាច់នៅក្នុងការការពារភាគីម្ខាងទៀត គឺមានកម្រិតទាប ដែលខុសពីករណីដែលមានតែភាគីម្ខាងមានការភាន់ច្រឡំ ។ ដូច្នេះវាមិនមានភាពចាំបាច់ក្នុងការពិចារណាទៅលើលទ្ធភាពក្នុងការដឹងរបស់ភាគីម្ខាងទៀតទេ ។

**១.២.២. ការឆបោក**

គោលបំណងឆបោក សំដៅលើភាគីម្ខាងទៀត ឬតតិយជនមានគោលបំណងធ្វើឲ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ និងបង្ហាញឆន្ទៈដោយមានវិការៈដោយសារតែការភាន់ច្រឡំនោះ។ គោលបំណងធ្វើឲ្យអ្នកបង្ហាញឆន្ទៈមានការភាន់ច្រឡំ មានន័យថាភាគីម្ខាងទៀត ឬ តតិយជនបានដឹងថាសកម្មភាពរបស់ខ្លួនគឺជាសកម្មភាពឆបោក និងអ្នកបង្ហាញឆន្ទៈនឹងមានការភាន់ច្រឡំដោយសារសកម្មភាពឆបោករបស់ខ្លួន។ ទន្ទឹមនឹងនេះ គោលបំណងធ្វើឲ្យអ្នកបង្ហាញឆន្ទៈបង្ហាញឆន្ទៈដោយវិការៈដោយសារការភាន់ច្រឡំ គឺចាំបាច់តម្រូវឲ្យមាន។

ការបង្ហាញឆន្ទៈដោយការឆបោក មានន័យថាបុគ្គលណាម្នាក់ ឬតតិយជនបានធ្វើឲ្យអ្នកបង្ហាញ ឆន្ទៈមានការភាន់ច្រឡំដោយសារមធ្យោបាយឆបោក ហើយអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈរបស់ខ្លួន ដោយខុសពីឆន្ទៈពិតប្រាកដរបស់ខ្លួន និងមិនបានដឹងពីភាពខុសគ្នានេះ នៅពេលដែលគាត់ធ្វើការបង្ហាញឆន្ទៈ។ លក្ខខណ្ឌដើម្បីកំណត់ថាវាជាការឆបោក មិនមានចែងក្នុងក្រមរដ្ឋប្បវេណីច្បាស់លាស់ប៉ុន្តែយើងអាចកំណត់បាននូវ

លក្ខខណ្ឌមួយចំនួនៈ ភាគីម្ខាងទៀត ឬតតិយជនមានគោលបំណងឆបោក សកម្មភាពឆបោកនោះ ត្រូវបានទទួលស្គាល់ថាខុសច្បាប់ អ្នកបង្ហាញឆន្ទៈ បានភាន់ច្រឡំដោយសារសកម្មភាពឆបោក និងអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈដោយមានវិការៈ ដោយសារតែការភាន់ច្រឡំនោះ។

### ១.២.៣ ព័ត៌មានមិនពិត

យោងតាមមាត្រា ៣៤៨ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តថា៖

១. នៅពេលធ្វើកិច្ចសន្យា បើហេតុដែលបានបង្ហាញដោយភាគីម្ខាងនោះខុសពីការពិត ហើយភាគីម្ខាងទៀតបានបង្ហាញឆន្ទៈដោយជឿជាក់ថា ហេតុទាំងនោះជាការពិតប៉ុន្តែ ប្រសិនបើភាគីនោះដឹងថា ហេតុនោះមិនមែន ជាការពិត ខ្លួននឹងមិនបង្ហាញឆន្ទៈទេ ភាគីនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។

២.បញ្ញត្តិនៃកថាខណ្ឌទី១ខាងលើនេះ មិនរារាំងភាគីដែលបានបង្ហាញឆន្ទៈក្នុងការទាមទារសំណងនៃការ ខូចខាតពីបុគ្គលដែលបានបង្ហាញការណ៍មិនពិតនោះទេ ក្នុងករណីដែលបុគ្គលនេះមានកំហុស។

៣.ការលុបចោលនូវកិច្ចសន្យាដោយព័ត៌មានមិនពិត ក្រៅពីភាគីម្ខាងទៀត អាចអះអាងចំពោះតតិយជនបាន។ ប៉ុន្តែ ប្រសិនបើតតិយជនជាជនសុចរិត ហើយគ្មានកំហុសអំពីព័ត៌មានមិនពិត មិនអាចអះអាងនូវអានុភាពនៃការលុបចោល ចំពោះតតិយជននោះបានឡើយ។

### ១.២.៤. ការរំលោភបំពានលើស្ថានភាព

ការរំលោភបំពានលើស្ថានភាពត្រូវបានបញ្ញត្តក្នុងក្រមរដ្ឋប្បវេណី ត្រង់មាត្រា៣៤៩ ថា៖

១.នៅពេលធ្វើកិច្ចសន្យា បើភាគីម្ខាងនៃកិច្ចសន្យាបានប្រើឋានៈខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ខាងផ្នែកសេដ្ឋកិច្ច ឬ ផ្នែកសង្គម ឬ បានប្រើស្ថានភាពផ្សេងទៀតដែលភាគីម្ខាងទៀតមិនអាចប្រឆាំងតបបានទេ ភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ ។

២.ការលុបចោលនូវកិច្ចសន្យាដោយយោងតាមបញ្ញត្តិនៃកថាខណ្ឌទី១ ខាងលើនេះ មិនអាចអះអាងចំពោះតតិជនដែលជាជនសុចរិត ហើយគ្មានកំហុសអំពីការរំលោភបំពានលើស្ថានភាពបានឡើយ។

មាត្រានេះចែងអំពីករណីដែលភាគីម្ខាងបង្ខំភាគីម្ខាងទៀតឲ្យចុះកិច្ចសន្យា តាមរយៈការប្រើឋានៈរបស់ខ្លួនដែលមានអាទិភាពជាងខាងផ្នែកសេដ្ឋកិច្ច ឬសង្គម ។ បើទោះនៅក្នុងករណីមិនមែនជាការ គម្រាមកំហែងក៏ដោយ ក៏អ្នកបង្ហាញឆន្ទៈត្រូវបានបង្ខំឲ្យបង្ហាញឆន្ទៈដែលខ្លួនមិនមានបំណងធ្វើដែរ ដូចនេះការបង្ហាញឆន្ទៈនោះមាន វិការៈ ហើយមាត្រានេះអនុញ្ញាតអោយលុបចោលកិច្ចសន្យាដែលមានការបង្ហាញឆន្ទៈបែបនេះជាធាតុផ្សំ ប៉ុន្តែ មានករណីជាច្រើនដែលកិច្ចសន្យាត្រូវបានបង្កើតឡើងតាមរយៈការប្រើឋានៈដែលមានអាទិភាពជាង

ភាគីម្ខាងទៀតខាងផ្នែកសេដ្ឋកិច្ច ហើយមិនមែនគ្រប់ករណីទាំងអស់ដែលគេអាចលុបចោលនូវកិច្ចសន្យាបាន នោះទេ។

**១.២.៥. ការគម្រាមកំហែង**

បុគ្គលដែលបានបង្ហាញឆន្ទៈ ដោយសារមានការគម្រាមកំហែងពីសំណាក់ភាគីម្ខាងទៀតឬពីសំណាក់តតិយជន អាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ[2] ។

**១.២.៦. អំពីកេងយកចំណេញហួសហេតុ**

យោងតាមមាត្រា ៣៥១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តិអំពីកេងចំណេញហួសហេតុថា ៖

ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លាតឱកាសដែលភាគីម្ខាងទៀតកំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះបទពិសោធន៍ ហើយបានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យា នោះភាគីម្ខាងទៀតនោះអាចលុបចោលនូវកិច្ចសន្យាបាន ដោយហេតុថាការបង្ហាញ ឆន្ទៈនោះមានវិការៈ។

**១.២.៧. ការបង្ហាញឆន្ទៈមិនពិត**

យោងតាមមាត្រា ៣៥៣ ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តិថា៖

១. កិច្ចសន្យា ដោយផ្អែកលើការបង្ហាញឆន្ទៈមិនពិតដែលត្រូវបានធ្វើឡើងដោយមានការឃុបឃិតជាមួយ នឹងភាគីម្ខាងទៀត ត្រូវចាត់ទុកជាមោឃៈ។

២. មោឃភាពនៃកិច្ចសន្យាដែលបានកំណត់នៅកថាខណ្ឌទី១ ខាងលើនេះ មិនអះអាងចំពោះតតិយជន ដែលមានទំនាក់ទំនងផលប្រយោជន៍ ដោយយកកិច្ចសន្យាដែលផ្អែកលើការបង្ហាញឆន្ទៈមិនពិតជាមូលដ្ឋាន បានឡើយ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលតតិយជននោះជាជនទុច្ចរិត ឬ មិនបានដឹងអំពីការបង្ហាញនូវឆន្ទៈមិនពិតដោយមានកំហុសធ្ងន់ធ្ងរ។

## ផ្នែកទី២ សមត្ថភាពភាគីចុះកុងត្រា

នៅក្នុងការបង្កើតកិច្ចសន្យានីមួយៗ បន្ទាប់ពីមានការព្រមព្រៀងរបស់គូភាគីហើយនោះកត្តាមួយដែលស្តីពីសមត្ថភាពនៃគូភាគីបង្កើតកិច្ចសន្យានោះ ក៏មានសារៈសំខាន់ផងដែរ។ ព្រោះថា ប្រសិនបើ គេពិនិត្យឃើញថាកិច្ចសន្យាណាមួយនោះ ត្រូវបានបង្កើតឡើងដោយជនដែលគ្មានសមត្ថភាពក្នុងការបង្កើតកិច្ចសន្យាតាមផ្លូវច្បាប់ទេ កិច្ចសន្យានោះអាចត្រូវបានគេចាត់ទុកថាមានវិការៈហើយមិនមានសុពលភាព និងគ្មានអានុភាពសម្រាប់យកមកអនុវត្តបានផងដែរ។ ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ក៏បានចែងពីការកម្រិតសមត្ថភាពក្នុងការ

[2] យោងតាមមាត្រា ៣៥០ នៃក្រមរដ្ឋវេណីឆ្នាំ២០០៧

ធ្វើសកម្មភាព ក្នុងការបង្កើតកិច្ចសន្យា ឬសកម្មភាពឯកតោភាគីផ្សេងៗផងដែរ។ ការកម្រិតពីរបបសមត្ថភាពក្នុងការធ្វើសកម្មភាពបែបនេះ គឺធ្វើឡើងដើម្បីការពារកុំឲ្យមានការទទួលរងនូវផលប៉ះពាល់ និងការខូចខាតនានា ដែលអាចកើតមានឡើងដោយសារកិច្ចការលក់ទំនិញ របស់ជនដែលមិនមានសមត្ថភាពក្នុងការវិនិច្ឆ័យ ដោយបានចែងមិនអនុញ្ញាតឲ្យជនមួយចំនួន ធ្វើការបង្កើតកិច្ចសន្យាដែលមានសុពលភាពពេញលេញមួយបាននោះ។

ជាធម្មតា ជនដែលមានសមត្ថភាពចុះកិច្ចសន្យាទាំងនោះដូចជាៈ អនីតិជនដែលមានអត្តាធីនភាព និងនីតិជនធម្មតា។ ចំណែកឯ ជនដែលមិនមានសមត្ថភាពក្នុងការចុះកិច្ចសន្យាវិញមានដូចជា អនីតិជនដែលគ្មានអត្តាធីនភាព នីតិជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅ និងនីតិជនដែលស្ថិតនៅក្រោមហិតូបត្ថម្ភ។ ហេតុដូច្នេះហើយ ជនក្រៅពីជនដែលត្រូវបានកម្រិតនូវសមត្ថភាពធ្វើសកម្មភាព គឺជាជនដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពពេញលេញ។ រាល់កិច្ចសន្យាដែលបង្កើតឡើងដោយ ជនក្រៅពីជនដែលត្រូវបានកម្រិតនូវសមត្ថភាព ក្នុងការធ្វើសកម្មភាព គឺមានសុពលភាពពេញលេញ ប្រសិនបើពុំមានមូលហេតុផ្សេងទៀតដែលនាំឲ្យមោឃៈ ឬ មូលហេតុដែលអាចនាំឲ្យមានការលុបចោលកិច្ចសន្យាទេនោះ។

**ក. អនីតិជន**

អនីតិជន គឺជាជនទាំងឡាយណាដែលមានអាយុក្រោម១៨ឆ្នាំ ឬ ជាជនទាំងឡាយណាដែលមិនទានគ្រប់អាយុទៅតាមច្បាប់កំណត់។ ជាទូទៅ អនីតិជនដែលស្ថិតនៅក្រោម១៨ ឆ្នាំតែងតែទទួលបានការអនុញ្ញាតឲ្យធ្វើ ឬមិនឲ្យធ្វើជាមុនសិនពីសំណាក់អ្នកដែលមាន អំណាចមេបា ឬអាណាព្យាបាល។ ហេតុដូចនេះហើយ ទើបគោលការណ៍រាល់សកម្មភាពទាំងឡាយដែលអនីតិជនធ្វើឡើងដោយឆន្ទៈខ្លួនឯង ហើយគ្មានការទទួលយល់ព្រមពីអ្នកមានសិទ្ធិអំណាចមេបា ឬ អាណាព្យាបាលសម្រាប់អនីតិជនទេនោះ គេអាចលុបចោលសកម្មភាពទាំងនោះបាន ដើម្បីជាមធ្យោបាយមួយសម្រាប់ការពារដល់អនីតិជននោះ។

**១.១. សិទ្ធិលុបចោលសកម្មភាពរបស់អនីតិជន**

ដោយសារតែ សកម្មភាពដែលធ្វើឡើងដោយអនីតិជននោះ ជាសកម្មភាពដែលមានវិការៈហេតុដូចនេះហើយ អនីតិជនសាមីខ្លួនផ្ទាល់ ព្រមទាំងអ្នកមានសិទ្ធិអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន អាចធ្វើការលុបចោលនូវសកម្មភាពទាំងនោះបាន។

ថ្វីត្បិតតែ សកម្មភាពដែលធ្វើឡើងដោយអនីតជន អាចត្រូវបានលុបចោល ប្រសិនបើសកម្មភាពនោះធ្វើឡើងដោយគ្មានការយល់ព្រមពីអ្នកមានសិទ្ធិអំណាច ឬអាណាព្យាបាលកក៏ដោយ ក៏នៅមានបញ្ញត្តិពិសេសមួយចំនួន ដែលទទួលស្គាល់នូវការធ្វើកិច្ចសន្យាដោយមានសុពលភាពពេញលេញរបស់ អនីតិជនផងដែរ។

សកម្មភាព ទាំងនោះមានដូចជា សកម្មភាពដែលទទួលបានសិទ្ធិ ឬឲ្យរួចផុតពីកាតព្វកិច្ច និងការទិញវត្ថុប្រើប្រាស់ប្រចាំថ្ងៃជាអាទិ៍។

### ១.២. ការអនុញ្ញាតឲ្យចាត់ចែងទ្រព្យសម្បត្តិសម្រាប់អនីតិជន

នៅពេលដែលអ្នកមានសិទ្ធិអំណាចមេបា ឬអាណាព្យាបាលបានចាត់ចែងទ្រព្យសម្បត្តិដល់អនីតិជន ដូចជាប្រាក់ជាដើមនោះ ដោយមានការកំណត់ពីគោលដៅច្បាស់លាស់ សំរាប់ការប្រើប្រាស់ ឬសម្រាប់ចាយវាយជាធម្មតាដោយមិនបានកំណត់ ពីគោលដៅប្រើប្រាស់ក៏ដោយអនីតិជន ក៏អាចធ្វើកិច្ចសន្យាដោយមានសុពលភាពពេញលេញបានផងដែរ ប្រសិនបើកិច្ចសន្យានោះស្ថិតនៅក្នុងទំហំដែលអាចបាត់បង់តម្លៃបានដោយប្រាក់ដែលបានផ្តល់នោះ។

### ១.៣. អនីតិជនដែលត្រូវបានអនុញ្ញាតឲ្យប្រកបអាជីវកម្ម

ថ្វីត្បិតតែ អនីតិជនជាជនដែលមិនទាន់មានអាយុគ្រប់គ្រាន់សម្រាប់ បំពេញសកម្មភាពផ្សេងៗក៏ពិតមែន ប៉ុន្តែនៅមានចំណុចលើកលែង សម្រាប់ឲ្យអនីតិជនអាចមានសមត្ថភាព ក្នុងការធ្វើកិច្ចសន្យាចាំបាច់សម្រាប់អាជីវកម្មបាន ប្រសិនបើមានការទទួលស្គាល់ ពីអាណាព្យាបាលឲ្យប្រកបអាជីវកម្មដោយឯករាជ្យ។ បើទោះបីជា អនីតិជននោះទទួលបានការផ្តល់សិទ្ធិឯករាជ្យសម្រាប់ ប្រកបអាជីវកម្មដល់ អនីតិជនក៏ដោយប៉ុន្តែរាល់ពេលដែលទិញទំនិញចូល ឬពេលជួលបុគ្គលិកជាដើមនោះ គឺសុទ្ធតែត្រូវទទួលការយល់ព្រមពីអ្នកមានអំណាចមេបា ឬអាណាព្យាបាលជាមុនសិន។ ប្រសិនបើ ការអនុញ្ញាតនោះធ្វើឡើងដោយការប្រទាំងធំដោយតែ អនីតិជននោះបែរជាយកដើមទុនសម្រាប់អាជីវកម្ម ទៅលេងល្បែងស៊ីសង ឬ ទិញទំនិញដែលលក់មិនដាច់ហើយខាតរាល់ដងជាដើម ក្នុងករណីនេះ អ្នកមានអំណាចមេបាជាដើមអាចលុបចោល ឬកម្រិតនូវការអនុញ្ញាតដែលខ្លួនបានផ្តល់ហើយនោះបាន។ នៅពេលដែលមានការលុបចោលនូវការអនុញ្ញាតនោះ ទៅសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់អនីតិជននោះ នឹងត្រឡប់ទៅស្ថានភាពដើមវិញ។ ម៉្យាងវិញទៀត ចំពោះអនីតិជនដែលមានអាយុឈានដល់ ១៦ឆ្នាំ ក៏អាចធ្វើការទ្រទ្រង់ជីវភាពរបស់ខ្លួនដោយឯករាជ្យពីអាណាព្យាបាលបានផងដែរ ដោយអនីតិជននោះគ្រាន់តែ ដាក់ពាក្យស្នើសុំទៅ តុលាការដើម្បីប្រកាសឲ្យមាននូវអត្តាធីនភាពដោយមិនចាំបាច់មានការដាក់ពាក្យស្នើសុំទៅតុលាការក៏បានដែរ។ រាល់អនីតិជនគ្រប់រូប ដែលទទួលបានអត្តាធីនភាព ពួកគេត្រូវបានចាត់ទុកថាក្លាយទៅជា នីតិជនដោយស្របច្បាប់។

## ២. ជននៅក្រោមអាណាព្យាបាលទូទៅ

ជននៅក្រោមអាណាព្យាបាលទូទៅ គឺជាជនទាំងឡាយណាដែលស្ថិតនៅក្នុងស្ថានភាពខ្វះការយល់ដឹង នឹងការវិនិច្ឆ័យដោយសារតែមានវិបត្តិផ្នែកស្មារតី ឬបញ្ហាមានលក្ខណៈជានិរន្តរ៍។ ឧទាហរណ៍ ៖ ជនដែល

មិនអាចទៅទិញជំនួស ជនដែលមិនស្គាល់ឈ្មោះ គ្រួសារ ទីកន្លែងដែលខ្លួនរស់នៅ និងជនដែលធ្លាក់ទៅក្នុងស្ថានភាពជាមនុស្សរុក្ខជាតិជាដើម ។ ការបង្កើតឲ្យមានបទបញ្ញត្តិស្តីពីជននៅក្រោមអាណាព្យាបាលនេះ គឺចែងមកឡើងដើម្បីការពារសិទ្ធិរបស់ជននោះ ដែលមានដូចជាជីវិត រូបកាយ សេរីភាព ទ្រព្យសម្បត្តិ ជាដើមដែលជននោះគ្មានសមត្ថភាពក្នុងការវិនិច្ឆ័យបាន ។ ជាទូទៅដើម្បីអាចធ្វើការគ្រប់គ្រង និងការពារសិទ្ធិរបស់ជនទាំងនោះបាន គឺចាំបាច់ណាស់ក្នុងការបង្កើតឲ្យមានអ្នកអាណាព្យាបាលទូទៅមួយ។

រាល់សកម្មភាព ឬ កិច្ចសន្យាទាំងឡាយណាដែលបង្កើតឡើងដោយជននៅក្រោមអាណាព្យាបាលទូទៅឯកឯងបែបនេះ គឺត្រូវបានគេចាត់ទុកថាវាមានវិការៈ ខាងសមត្ថភាពរបស់គូភាគីដែលជាហេតុនាំឲ្យកិច្ចសន្យា ឬសកម្មភាពទាំងនោះអាចត្រូវបានគេលុបចោលផងដែរ។ ដោយសារតែ អ្នកនៅក្រោមអាណាព្យាបាលទូទៅ គឺជាជនដែលខ្វះសមត្ថភាពខាងឆន្ទៈ ទោះបីជាអ្នកអាណាព្យាបាលទូទៅបានយល់ព្រមដោយបញ្ជាក់ថាជននោះ មានសមត្ថភាពខាងឆន្ទៈឡើងវិញក៏ដោយ ក៏អាចធ្វើការលុបចោលបានផងដែល ដោយសារជនទាំងនោះអាចបាត់បង់ម្តងទៀតនូវសមត្ថភាពខាងឆន្ទៈនោះ ពេលធ្វើសកម្មភាពផងក៏មាន។

ការលុបចោល គឺមិនអាចធ្វើទៅបានឡើយប្រសិនបើសកម្មភាពទាំងនោះ ទាក់ទងទៅនឹងជីវភាពរស់ប្រចាំថ្ងៃ ។ គេមិនអនុញ្ញាតឲ្យមានការលុបចោលរាល់សកម្មភាព ដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃនោះ ដោយសារតែ ប្រសិនបើយើងអនុញ្ញាតឲ្យមានការលុបចោលបែបនោះនាំឲ្យនៅពេលដែល អ្នកនៅក្រោមអាណាព្យាបាលមានសមត្ថភាពឡើងវិញ ហើយមានបំណងចង់ធ្វើសកម្មភាពខាងឆន្ទៈឡើងវិញ ហើយមានបំណងចង់ធ្វើសកម្មភាពពាក់ព័ន្ធ និងជីវភាពរស់នៅប្រចាំថ្ងៃក៏ដោយ ក៏ភាគីម្ខាងទៀតនៅតែមានការបារម្ភថាសកម្មភាពនោះនឹងត្រូវលុបចោលវិញហើយមិនធ្វើកិច្ចការជួញដូរជាមួយជននោះបន្តទៅទៀត ដែលជាហេតុបណ្តាលឲ្យមានការលំបាក ។

### **៣. ជននៅក្រោមហិតូបត្ថម្ភ**

ជនដែលអាចចាត់ទុកបានថាជា ជននៅក្រោមហិតូបត្ថម្ភបានលុះត្រាតែជននោះ ជាជនមានសមត្ថភាពតិចតួចក្នុងការយល់ដឹង និងវិនិច្ឆ័យ អំពីលទ្ធផលបានដោយសារមានវិបត្តិបញ្ញាស្មារតី ឬ អាចនិយាយបានថា គ្រាន់តែជាអ្នកដែលអាចទិញរបស់របរប្រើប្រាស់ សម្រាប់ជីវភាពប្រចាំថ្ងៃតែប៉ុណ្ណោះ តែមិនអាចធ្វើកិច្ចការសំខាន់បានដោយខ្លួនឯង ដោយចាំបាច់ត្រូវមានជំនួយពីអ្នកដទៃ ។ សាមីខ្លួនផ្ទាល់ សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង៤ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬតំណាងអយ្យការអាចដាក់ពាក្យស្នើសុំឲ្យ តុលាការប្រកាសពីការចាប់ផ្តើមហិតូបត្ថម្ភ លើជនណាម្នាក់បាន។ ប៉ុន្តែ បើសិនជាជននោះស្ថិតនៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការ

ប្រកាស ស្ដីពីការចាប់ផ្ដើមអាណាព្យាបាលទូទៅចំពោះជននោះ ។ ជនដែលទទួលបានការប្រកាសចាប់ផ្ដើមហិតូបត្ថម្ភ ហៅថាជននៅក្រោមហិតូបត្ថម្ភ ហើយស្ថិតនៅក្រោមការថែរក្សារបស់ហិតូបត្ថម្ភកៈ ។

ជាគោលការណ៍ រាល់សកម្មភាពទាំងឡាយណាដែល ទាក់ទងទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ ដែលធ្វើឡើងដោយជននៅក្រោមហិតូបត្ថម្ភ គឺមិនត្រូវបានលុបចោលឡើយ លើកលែងតែសកម្មភាពមួយចំនួន ជននៅក្រោមហិតូបត្ថម្ភ អាចធ្វើសកម្មភាពបានលុះត្រាតែ មានការអនុញ្ញាតពីហិតូបត្ថម្ភកៈជាមុន សិន។ បើគ្មានការអនុញ្ញាតជាមុនពីសំណាក់ហិតូបត្ថម្ភកៈទេ សកម្មភាពនោះអាចត្រូវបានលុបចោលហើយសកម្មភាពទាំងនោះមានដូចជា ៖

- ការទទួល ឬការប្រើប្រាស់ទុន
- ការខ្ចីទ្រព្យ ឬការធានា
- ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬ ធ្វើឲ្យបាត់បង់សិទ្ធិដែលទាក់ទងទៅនឹងអចលនវត្ថុ ឬទ្រព្យសម្បត្តិដែលមានសារៈសំខាន់
- ការធ្វើរាល់សកម្មភាពបណ្ដឹង
- ការធ្វើប្រទានកម្ម ឬធ្វើកិច្ចសន្យាស្រុះស្រួល ឬកិច្ចសន្យាមជ្ឈិតកម្ម
- ការទទួលស្គាល់នូវសន្តតិកម្ម ឬការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬការបែងចែកមរតក
- ការប្រកែកមិនទទួលប្រទានកម្ម ឬអច្ច័យទាន ឬការយល់ព្រមទទួលនូប្រទានកម្ម ឬអច្ច័យទានដែលភ្ជាប់បន្ទុក
- ការសាងសង់សំណង់ថ្មី ការសាងសង់ឡើងវិញ ការសាងសង់បន្ថែម ឬជួសជុលខ្នាតធំ
- ការធ្វើភតិសន្យាដែលមានអំឡុងពេលលើសពី ៣ឆ្នាំចំពោះដីធ្លី លើសពី២ ឆ្នាំចំពោះអាគារ និងលើសពី ៦ខែចំពោះចលនវត្ថុ
- សកម្មភាពដែលតុលាការប្រកាសជាពិសេសថាចាំបាច់ត្រូវមានការយល់ព្រមពីហិតូបត្ថម្ភកៈតាមពាក្យសុំរបស់ជនមួយចំនួន ដែលមានសិទ្ធិទៅលើជននៅក្រោមហិតូបត្ថម្ភនោះ។

តាមរយៈការរៀបរាប់ខាងលើ ជនទាំងបីប្រភេទដែលរួមមាន អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភនេះ គឺមិនមានសមត្ថភាពតាមផ្លូវច្បាប់គ្រប់គ្រាន់ឡើយ ដើម្បីធ្វើកិច្ចសន្យាណាមួយបានដោយខ្លួនឯងនោះ លុះត្រាតែទទួលបានការអនុញ្ញាតពីអ្នកដែលមានសិទ្ធស្របច្បាប់ក្នុងការគ្រប់គ្រង និងថែរក្សាជនទាំងនោះជាមុនសិនតែប៉ុណ្ណោះ។ ហេតុដូច្នេះ ប្រសិនបើកិច្ចសន្យាណាមួយដែលធ្វើឡើងដោយមានភាគីណាម្ខាង ជាជនដែលត្រូវបានកម្រិតសមត្ថភាព ជាអ្នកបង្ហាញឆន្ទៈហើយបានបង្កើតកិច្ច

សន្យា ដោយគ្មានការអនុញ្ញាតពីអាណាព្យាបាលស្របច្បាប់ទេនោះ កិច្ចសន្យានោះនឹងត្រូវចាត់ទុកថាមានវិការៈ ដែលនាំឲ្យ កិច្ចសន្យានោះគ្មានសុពលភាព និងមិនមានអានុភាពសម្រាប់ អនុវត្តនាពេលអនាគតបានឡើយ។

## ផ្នែកទី៣ កម្មវត្ថុនៃការបង្កើតកិច្ចសន្យា

នៅក្នុងលក្ខខណ្ឌកិច្ចសន្យាមួយអាចកើតឡើងបានលុះត្រាតែ ភាគីម្ចាស់ការ និង ភាគីអ្នកទទួលម៉ៅការ បានព្រមព្រៀងគ្នា កំណត់អំពីគោលបំណង និងទិសដៅរួមមួយនៅក្នុងកិច្ចសន្យាសម្រាប់យកទៅអនុវត្តឱ្យសម្រេចបានជោគជ័យ និងមានប្រសិទ្ធភាព។ កិច្ចសន្យាមានសុពលភាពនៅពេលដែលកាតព្វកិច្ចដែលកិច្ចសន្យានោះមានវត្ថុមួយជាក់លាក់ និងស្របច្បាប់ ស្របរបៀបរៀបរយសាធារណៈ ឬទំនៀមទំលាប់ដ៏ប្រពៃរបស់សង្គម។ កម្មវត្ថុនៃកិច្ចសន្យា គឺមានន័យថាភាគីទាំងពីរបានធ្វើការព្រមព្រៀងស្ម័គ្រចិត្តចុះកិច្ចសន្យាទៅលើកម្មវត្ថុ ជាក់លាក់នៃកិច្ចសន្យាម៉ៅការណាមួយ ដូចជា កិច្ចសន្យាម៉ៅការសាងសង់ អាចជា ការសាងសង់អគារ សំណង់ ផ្លូវ ស្ពាន និង កិច្ចសន្យាម៉ៅការចាក់បំពេញដី កិច្ចសន្យាចាក់ថ្ម។ល។ កម្មវត្ថុទាំងនោះត្រូវតែជាកម្មវត្ថុស្របច្បាប់ មានន័យថា រាល់ការចាក់ដី ចាក់ថ្ម សំណង់អគារ ផ្លូវ ស្ពាន ត្រូវទទួលការអនុញ្ញាតពីច្បាប់រដ្ឋជាមុន។

### ១. កិច្ចសន្យាម៉ៅការសាងសង់

ភាគីទាំងពីរដែលបានធ្វើកិច្ចព្រមព្រៀង ដោយភាគី ក បានព្រមព្រៀងឱ្យ ភាគី ខ ទទួលម៉ៅការសំណង់ និង ជួសជុល ដែលមានទីតាំងស្ថិតនៅផ្លូវលេខ ៤៨ ភូមិអន្លង់ក្ងាន សង្កាត់ឃ្មួញ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ភាគី ក បានយល់ព្រមឱ្យភាគី ខ ទទួលម៉ៅការសាងសង់របង និងជួសជុលអគារសាលារៀន (សម្ភារៈ និងពលកម្ម) មានអាសយដ្ឋានផ្ទះលេខ ៤៨ ផ្លូវហាណយ ភូមិ អន្លង់ក្ងាន សង្កាត់ ឃ្មួញ ខណ្ឌ សែនសុខ រាជធានី ភ្នំពេញ ។

#### ១.១. រយៈពេលនៃការអនុវត្តន៍ការងារសាងសង់

ការធ្វើកិច្ចសន្យា គឺជាការចងកាតព្វកិច្ចនៃភាគីអ្នកម៉ៅការ ដើម្បីឱ្យមានការកំណត់ពេលវេលាសម្រាប់ ពេលនៃការចាប់ផ្តើមបំពេញការងារ និងសម្រេចការងារឱ្យចោល់តាមពេលកំណត់ដែលភាគីម្ចាស់ការ និងភាគី អ្នកម៉ៅការបានព្រមព្រៀងនៅក្នុងកិច្ចសន្យា ។

ភាគីទាំងពីរបានព្រមព្រៀងគ្នាថារយៈពេលនៃការសាងសង់ គឺភាគី ខ ត្រូវចាប់ផ្តើមការងាររបស់ខ្លួន យ៉ាង យូរ ៧ថ្ងៃ (ប្រាំពីរថ្ងៃ) បន្ទាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យា ។ ភាគី ខ ត្រូវបញ្ចប់ការងារសាងសង់ឱ្យបានក្នុង រយៈពេល ៤ខែ (បួនខែ) ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យា ។

**១.២. ករណីប្រធានសក្តិ**

នៅក្នុងករណីប្រធានស័ក្តិ (មានព្រឹត្តិការណ៍បណ្តាលមកពីគ្រោះធម្មជាតិ បាតុភូតនយោបាយ ដូចជា សង្គ្រាម វិធានការណ៍យោធា វិធានការណ៍សន្តិសុខរបស់រាជរដ្ឋាភិបាល ជម្ងឺឆ្លងគ្រប់ប្រភេទ) ដែលធ្វើឱ្យផ្អាក នឹងមិនអាចបំពេញការងាររបស់ខ្លួនដោយរលូនបាន ភាគី ក ត្រូវធ្វើការទូទាត់ប្រាក់ដែលនៅសេសសល់មកឱ្យ ភាគី ខ ទៅតាមលទ្ធផលការងារដែល ភាគី ខ បានធ្វើហើយជាក់ស្តែង មុនការសម្រេចពន្យាពេល ។ នៅពេល ដែលស្ថានភាពអាក្រក់បានត្រលប់មកធម្មតាវិញ ភាគីទាំងពីរត្រូវបន្តអនុវត្តកិច្ចសន្យានេះឡើងវិញ ដោយត្រូវ ជជែកពិភាក្សា និង ព្រមព្រៀងគ្នា ដើម្បីបន្តការងាររហូតអាចសម្រេចការសាងសង់គម្រោងទាំងមូលជោគជ័យ ទើបអាចបញ្ចប់កិច្ចសន្យាជាស្ថាពរ ។ ប្រសិនបើមានការយឺតយ៉ាវក្នុងការបំពេញការងារ ដោយករណីប្រធានស័ក្តិ ដែលមិនមែនជាការបង្កដោយភាគីណាមួយ នោះភាគីទាំងពីរ នឹងធ្វើការសម្របសម្រួលពេលវេលាសាងសង់តាមការចាំបាច់ ។

**១.៣. ការកែប្រែ ការរុះរើ ឬការសាងសង់ឡើងវិញ**

នៅក្នុងករណីដែលភាគី ក មានការប្រែខុសពីប្លង់ស្ថាបត្យកម្ម និងតារាងសម្រង់តម្លៃ ដោយត្រូវឱ្យមាន ការរុះរើ ឬមានការសាងសង់ឡើងវិញ ភាគី ក ត្រូវរ៉ាប់រងទូទាត់តម្លៃទាំងសម្ភារៈ និងពលកម្មមកឱ្យ ភាគី ខ លើទំហំការងារជាក់ស្តែង ដោយមានការព្រមព្រៀងគ្នាជាមុន។

**១.៤. ទឹកប្រាក់នៃការសាងសង់ លក្ខខណ្ឌ និងរយៈពេលនៃការបង់ប្រាក់**

ភាគីទាំងពីរបានព្រមព្រៀងចុះកិច្ចសន្យាម៉ៅការសាងសង់របង និងជួសជុលអគារសាលារៀនដែលការសាងសង់មានទឹកប្រាក់ ចំណាយសរុប ១៤០,៧២៥.០០ដុល្លារអាមេរិច (ដប់បួនម៉ឺន ប្រាំពីររយ ម្ភៃប្រាំ ដុល្លារអាមេរិច)។

ការបង់ប្រាក់ត្រូវធ្វើជា ៤ដំណាក់កាល៖

- ដំណាក់កាលទី១៖ ភាគី ក ត្រូវបង់ប្រាក់ ៣០%ស្មើនឹងចំនួន ៤២,២១៧.០០ ដុល្លារអាមេរិច (បួនម៉ឺន ពីរពាន់ ពីររយ ដប់ប្រាំពីរដុល្លារអាមេរិច) ជូនភាគី ខ នៅថ្ងៃចុះហត្ថលេខាលើកិច្ចសន្យា។
- ដំណាក់កាលទី២៖ ភាគី ក ត្រូវបង់ប្រាក់ ៤០% ស្មើនឹងចំនួន ៥៦,២៩០.០០ដុល្លារអាមេរិច (ប្រាំម៉ឺន ប្រាំមួយពាន់ ពីររយកៅសិបដុល្លារអាមេរិច) ជូនភាគី ខ នៅពេលដែល ភាគី ខ បានរួចរាល់ការងារបាន៥០%។

- ដំណាក់កាលទី៣៖ ភាគី ក ត្រូវបង់ប្រាក់ ២០% ស្មើនឹងចំនួន ២៨,១៤៥.០០ ដុល្លារអាមេរិច (ពីរម៉ឺនប្រាំបីពាន់ មួយរយសែសិបប្រាំ ដុល្លារអាមេរិច) ជូនភាគី ខ នៅពេលដែល ភាគី ខ បានរួចរាល់ការងារបាន៩០%។
- ដំណាក់កាលទី៤៖ ភាគី ក ត្រូវបង់ប្រាក់ ៧% ស្មើនឹងចំនួន ៩,៨៥០.០០ដុល្លារអាមេរិច (ប្រាំបួនម៉ឺនប្រាំបីរយហាសិប ដុល្លារអាមេរិច) ជូនភាគី ខ នៅពេលដែលភាគី ខ បានបញ្ចប់ការងារបាន១០០%។
- ដំណាក់កាលចុងក្រោយ៖ ភាគី ខ យល់ព្រមតម្កល់ប្រាក់ ៣% ស្មើនឹងចំនួន ៤,២២៣.០០ ដុល្លារអាមេរិច (បួនពាន់ ពីររយ ម្ភៃបី ដុល្លារអាមេរិច) ជាប្រាក់ធានាគុណភាពសំណង់ ទុកនៅ ភាគី ក រយៈពេល ៣ខែ គិតចាប់ពីថ្ងៃដែលភាគី ខ បាប្រគល់គម្រោងជូន ភាគី ក និងបានពិនិត្យ និងទទួលស្គាល់ថាការងារ សាងសង់ស្របតាមប្លង់ស្ថាបត្យកម្ម ដែលបានធ្វើការព្រមព្រៀងចុះកិច្ចសន្យា។ ប្រាក់តម្កល់នេះ ត្រូវ ទូទាត់មកឱ្យភាគី ខ វិញ នៅពេលផុតកំណត់សុពលភាពធានា យ៉ាងយូរបំផុត៧ថ្ងៃ។

**២. កិច្ចសន្យាម៉ៅការចាក់បំពេញដី**

ក្រុមហ៊ុនពីរបានធ្វើការចុះកិច្ចព្រមព្រៀងដោយ ក្រុមហ៊ុន ក តំណាងភាគី ក ជាម្ចាស់ការ និងក្រុមហ៊ុន ខ តំណាងភាគី ខ ជាអ្នកម៉ៅការ ។ ភាគីទាំងពីរ បានព្រមព្រៀងដោយឱ្យភាគី ខ ដែលជាអ្នកម៉ៅការ ធ្វើការចាក់បំពេញដីកន្លែងមានទឹកដក់ ឈូសបំពេញដីផ្នែកខាងក្រោយ ចំនួន៥៥០,០០០ម៉ែត្រគីប ដែលកិច្ចសន្យានេះបានចុះនៅថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០២០ ។

១. ភាគី ក យល់ព្រមឱ្យភាគី ខ ទទួលម៉ៅការចាក់បំពេញដី ដែលមាន ៣ដំណាក់កាល ៖

- ដំណាក់កាលទី១ ចំនួន ១៦០,០០០ ម៉ែត្រគីប ក្នុងរយៈពេល ៥៥ថ្ងៃ
- ដំណាក់កាលទី២ ចំនួន ១៦០,០០០ ម៉ែត្រគីប ក្នុងរយៈពេល ៥៥ថ្ងៃ
- ដំណាក់កាលទី៣ ចំនួន ២៣០.០០០ ម៉ែត្រគីប ក្នុងរយៈពេល ៧២ ថ្ងៃ

២. ភាគី ខ បានយល់ព្រមទទួលម៉ៅការសាងសង់ផ្លូវដូចមានចែងក្នុងចំណុច ១ខាងលើនៃកិច្ចសន្យា។

**៣. កិច្ចសន្យាម៉ៅការចាក់ថ្ម**

កម្មវត្ថុចម្បងនៃកិច្ចសន្យានេះ គឺជាការទិញថ្មដែលមានការធ្វើពិសោធន៍ត្រឹមត្រូវ ពីអ្នកបច្ចេកទេស ដោយភាគី ក គឺជាអ្នកផ្គត់ផ្គង់ថ្ម អោយដល់ភាគី ខ អនុលោមតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យានេះ។ នៅក្នុងកិច្ចសន្យានេះផងដែរ គឺមានការកំណត់ពេលវេលា ដំណើរការការងារ ប្រភេទថ្ម បរិមាណ អំពីតម្លៃ និង ការទូទាត់ប្រាក់ជាដើម ។

**៣.១. កម្មវត្ថុនៃកិច្ចសន្យា**

ភាគី កដែលជាម្ចាស់ការដ្ឋាន ត្រូវមានអាជ្ញាប័ណ្ណក្នុងការធ្វើអាជីវកម្មដឹកថ្ម ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា សន្យានឹងផ្គត់ផ្គង់ថ្ម អោយដល់ភាគី ខ ហើយភាគី ខ មានបំណងក្នុងការទិញថ្មពី ភាគី ក ដើម្បីចាក់បំពេញផ្លូវ ។

**៣.២. ការកំណត់ពេលវេលា**

១ ភាគី ក ត្រូវចាប់ផ្តើមការងារដឹកថ្មពីការដ្ឋានថ្ម ដើម្បីទៅចាក់បំពេញនៅទីតាំងដែលបានកំណត់ និង ភាគី ក ត្រូវបញ្ចប់ការងារនៅត្រឹមថ្ងៃកំណត់ ឬមុនថ្ងៃកំណត់ ។

២ ប្រសិនបើកាលៈទេសៈពិសេសដែលរំខានដែលរំខានដល់ការងាររបស់ភាគី ក តាមស្ថានភាពជាក់ស្តែង ភាគី ក អាចធ្វើការស្នើសុំបាន ហើយភាគី ខ ត្រូវដល់ការពន្យាពេល តាមការព្រមព្រៀងគ្នាជាថ្មីសម្រាប់ការ បញ្ចប់ចាក់ថ្ម ។ កាលៈទេសៈពិសេស នៅក្នុងន័យនេះ គឺចង់សំដៅលើ ស្ថានភាពកើតមានពីករណីប្រធានសក្តិ ឬ សង្គ្រាមស៊ីវិល ឬ ភាពអសន្តិសុខក្នុងសង្គម ឬការហាមឃាត់ពីសំណាក់អាជ្ញាធរសមត្ថកិច្ច ឬច្បាប់ពិសេស ។

**៣.៣. ដំណើរការការងារ ប្រភេទថ្ម និងបរិមាណ**

១. ភាគី ក បានយល់ព្រមដឹកថ្មពីការដ្ឋានថ្ម ដើម្បីទៅចាក់បំពេញនៅទីតាំងដែលបានកំណត់ ជាមួយនឹងចំនួនថ្មដែលបានធ្វើការព្រមព្រៀង ទៅតាមកាលបរិច្ឆេទដែលកំណត់ ។

២. ភាគី ក នឹងបំពេញការងារដឹកថ្ម មកចាក់លើទីតាំងផ្លូវរបស់ភាគី ខ ដោយប្រើប្រាស់ថ្មដែលជាប្រភេទ ថ្មដែលបានព្រមព្រៀង តាមបរិមាណកំណត់ ។ ការត្រួតពិនិត្យអំពីគុណភាព និងបរិមាណថ្មគឺអនុលោមតាមការត្រួតពិនិត្យជាក់ស្តែងរវាងភាគី ក និងភាគី ខ រួមជាមួយនឹងអ្នកជំនាញ ។

**៣.៤. អំពីតម្លៃ និងការទូទាត់ប្រាក់**

១. តម្លៃនៃប្រភេទថ្មតាមកិច្ចសន្យា ដែលភាគីទាំងពីរបានធ្វើការព្រមព្រៀង។ រាល់ការបង់ប្រាក់ ភាគី ខ បង់ជាសាច់ប្រាក់សុទ្ធ ឬតាមរយៈមូលប្បទានបត្រដែលមានសាច់ប្រាក់គ្រប់គ្រាន់។

២. នៅថ្ងៃចុះកិច្ចសន្យានេះ ភាគី ខ ត្រូវបង់ប្រាក់កក់ទៅតាមការព្រមព្រៀង អោយទៅភាគី ក ដើម្បីជាការធានាដល់ការមិនអនុវត្តកាតព្វកិច្ចបង់ប្រាក់។

៣. ភាគី ខ ត្រូវបង់ប្រាក់ថ្លៃថ្ម ក្នុងរយៈពេល០២ (ពីរ) សប្តាហ៍ម្តង ដោយភាគី ក ត្រូវចេញវិក្កយបត្របញ្ជាក់ពីបរិមាណ និងតម្លៃដែលត្រូវបង់ រួចហើយប្រគល់អោយភាគី ខ។ ភាគី ខ មានរយៈពេល ០១ (មួយ) សប្តាហ៍ ដោយគិតចាប់ថ្ងៃទទួលបានវិក្កយបត្រ ក្នុងការរៀបចំទឹកប្រាក់ សម្រាប់បង់ថ្លៃថ្មដល់ភាគី ក។ ក្នុង

ករណី ភាគី ខ មិនបានបង់ប្រាក់ថ្លៃថ្នូដល់ភាគី ក តាមវិក្កយបត្រដែលភាគី ក ប្រគល់អោយទេ ភាគី ក មានសិទ្ធិផ្អាកការ ដឹកថ្មជាបណ្តោះអាសន្នសិន រហូតទាល់តែភាគី ខ បង់ប្រាក់ថ្លៃថ្មគ្រប់ចំនួនអោយដល់ភាគី ក។ ការផ្អាកដឹកថ្មជា បណ្តោះអាសន្ននេះ មិនអាចលើសពីរយៈពេល ០១(មួយ) សប្តាហ៍ឡើយ។ ប្រសិនបើ រយៈពេលផ្អាក ០១ (មួយ) សប្តាហ៍ បានកន្លងផុតទៅ ភាគី ខ នៅតែមិនបង់ប្រាក់ថ្លៃថ្មទៀត ភាគី ក មានសិទ្ធិរំលាយកិច្ចសន្យានេះជា ឯកាតោភាគី ដោយមិនប្រគល់ប្រាក់កក់ខាងលើអោយភាគី ខ វិញឡើយ។

# ជំពូកទី២
# ការព្វកិច្ចរបស់ភាគី

## ជំពូកទី២ កាតព្វកិច្ចរបស់ភាគី

កិច្ចសន្យាម៉ៅការមានអនុភាពតែទៅលើភាគីនៅក្នុងកិច្ចសន្យាតែប៉ុណ្ណោះ ពោលគឺម្ចាស់ការ និងភាគីអ្នកទទួលម៉ៅការ។ ជាទូទៅ គឺមានភាគីម្ចាស់ម៉ៅការ និងភាគីករណីយកិច្ចរបស់អ្នកម៉ៅការ។

យោងតាមមាត្រា៣០៨ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានឱ្យនិយមន័យនៃកាតព្វកិច្ចថា ៖

១. កាតព្វកិច្ច គឺជាទំនាក់ទំនងគតិយុត្តដែលចងបុគ្គលពីរនាក់ ដោយឱ្យបុគ្គលម្នាក់ដែលបានកំណត់មាន ករណីយកិច្ចមួយចំនួនចំពោះបុគ្គលដែលបានកំណត់ម្នាក់ទៀត។

២. បុគ្គលដែលមានករណីយកិច្ច ហៅថាកូនបំណុល រីឯបុគ្គលដែលទទួលផលប្រយោជន៍ពីករណីយកិច្ចនោះហៅថា ម្ចាស់បំណុល។

៣. ម្ចាស់បំណុលមានសិទ្ធិត្រូវគ្នាទៅនឹងករណីយកិច្ចរបស់កូនបំណុល។

### ផ្នែកទី១ កាតព្វកិច្ចរបស់អ្នកម៉ៅការ

កាតព្វកិច្ចរបស់អ្នកម៉ៅការ គឺត្រូវសម្រេចឱ្យបាននូវការងារទៅតាមកិច្ចសន្យាដោយប្រគល់សំណង់គ្មានវិការៈ។ អ្នកម៉ៅការត្រូវអនុវត្តការងារឱ្យបានត្រឹមត្រូវតាមមាត្រដ្ឋានសំណង់ បច្ចេកទេសសំណង់ និងគុណភាព សំណង់។ មួយវិញទៀត អ្នកម៉ៅការក៏មានកាតព្វកិច្ចក្នុងការមើលថែរក្សាសំណង់ និងសម្ភារៈសាងសង់ដោយ ខ្លួនឯង ហើយត្រូវសាងសង់ឱ្យបានទាន់ពេលវេលាតាមការកំណត់របស់កិច្ចសន្យា។ ជាពិសេសអ្នកម៉ៅការត្រូវ ទទួលខុសត្រូវចំពោះសកម្មភាពរបស់ខ្លួន ដែលបណ្តាលឱ្យមានវិការៈកើតឡើងដូចជាការបំពេញការងារដោយ ធ្វេសប្រហែស មិនយកចិត្តទុកដាក់ កេងបន្លំបរិមាណសម្ភារៈសំណង់ និងធ្វើសំណង់មិនរឹងមាំ ជាដើម។

#### ១.ករណីយកិច្ចសម្រេចដោយគ្មានវិការៈ

នៅក្នុងមាត្រា ៦៥៤ កថាខណ្ឌទី១ បានចែងច្បាស់លាស់ថា អ្នកម៉ៅការ មានករណីយកិច្ចសម្រេចការងារដោយគ្មានវិការៈចំពោះម្ចាស់ការ ជាការទទួលខុសត្រូវដែលអ្នកម៉ៅការត្រូវទទួលបន្ទុកក្នុងករណីដែលការងារនោះមានវិការៈ គឺជាប្រភេទមួយនៃការទទួលខុសត្រូវចំពោះការមិនអនុវត្តកាតព្វកិច្ច។ បើការងារពុំមានលក្ខណៈដូចបានព្រមព្រៀងទេ ត្រូវចាត់ទុកថា ជាការងារមានវិការៈ។

ឧទាហរណ៍៖ នៅក្នុងករណីនៃកិច្ចសន្យាម៉ៅការសាងសង់ផ្ទះ ដែលបានព្រមព្រៀងលាបជញ្ជាំងពណ៌ផ្កាឈូក តែប្រសិនបើអ្នកម៉ៅការទៅលាបពណ៌ស្វាយ វិញ ទោះបីជាពណ៌ផ្កាឈូកក៏ដោយ ពណ៌ស្វាយក៏ដោយក៏គ្មានបញ្ហាអ្វីដែរ សម្រាប់នៅក្នុងការរស់នៅ ប៉ុន្តែវាពុំមានលក្ខណៈដូចទៅនឹងកិច្ចព្រមព្រៀង ដែលបានព្រមព្រៀងទុក ហេតុនេះហើយ ត្រូវចាត់ទុកថា ជាការងារដែលមានវិការៈផងដែរ។ ម្យ៉ាងទៀតនៅក្នុងករណីដែលមិន

បានព្រមព្រៀងអំពីលក្ខណៈ បើការងារនោះពុំត្រឹមត្រូវក្នុងការប្រើប្រាស់ដែលបានសន្មតនៅក្នុងកិច្ចសន្យា ឬក្នុងករណីដែលពុំបានសន្មតនៅក្នុងកិច្ចសន្យានៃការប្រើប្រាស់ដែលបានកំណត់ បើការងារនោះមិនត្រឹមត្រូវក្នុងការប្រើប្រាស់ជាប្រក្រតីទេ ត្រូវចាត់ទុកថា ជាការងារមានវិការៈ។

ឧទាហរណ៍១៖ លីណា បានទៅហាងកាត់សម្លៀកបំពាក់របស់វិជ្ជរ៉ា ដើម្បីអោយវិជ្ជរ៉ាកាត់ខោអាវធំមួយកំប្លេសម្រាប់ រដូវរងារ ដើម្បីយកទៅប្រទេសជប៉ុននៅរដូវរងារខាងមុខនេះ តែប្រសិនបើវិជ្ជរ៉ាបានកាត់ខោអាចធំសម្រាប់រដូវក្ដៅ ដូចនៅក្នុងប្រទេសកម្ពុជាវិញ ការងារនោះមិនត្រឹមត្រូវក្នុងការប្រើប្រាស់ដែលបានសន្មត់នៅក្នុងកិច្ចសន្យាទេ ហេតុនេះហើយ ទោះបីជាខោអាវធំនោះ ដេរបានល្អយ៉ាងណាក៏ដោយ ក៏ការងារនោះមានវិការៈដែរ។

ឧទាហរណ៍២៖ មករា ជាអ្នកម៉ៅការម្នាក់ ដែលបានសាងសង់ផ្ទះលើដីរបស់ ដារីដែលជាម្ចាស់ការ ហើយក្រោយពេលប្រគល់ផ្ទះនោះទៅឲ្យ ដារី ប្រសិនបើទឹកកភ្លៀងបានជ្រាបពីពិដាន នៅរដូវភ្លៀងធ្លាក់ ហើយលេចទឹកភ្លៀង ទោះបីជាពុំមានការសន្មត់អំពីការប្រើប្រាស់ពិសេសក្នុងកិច្ចសន្យាក៏ដោយតាមធម្មតា ផ្ទះដែលលេចទឹកភ្លៀងមិនអាចប្រើប្រាស់ជាប្រក្រតីបានឡើយ ដូច្នេះការងារនេះត្រូវបានចាត់ទុកថាជាការងារមានវិការៈ។

ម៉្យាងវិញទៀត ប្រសិនបើអ្នកម៉ៅការ បានធ្វើការផ្ទុយនឹងការបញ្ជា ឬ បើការងារដែលបានធ្វើនោះមិនគ្រប់ចំនួនទេ ត្រូវចាត់ទុកថាជាកាងារមានវិការៈ។ ឧទារហរណ៍ រចនា បានទៅហាងគ្រឿងអលង្ការ ដើម្បីអោយគេធ្វើខ្សែករអោយចំនួនពីរខ្សែរ តែគេបែរជាទៅធ្វើខ្សែដៃអោយរចនាមួយខ្សែទៅវិញ ការងារនេះក៏គេចាត់ទុកថាជាការងារដែលមានវិការៈដែរ។

### ១.១. ការទទួលខុសត្រូវរបស់អ្នកម៉ៅការ ក្នុងករណីការងារមានវិការៈ

នៅក្នុងករណីដែលអ្នកម៉ៅការ បំពេញការងារដោយមិនមានវិការៈ ម្ចាស់ការមានសិទ្ធិទាមទារឱ្យ អ្នកម៉ៅការធ្វើការអនុវត្តឱ្យបានត្រឹមត្រូវតាមកិច្ចសន្យា ឬជ្រើសរើសវិធីណាមួយតាមការអនុញ្ញាតរបស់ក្រមរដ្ឋប្បវេណី។ សិទ្ធិទាមទារនេះ ត្រូវយកមកអនុវត្តនៅក្នុងអំឡុងពេល ១ឆ្នាំ ដែលត្រូវចាប់ផ្ដើមគណនាចាប់ពីពេលដែលម្ចាស់ការ បានដឹង ឬគួរបានដឹងអំពីអត្ថិភាពនៃវិការៈនោះ[3] ។

[3]យោងតាមមាត្រា៦៦១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ការរៀបរាប់ខាងលើនេះ មិនអាចឱ្យអ្នកម៉ៅការរួចផុតពីកាតព្វកិច្ចបានឡើយ ទោះបីជាមានកិច្ចសន្យាពិសេសអំពីការអនុគ្រោះ ឬកម្រិតការទទួលខុសត្រូវក៏ដោយ ប្រសិនបើអ្នកម៉ៅការបានដឹងហើយ តែបែរជាមិន រាយការណ៍ប្រាប់ម្ចាស់ការ[4] ។

### ១.១.១. ការទាមទារឲ្យអនុវត្តពេញលេញរបស់ម្ចាស់ការ

បើការងារមានវិការៈ ម្ចាស់ការអាចទាមទារចំពោះអ្នកម៉ៅការឲ្យអនុវត្តការងារពេញលេញដោយកំណត់អំឡុងពេលសមរម្យបាន។ ការអនុវត្តការងារពេញលេញ ត្រង់នេះគឺមានន័យថាជាទស្សនៈមួយដែលរួមទាំងការជួសជុលនូវវិការៈ និងការធ្វើការងារឡើងវិញ។ ប្រសិនបើ ការអនុវត្តការងារនេះចាំបាច់ត្រូវចំណាយសោហ៊ុយហួសហេតុ បើប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈនោះ អ្នកម៉ៅការអាចបដិសេធបាន។

ឧទាហរណ៍១. ក្នុងករណីដែលបានឲ្យកាត់ខោអាវសម្រាប់រដូវរងារ តែបែរជាកាត់ខោអាវសម្រាប់រដូវក្តៅទៅវិញ ការកែខោអាវសម្រាប់រដូវក្តៅ ឲ្យទៅជាខោអាវសម្រាប់រដូវរងារ មិនអាចធ្វើបាន ឬត្រូវការពេលវេលាយ៉ាងច្រើន។ ក្នុងករណីនេះ ការកាត់ថ្មីជាការងាយស្រួលជាង។

ឧទាហរណ៍២. អគារដែលត្រូវប្រើឥដ្ឋ ក៏ប៉ុន្តែក្នុងនោះមានប្រើប្រទ្បាំឥដ្ឋមួយដុំដែលមានពណ៌ផ្សេងពីគេ។ ក៏ប៉ុន្តែ ក្នុងករណីនេះ ប្រសិនបើប្តូរឥដ្ឋដែលមានពណ៌ខុសគេនោះ តាមបច្ចេកទេស ត្រូវវាយបំបែកជញ្ជាំងនៅជុំវិញនោះសិន ហើយត្រូវធ្វើឲ្យអស់សោហ៊ុយយ៉ាងច្រើនផង។ ឥដ្ឋមួយដុំពណ៌ខុសគេ មិនមែនជាវិការៈធ្ងន់ធ្ងរប៉ុន្មានទេ គ្រាន់តែមិនសូវល្អមើលបន្តិចប៉ុណ្ណោះ។ ថែមទាំងចំណាយសម្រាប់ការជួសជុលច្រើនជ្រុល មិនសមរម្យនឹងទម្ងន់នៃវិការៈផង។ ក្នុងករណីនេះ មិនអាចទាមទារឲ្យជួសជុលឡើងវិញទេ។ បើអ្នកម៉ៅការបានចាប់ផ្តើមធ្វើការងារនោះឡើងវិញ អ្នកម៉ៅការនោះអាចទាមទារឲ្យម្ចាស់ការសងការងារដែលមានវិការៈមកវិញបាន។

### ១.១.២. ការជួសជុលវិការៈដោយម្ចាស់ការ

នៅក្រោយពេលដែលអំឡុងពេលសមរម្យ ដែលបានកំណត់ដើម្បីអនុវត្តការងារឲ្យពេញលេញនោះបានកន្លងផុតហើយ ម្ចាស់ការអាចជួសជុលវិការៈដោយខ្លួនឯងផ្ទាល់ ហើយអាចទាមទារសោហ៊ុយដែលចាំបាច់លើការជួសជុលវិការៈនោះ ពីអ្នកម៉ៅការបាន។ ឧទាហរណ៍ ក្នុងករណីដែលម្ចាស់ការបានឲ្យអ្នកម៉ៅការធ្វើផ្ទះក៏ប៉ុន្តែ ផ្ទះនោះលេចទឹកភ្លៀង ម្ចាស់ការអាចដាស់តឿនឲ្យអ្នកម៉ៅការសាងសង់ឲ្យអនុវត្តការងារពេញលេញ ដោយកំណត់អំឡុងពេលសមរម្យមួយ តែប្រសិនបើអ្នកម៉ៅការពុំបានអនុវត្តការងារពេញលេញ

[4] យោងតាមមាត្រា៦៦១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

ទោះបីជាអំឡុងពេលនោះបានកន្លងផុតហើយក៏ដោយ នោះម្ចាស់ការអាចជួសជុលកន្លែងលេចទឹកភ្លៀងដោយខ្លួនឯងបាន ឬអាចឲ្យជាងផ្ទះផ្សេងទៀត ជាអាទិ៍ជួសជុល ហើយអាចទាមទារសោហ៊ុយនៃការជួសជុលនោះពីអ្នកម៉ៅការបាន។ ក្នុងករណីដែលអ្នកម៉ៅការបានបរាជ័យក្នុងការជួសជុល ឬធ្វើឡើងវិញ ចំពោះម្ចាស់ការ ម្ចាស់ការអាចជួសជុលវិការៈដោយខ្លួនឯង ហើយអាចទាមទារសោហ៊ុយដែលចាំបាច់ក្នុងការជួសជុលវិការៈ ពីអ្នកម៉ៅការបាន ហើយម្ចាស់ការក៏អាចទាមទារចំពោះអ្នកម៉ៅការ ឲ្យបង់សោហ៊ុយដែលចាំបាច់លើការជួសជុលវិការៈជាមុនបានដែរ។ ប៉ុន្តែប្រសិនបើអ្នកម៉ៅការបានបដិសេធការអនុវត្តការងារឲ្យពេញលេញ នោះក្នុងករណីខាងលើទាំងប៉ុន្មានគឺមិនត្រូវបានយកមកអនុវត្តនោះឡើយ។

**១.១.៣.សិទ្ធិរំលាយរបស់ម្ចាស់ការ**

ម្ចាស់ការអាចរំលាយកិច្ចសន្យា ដោយយកមូលហេតុវិការៈនៃការងារ ផ្អែកតាមបញ្ញត្តិទូទៅស្តីពីការរំលាយ នៃគន្ថីស្តីពីកាតព្វកិច្ច។ ក្នុងករណីដែលការអនុវត្តការងារឲ្យពេញលេញ មិនបានសម្រេច ឬក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឲ្យពេញលេញដោយអ្នកម៉ៅការនឹងធ្វើឲ្យមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវ ចំពោះម្ចាស់ការ ។ នៅក្នុងករណីខាងលើនេះ គឺមិនត្រូវយកមកអនុវត្តចំពោះអាគារ ឬសំណង់លើដីផ្សេងទៀតឡើយ ។ ប៉ុន្តែ ត្រូវយកមកកអនុវត្តផងដែរ បើសំណង់នោះពុំមានតម្លៃនឹងប្រើប្រាស់ចំពោះម្ចាស់ការ ដោយសារវិការៈធ្ងន់ធ្ងរពេក ។នៅក្នុងករណីនៃការងារសាងសង់ ជាអាទិ៍ ទោះជាមានវិការៈក៏ដោយក៏ម្ចាស់ការមិនអាចរំលាយកិច្ចសន្យា ហើយទាមទារឲ្យសងនូវថ្លៃសាងសង់បានឡើយ គឺម្ចាស់ការគ្រាន់តែអាចទាមទារឲ្យជួសជុល និង ទាមទារនូវសំណងនៃការខូចខាតប៉ុណ្ណោះ។ ចំពោះសំណង់ដែលពិតជាមានវិការៈមែន តែត្រូវបានសាងសង់រួចហើយ ប្រសិនបើទទួលស្គាល់ឲ្យរំលាយទៅជាលទ្ធផល អ្នកម៉ៅការមិនត្រឹមតែទទួលនូវការខូចខាតដ៏ធ្ងន់ធ្ងរប៉ុណ្ណោះទេ គឺថែមទាំងត្រូវវាយបំបែកនូវសំណង់ដែលត្រូវបានសាងសង់រួចហើយទៀតផង។ នេះគឺជាការមួយធ្វើឲ្យបាត់បង់នូវធនធានយ៉ាងច្រើន ហើយខាតបង់កម្លាំងពលកម្ម និងពេលវេលាផងដែរ ដូច្នេះ ត្រូវជៀសវាងអំពើនេះ។ ក៏ប៉ុន្តែ ក្នុងករណីដែលបានឲ្យក្រុមហ៊ុនសំណង់សាងសង់ផ្ទះ ហើយផ្ទះដែលសាងសង់ហើយនោះ មានគ្រឹះមិនពេញលក្ខណៈ ការសាងសង់មិនត្រឹមត្រូវទាំងស្រុងតាមគំនូសប្លង់ ឬការប្រើគ្រឿងសំណង់ដែលមានគុណភាពមិនល្អនោះជាអាទិ៍ ហើយអាចមានគ្រោះថ្នាក់រហូតដល់អាគារនោះរលំបែកបាក់ ប្រសិនបើមិនរុះអាគារនោះ ហើយសាងសង់គ្រឹះសារជាថ្មីទេ នោះអាគារនោះមានវិការៈធ្ងន់ធ្ងរ ហើយមានតែសាងសង់ឡើងវិញទេទើបអាចប្រើបាន ដោយសារអាគារនោះពុំមានតម្លៃនឹងប្រើប្រាស់ទៀត។ ដូច្នេះហើយ ការរើអាគារនោះ មិនអាចចាត់ទុកថា បានប្រើខ្ជះខ្ជាយនូវសេដ្ឋកិច្ចជាតិឡើយ ។ ម៉្យាងទៀត ការទទួលស្គាល់ឲ្យរំលាយកិច្ចសន្យា ហើយឲ្យសងថ្លៃសាងសង់ ឬ ទទួលបន្ទុកនូវ

សោហ៊ុយសម្រាប់ធ្វើការបដិទានឡើងវិញ គឺជាការកំណត់មួយដែលមិនទុកឲ្យអ្នកម៉ៅការបដិសេធបានឡើយ។

### ១.១.៤. សិទ្ធិទាមទារឲ្យបន្ថយតម្លៃរបស់ម្ចាស់ការ

នៅក្រោយពេលដែលអំឡុងពេលសមរម្យដែលបានកំណត់ដើម្បីអនុវត្តការងារឲ្យពេញលេញនោះ បានកន្លងផុតហើយ ម្ចាស់ការអាចទាមទារឲ្យបន្ថយថ្លៃ តាមការបង្ហាញឆន្ទៈចំពោះអ្នកម៉ៅការ ដោយយកវិការៈនៃការងារមកធ្វើជាមូលហេតុបាន ក្នុងករណីដែលម្ចាស់ការគិតឃើញថា មិនចាំបាច់ធ្វើរហូតដល់រំលាយកិច្ចសន្យាទេ ម្ចាស់ការគ្រាន់តែអាចបន្ថយនូវកម្រៃនៃកិច្ចសន្យាក៏បានដែរ។ ក្នុងករណីដែលមិនស្របនឹងលក្ខខណ្ឌដើម្បីរំលាយកិច្ចសន្យា ម្ចាស់ការអាចទាមទារនូវសំណងនៃការខូចខាតបាន។ ក្នុងករណីដែលការអនុវត្តការងារឲ្យពេញលេញ មិនបានសម្រេច ឬក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឲ្យពេញលេញដោយអ្នកម៉ៅការនឹងធ្វើឲ្យមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវ ចំពោះម្ចាស់ការ។ ហើយកម្រៃក៏នឹងត្រូវបានបន្ថយចុះតាមការទាមទារឲ្យបន្ថយថ្លៃ យោងតាមសមាមាត្រនៃតម្លៃការងារដែលមានភ្ជាប់នូវវិការៈ ជាមួយនឹងតម្លៃនៃការងារដែលគ្មានវិការៈនោះ។

### ១.១.៥.សិទ្ធិទាមទារសំណងនៃការខូចខាតរបស់ម្ចាស់ការ

ការទទួលខុសត្រូវរបស់អ្នកម៉ៅការ ដោយសារការងារមានវិការៈ គឺជាប្រភេទមួយនៃការទទួលខុសត្រូវក្នុងការការមិនអនុវត្តកាតព្វកិច្ចដែរ ដោយហេតុម្ចាស់ការ អាចទាមទារសំណងនៃការខូចខាត ដោយយោងតាមបញ្ញត្តិនៃផ្នែកទី ៣ ( សំណងនៃការខូចខាត ) ជំពូកទី ៤ នៃគន្ថីទី៤ បានដោយមិនអនុវត្ត ឬដោយអនុវត្តព្រមគ្នានូវសិទ្ធិដែលបានកំណត់ ។ ប៉ុន្តែ ចំពោះការអនុវត្តការងារឲ្យពេញលេញជំនួសសំណងនៃការខូចខាត នៅក្រោយពេលដែលអំឡុងពេលសមរម្យដែលបានកំណត់ដើម្បីអនុវត្តការងារឲ្យពេញលេញនោះ បានកន្លងផុតហើយ លុះត្រាតែនៅក្នុងករណីដែលការអនុវត្តការងារឲ្យពេញលេញមិនបានសម្រេច ឬក្នុងករណីដែលវាយតម្លៃថា ការអនុវត្តការងារឲ្យពេញលេញដោយអ្នកម៉ៅការ នឹងធ្វើឲ្យមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវចំពោះម្ចាស់ការទើបអាចទាមទារបាន។ ប្រសិនបើការអនុនុវត្តការងារឲ្យពេញលេញនោះ ចាំបាច់ត្រូវចំណាយសោហ៊ុយច្រើនហួសហេតុ បើប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈនោះ ម្ចាស់ការមិនអាចទាមទារចំនួនទឹកប្រាក់ ដែលសមរម្យនឹងសោហ៊ុយដែលចាំបាច់ ក្នុងការជួសជុលវិការៈនោះថាជាសំណងនៃការខូចខាត។

### ១.១.៦. ក្នុងករណីដែលវិការៈកើតមានឡើងដោយសម្ភារៈ ឬ ការបញ្ជារបស់ម្ចាស់ការ

ប្រសិនបើវិការៈនៃការងារនោះ កើតឡើងពីលក្ខណៈនៃសម្ភារៈដែលបានផ្តល់ដោយម្ចាស់ការ ឬដោយការបញ្ជារបស់ម្ចាស់ការនោះ គឺមិនត្រូវយកមកអនុវត្តឡើយចាប់ពីមាត្រា ៦៥៤ ដល់មាត្រា ៦៥៩។ ការសម្តែងប្រាប់ដែលគ្រាន់តែជាបំណងរបស់ម្ចាស់ការ ពុំត្រូវចាត់ទុកថាជាការបញ្ជាឡើយ។ ក្នុងករណីដែលវិការៈបានកើតឡើង ដោយសារលក្ខណៈនៃសម្ភារៈដែលបានផ្តល់ដោយម្ចាស់ការ ឬ ដោយសារការបញ្ជារបស់ម្ចាស់ការ អ្នកម៉ៅការពុំត្រូវទទួលខុសត្រូវចំពោះវិការៈនៃការងារនោះឡើយ។ ក៏ប៉ុន្តែប្រសិនបើអ្នកម៉ៅការបានដឹងថា សម្ភារៈដែលបានផ្តល់ឲ្យខ្លួននោះ ឬ ការបញ្ជារបស់ម្ចាស់ការនោះ មានភាពមិនត្រឹមត្រូវ ហើយវិការៈបានកើតឡើង ដោយសារខ្លួនបានបំពេញការងារដោយមិនបានប្រាប់ទៅម្ចាស់ការអំពីភាពមិនត្រឹមត្រូវនោះទេការអនុគ្រោះមិនឲ្យអ្នកម៉ៅការទទួលខុសត្រូវក្នុងករណីនេះ មិនមានភាពសមរម្យទេ។

### ២. ករណីយកិច្ចប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ

យោងតាមមាត្រា ៦៥៣ បានបញ្ញត្តថា ប្រាក់កម្រៃត្រូវបង់ដំណាលគ្នានឹងការប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ។ នៅក្នុងន័យម្យ៉ាងទៀតអ្នកម៉ៅការត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ ក្រោយការបញ្ចប់ការងារ។ បន្ទាប់មក តើនៅពេលណា ដែលត្រូវទទួលបាននូវកម្មសិទ្ធិ ហើយនិងតើអ្នកណា ដែលត្រូវទទួលបានកម្មសិទ្ធិលើវត្ថុដែលជាកម្មវត្ថុនៃការងារនេះ។ នៅក្នុងករណីដែលខ្លឹមសារនៃកិច្ចសន្យាម៉ៅការ គឺត្រូវសាងសង់អាគារ។ អាគារនេះមិនអាចក្លាយជាកម្មវត្ថុនៃសិទ្ធិប្រត្យក្សដាច់ដោយឡែកបានឡើយ។ (យោងតាមមាត្រា ១២២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។)

ដូចនេះគេអាចនិយាយបានថា ទោះបីជាអ្នកម៉ៅការ បានផ្តល់នូវសំភារៈសម្រាប់សាងសង់អាគារក៏ដោយ ក៏កម្មសិទ្ធិនៃអាគារនោះ គឺជារបស់ម្ចាស់ការតាំងពីដើមដំបូងតែម្តង។ នៅក្នុងករណីនេះ គាត់អាចធានានូវប្រាក់កំរៃបានតាមរយៈសិទ្ធិឃាត់ទុក ឬឯកសិទ្ធិនៅលើអចលនវត្ថុ។ ចំពោះករណីដែលខ្លឹមសារនៃកិច្ចសន្យាគឺដើម្បីផលិតនូវចលនវត្ថុ ដូចជាសំម្លៀកបំពាក់ ឬស្បែកជើង តើមានលក្ខណៈយ៉ាងដូចម្តេច?

ឧទាហរណ៍៖ ម្ចាស់ការបានផ្តល់នូវសំភារៈសំរាប់កាត់សម្លៀកបំពាក់ ទៅឲ្យអ្នកម៉ៅការ ហើយបញ្ជាគាត់ឲ្យកាត់សំលៀកបំពាក់ ដូច្នេះ តើអ្នកណា ត្រូវទទួលបាននូវកម្មសិទ្ធិ? ហើយនៅក្នុងករណី ដែលអ្នកម៉ៅការ បានផ្តល់នូវសំភារៈ ឬក្រណាត់សំរាប់កាត់សម្លៀកបំពាក់វិញ តើវានឹងទៅជាយ៉ាងណា?

– វាមានគោលគំនិតដែលអាចគិតទៅបានចំនួន ៣គឺ ៖

គំនិតទី ១ គឺថាម្ចាស់ការ ត្រូវទទួលបាននូវកម្មសិទ្ធិ។ មូលដ្ឋានសំរាប់គំនិតនេះ គឺថាអ្នកម៉ៅការអាចគិតថាគាត់បានផលិតនូវទ្រព្យសម្បត្តិរបស់ម្ចាស់ការ និងមិនមែនជាទ្រព្យសម្បត្តិផ្ទាល់របស់គាត់ទេ។

ដោយពិចារណាទៅលើផលទ្ធ:របស់អ្នកម៉ៅការកម្មសិទ្ធិត្រូវបានទៅលើម្ចាស់ការ នៅពេលដែលអ្នកម៉ៅការបានបញ្ចប់ការងារ។

គំនិតទី២ គឺថាអ្នកម៉ៅការ ត្រូវទទួលកម្មសិទ្ធិ ហើយគាត់ត្រូវផ្ទេរកម្មសិទ្ធិដោយការប្រគល់។ គំនិតនេះមានគោលដៅការពារអ្នកម៉ៅការនៅក្នុងករណីដែលម្ចាស់ការមិនអាចបង់នូវប្រាក់កំរៃបាន ដោយសារក្ស័យធន ឬកង្វះទ្រព្យធន។ នៅក្នុងករណីនេះ អ្នកម៉ៅការ អាចដកទុកនូវសោហ៊ុយ តាមរយៈការលក់នូវវត្ថុនោះ។

គំនិតទី៣ គឺថាបុគ្គលដែលផ្តល់នូវសំភារៈទាំងអស់ ឬសំភារៈចំបងត្រូវទទួលបាននូវកម្មសិទ្ធិ។ នេះគឺជាគំនិតមួយ ដែលសម្របសម្រួលនូវគំនិតពីខាងលើ ។ ការអនុវត្តនៅក្នុងប្រទេសជប៉ុន ជាគោលការណ៍ គឺយកតាមគំនិតនេះ។ ក៏ប៉ុន្តែមាត្រានេះប៉ះពាល់ទៅដល់មាត្រាដែលទាក់ទងទៅនឹងការកែច្នៃចលនវត្ថុ។ ខុសពីមាត្រា១៩៩ នៃក្រមរដ្ឋប្បវេណីកម្ពុជា ដែលវាបានបញ្ញត្តិថា ប្រសិនបើអ្នកកែច្នៃបានចូលរួមចំណែកក្នុងការផលិតនូវចលនវត្ថុ ដែលជារបស់អ្នកដទៃ នោះកម្មសិទ្ធិនៅលើវត្ថុនោះ គឺជារបស់ម្ចាស់នៃវត្ថុធាតុដើម នោះអ្នកកែច្នៃត្រូវទទួលបានកម្មសិទ្ធិលើវត្ថុ ដែលបានកែច្នៃនោះ ។ ដូច្នេះ គំនិតនេះមិនអាចអនុវត្តបានជាចាំបាច់ទៅនឹងករណីនោះទេ ដោយផ្អែកទៅលើក្រមរដ្ឋប្បវេណី ។

## ផ្នែកទី ២ កាតព្វកិច្ចរបស់ម្ចាស់ការ

កាតព្វកិច្ចរបស់ម្ចាស់ការ គឺម្ចាស់ការជាភាគីដែលត្រូវមានកាតព្វកិច្ចនៅក្នុងការបង់កម្រៃ ឬប្រគល់កម្រៃ ទៅឱ្យភាគីអ្នកម៉ៅការ និង ជាអ្នកទទួលបានវត្ថុដែលជាកម្មវត្ថុ ដែលបានសម្រេចនៅក្នុងកិច្ចសន្យា។

### ១. ករណីយកិច្ចបង់កម្រៃ

អ្នកម៉ៅការចាំបាច់ត្រូវប្រគល់វត្ថុដែលជាកម្មវត្ថុនៃការងារ កម្រៃត្រូវបង់ព្រមជាមួយគ្នានឹងពេលដែលបានប្រគល់វត្ថុដែលជាកម្មវត្ថុនោះ ហើយក្នុងករណីដែលមិនចាំបាច់ប្រគល់វត្ថុទេ អ្នកម៉ៅការអាចទាមទារឲ្យបង់កម្រៃ បាន ក្រោយពេលបានសម្រេចការងារ[5] ។ ប៉ុន្តែ តាមភាពជាក់ស្តែងមានករណីជាច្រើនដែលអ្នកម៉ៅការពុំមែនជាអ្នកមានធនធានគ្រប់គ្រាន់ ដើម្បីបង់សោហ៊ុយជំនួសជាមុនទាំងអស់ រហូតដល់សម្រេចការងារនោះ។ ម៉្យាងទៀត អ្នកម៉ៅការមានការបារម្ភថា តើម្ចាស់ការច្បាស់ជានឹងបង់ប្រាក់អោយខ្លួនដែរឬទេ ពេលសម្រេចការងារ។ តាមធម្មតា ជាឧទាហរណ៍ ក្នុងករណីម៉ៅការសាងសង់ផ្ទះ ភាគីច្រើនធ្វើកិច្ចព្រមព្រៀងបង់កម្រៃម្តង ពេលចាប់ផ្តើមសាងសង់ ម្តងទៀត ពេលធ្វើគ្រោងផ្ទះ និង បង់កម្រៃដែលនៅសល់ ពេលសាងសង់រួចហើយប្រគល់សំណង់ជាអាទិ៍ ។

[5] យោងតាមមាត្រា ៦៥៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

## ២. ករណីយកិច្ចទទួលវត្ថុដែលជាកម្មវត្ថុនៃកិច្ចសន្យា

នៅក្នុងកិច្ចសន្យាម៉ៅការកាតព្វកិច្ចដ៏ចំបងរបស់ភាគីម្ចាស់ការប្រគល់សម្ភារៈផ្សេងទៀត ដែលបានសន្យាទៅអោយភាគីអ្នកទទួលការ។ ការប្រគល់នេះគឺអាស្រ័យទៅតាមលក្ខខណ្ឌដែលបានជជែកវែកញែកគ្នារវាង ភាគី ទាំងពីរដែលអាចធ្វើឡើងជាដំណាក់កាល ឬតាមទំហំនៃលទ្ធផលការងារដែលភាគីទទួលការសម្រេចបាន។ ម្ចាស់ការមានករណីកិច្ចទទួលយកវត្ថុដែលបានសម្រេចដោយអ្នកម៉ៅការ។ ករណីដែលម្ចាស់ការប្រកែកមិនទទួល នូវការងារនោះ ដោយមានកំហុស នោះម្ចាស់ការត្រូវទទួលខុសត្រូវក្នុងករណីយឺតយ៉ាវនៅក្នុងការទទួលនេះ។ ម្ចាស់ការ មានករណីយកិច្ចនូវវត្ថុ ដែលជាកម្មវត្ថុនៃកិច្ចសន្យាក្រោយពេលដែល អ្នកម៉ៅការបានសម្រេចការងាររបស់ខ្លួន។ យោងតាមមាត្រា៤៥៦ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧បានបញ្ញត្តថា ប្រសិន បើម្ចាស់ការមិនបានទទួលវត្ថុដោយមានកំហុស នោះគាត់ទទួលបន្ទុកកាតព្វកិច្ចនៅក្នុងករណីយឺតយ៉ាវក្នុងការទទួល។

# ជំពូកទី៣
# ការបញ្ចប់កិច្ចសន្យាម៉ៅការ

## ជំពូកទី៣ ការបញ្ចប់កិច្ចសន្យាម៉ៅការ

ការបញ្ចប់កិច្ចសន្យាម៉ៅការ គឺមានគោលការណ៍កាតព្វកិច្ចរបស់ភាគី នៅក្នុងកិច្ចសន្យាត្រូវមានកំណត់អំពីការបញ្ចប់កិច្ចសន្យាដែលមានចែងនៅក្នុងច្បាប់ ឬ មានចែងនៅក្នុងកិច្ចសន្យារវាងភាគីម្ចាស់ការ និង ភាគីអ្នកម៉ៅការ ។

### ផ្នែកទី១ សិទ្ធិរំលាយកិច្ចសន្យា

សិទ្ធិរំលាយកិច្ចសន្យា ជាសិទ្ធិស្វ័យភាពដែលត្រូវបានផ្តល់ឱ្យភាគីនៃការព្រមព្រៀងនៅក្នុងកិច្ចសន្យាដើម្បីបង្ហាញឆន្ទៈរៀងៗខ្លួននៅក្នុងការបង្កើត កែប្រែ ឬរលត់កាតព្វកិច្ច ដែលបានកំណត់ក្នុងវិធានច្បាប់ ដើម្បីឱ្យមានភាពងាយស្រួលនៅក្នុងការរំលាយកិច្ចសន្យា ។ ការរំលាយកិច្ចសន្យា សំដៅទៅលើ សកម្មភាពឯកតោភាគី ដែលធ្វើអោយភាគីទាំងសងខាងរួចផុតពីករណីយកិច្ចរបស់ខ្លួន នៅក្នុងកិច្ចសន្យា លើកលែងតែករណីយកិច្ចសង ការខូចខាត[6] ។ យោងតាមមាត្រា ៣១២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តិថា ការរំលាយកិច្ចសន្យា នេះដែរ ធ្វើឱ្យមានអានុភាពជា ឯកតោភាគី ហើយមិនចាំមានការព្រមព្រៀងពីភាគីម្ខាងទៀតទេ ព្រោះវាគឺជា សកម្មភាពឯកតោភាគី ។

#### ១.សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់ក្នុងច្បាប់

សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់ក្នុងច្បាប់ ត្រូវបានបញ្ញត្តិអំពីការរំលាយកិច្ចសន្យា សម្រាប់ដោះ បញ្ហានៅក្នុងកិច្ចសន្យា ដែលកើតឡើងទៅលើភាគីណាមួយមិនបានអនុវត្តកាតព្វកិច្ច ឬការបំពានលើកិច្ចសន្យា យ៉ាងធ្ងន់ធ្ងរ ឬ ការបាត់បង់កម្មវត្ថុនៃកិច្ចសន្យា[7] ។

ឧទាហរណ៍ នៅក្នុងករណីដែលភាគី ក ដែលជាអ្នកម៉ៅការ មិនបានប្រគល់នូវកម្មវត្ថុនៅក្នុងអំឡុងពេល សមរម្យ នៅក្រោយពេលបរិច្ឆេទកំណត់ទេ ទោះបីជាមានការដាស់តឿនរបស់ភាគី ខ ដែលជាម្ចាស់ការក៏ដោយ ដូចនេះភាគី ខ អាចលើកឡើងពីការរំលាយកិច្ចសន្យាបាន ។ នៅក្នុងករណីនេះ ការរំលាយកិច្ចសន្យារបស់ភាគី ខ ត្រូវបានអនុវត្ត[8] ។

#### ២.សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់ក្នុងកិច្ចសន្យា

សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅក្នុងកិច្ចសន្យា គឺជាសិទ្ធិរំលាយកិច្ចសន្យា ដែលភាគីម្ខាង ឬ សងខាង អាចរំលាយកិច្ចសន្យាបាន ដោយផ្អែកទៅលើកិច្ចសន្យានោះផ្ទាល់តែម្តង។ ភាគីម្ចាស់ការ និងភាគី

[6] យោងតាមមាត្រា៤១១ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[7] យោងតាមមាត្រា ៤០៧ ដល់ ៤១៣ នៃក្រមដដែល

[8] យោងតាមមាត្រា ៤០៨ កថាខណ្ឌទី១ ចំណុច ក នៃក្រមដដែល

ម៉ៅការអាចរំលាយកិច្ចសន្យាបានតាមការព្រមព្រៀងបាន បើទោះបីជាសិទ្ធិរំលាយមិនបានចែងក្នុងកិច្ចសន្យាក៏ដោយ ។

ឧទាហរណ៍៖ ប្រសិនបើ ភាគីបានធ្វើការព្រមព្រៀងគ្នា ដោយភាគី ក បានធ្វើកិច្ចព្រមព្រៀងគ្នាជាមួយនឹង ភាគី ខ ទៅលើកិច្ចសន្យាម៉ៅការសាងសង់ផ្ទះដោយ ភាគី ក ជាម្ចាស់ការ និងភាគី ខ ជាអ្នកម៉ៅការ នៅក្នុងកិច្ចសន្យាជាមុនថា ម្ចាស់ការអាចរំលាយកិច្ចសន្យាជាឯកតោភាគី នៅពេលណាដែលអ្នកម៉ៅការសាងសង់យឺតមួយអាទិត្យជាងពេលកំណត់ក្នុងកិច្ចសន្យា បើទោះជាមានការដាស់តឿនពីម្ចាស់ការក៏ដោយ ដូច្នេះ ម្ចាស់ការ អាចរំលាយកិច្ចសន្យាបាន តាមលក្ខខណ្ឌដែលមានចែងនៅក្នុងកិច្ចសន្យា។ " អានុភាព ឬ វិធីក្នុងការអនុវត្តសិទ្ធិរំលាយកិច្ចសន្យា គឺត្រូវអនុវត្តដូចគ្នាទៅនឹង សិទ្ធិរំលាយកិច្ចសន្យា ដែលបានកំណត់នៅ ក្នុងច្បាប់ លើកលែងតែ ភាគីបានព្រមព្រៀងគ្នាផ្សេងពីនេះ ។ " [9]

### ៣.សិទ្ធិរំលាយកិច្ចសន្យា ដោយផ្អែកទៅលើបញ្ញត្តិពិសេស

បញ្ញត្តិមួយចំនួន នៅក្នុងកិច្ចសន្យាសំខាន់ៗ បានចែងអំពីសិទ្ធិរំលាយកិច្ចសន្យាពិសេសនៅក្នុង កិច្ចសន្យានីមួយៗ ។ យោងតាមមាត្រា ៦៤៧ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧បានបញ្ញត្តិថា ការរំលាយកិច្ចសន្យាអាណត្តិ គឺភាគីនីមួយៗ អាចរំលាយកិច្ចសន្យាអាណត្តិ នៅពេលណាក៏បាន ដោយភាគីម្ខាងត្រូវសងសំណងនៃការខូចខាត ប្រសិនបើបានរំលាយកិច្ចសន្យាអាណត្តិនៅក្នុងអំឡុងពេលដែលធ្វើឲ្យខូចផលប្រយោជន៍ចំពោះភាគីម្ខាងទៀត ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវបានយកមកអនុវត្តឡើយ ប្រសិនបើមានមូលហេតុដែលមានអាចជៀសវាងបាន ។ នៅក្នុងអត្ថន័យនៃច្បាប់ សិទ្ធិរំលាយរបស់ម្ចាស់ការក្នុងពេលនៅក្នុងពេលដែលការងារមិនទាន់បានសម្រេច គឺម្ចាស់ការអាចរំលាយកិច្ចសន្យា នៅពេលណាក៏បាន ចំពោះការងារដែលម្ចាស់ការលែងត្រូវការ ម្ចាស់ការគ្មានភាពចាំបាច់ក្នុងការធ្វើឱ្យការងារនោះសម្រេចដោយបង្ខំទេ ដូចនេះម្ចាស់ការអាចរំលាយកិច្ចសន្យា មុនការបញ្ចប់ការងារនោះដោយអ្នកម៉ៅការ ក៏ប៉ុន្តែក្នុងករណីនេះម្ចាស់ការត្រូវសងសំណងនៃការខូចខាត និង សំណងសោហ៊ុយដែលអ្នកម៉ៅការបានចេញរួចហើយ ព្រមទាំងផលប្រយោជន៍របស់អ្នកម៉ៅការ ដែលអាចទទួល បាននៅពេលការងារខ្លួនបានសម្រេច។ ការរំលាយកិច្ចសន្យាតាមបញ្ញត្តិពិសេសទាំងនេះនឹងត្រូវបានលើកយកមកសិក្សាលំអិត នៅពេលសិក្សាពីកិច្ចសន្យាសំខាន់ៗ ។

## ផ្នែកទី២ លក្ខខណ្ឌនៃការរំលាយកិច្ចសន្យា

មូលហេតុដែលនាំមានការរំលាយកិច្ចសន្យា ដែលភាគីមិនបានអនុវត្តតាមការព្រមព្រៀង ដូចជាការយឺតយ៉ាវនៃការងារ ការមិនអនុវត្តកាតព្វកិច្ចទាំងស្រុង ឬអនុវត្តកាតព្វកិច្ចតែមួយផ្នែក ឬ អលទ្ធភាព

[9] យោងតាមមាត្រា ៤១៤ កថាខណ្ឌ ១ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

នៃការអនុវត្តកាតព្វកិច្ច រួមទាំងការក្ស័យធនរបស់ម្ចាស់ការ ក៏ជាមូលហេតុដែលអាចធ្វើអោយកិច្ចសន្យាអាចបញ្ចប់បានដែរ។

## ១. សិទ្ធិរំលាយរបស់ម្ចាស់ការ នៅក្នុងពេលដែលការងារមិនទាន់បានសម្រេច

ភាគីម្ចាស់ការ អាចរំលាយកិច្ចសន្យា នៅពេលណាក៏បានដោយសងសំណងនៃការខូចខាតរហូតដល់ពេលដែលអ្នកម៉ៅការបានសម្រេចការងាររបស់ខ្លួន[10] ។ ការចែងបែបនេះ គឺដើម្បីឱ្យម្ចាស់ការ និងអ្នកម៉ៅការរួចផុត ពីកាតព្វកិច្ច ប្រសិនបើម្ចាស់ការមិនចង់បន្តការងារតទៅទៀត ។ សរុបមក ម្ចាស់ការ អាចបញ្ឈប់ការងារសាងសង់របស់ខ្លួននៅពេលណាក៏បាន ប៉ុន្តែម្ចាស់ការត្រូវសងសំណងនៃការខូចខាត ដែលកើតចេញពីការរំលាយនេះទៅឲ្យអ្នកម៉ៅការ។

ឧទាហរណ៍៖ ម្ចាស់ការ បានធ្វើកិច្ចសន្យាជាមួយអ្នកម៉ៅការ ដើម្បីសាងសង់ផ្ទះមួយខ្នង នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ ២០២០ ។ ក្រោយពីបានធ្វើកិច្ចសន្យា និងបានចុះហត្ថលេខារួចរាល់ហើយ អ្នកម៉ៅការក៏បានចាប់ផ្តើមទៅទិញសម្ភារៈសម្រាប់ចាប់ដំណើរការសាងសង់ អស់១៥០០ដុល្លារ ហើយចាប់ផ្តើមសាងសង់ នៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០២០ ។ បន្ទាប់ពីដំណើរការបានប្រមាណ ៥ខែ ម្ចាស់ការបានខាតលុយ ក្នុងមុខរបរជំនួញរបស់ខ្លួន ហើយគាត់ក៏បានសម្រេចចិត្តឈប់សាងសង់ផ្ទះនោះ ។ តើម្ចាស់ការ អាចរំលាយកិច្ចសន្យាបានឬទេ ? ម្ចាស់ការអាចរំលាយកិច្ចសន្យានេះបាន ដោយត្រូវសងសំណងនៃការខូចខាតដល់អ្នកម៉ៅការ ។

## ២. ការរំលាយកិច្ចសន្យា មូលហេតុអនុវត្តការងារយឺតយ៉ាវ

បញ្ហាកើតមានឡើងនៅពេលការងារមិនត្រូវបានសម្រេចតាមការកំណត់ ដែលបានចុះកិច្ចសន្យាឬមានការយឺតយ៉ាវដោយសារការមិនយកចិត្តទុកដាក់លើការអនុវត្តការងាររបស់អ្នកម៉ៅការ ដែលខ្លួនត្រូវបំពេញទៅតាមការព្រមព្រៀងជាមួយម្ចាស់ការ ។

ក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ បានបញ្ញត្តិថា ភាគីម្ខាងបានដាស់តឿនភាគីម្ខាង ដែលមិនបានអនុវត្តកាតព្វកិច្ចតាមពេលកំណត់ដោយកំណត់អំឡុងពេលសមស្រប ដើម្បីឲ្យអនុវត្តកាតព្វកិច្ច ហើយកាតព្វកិច្ចមិនត្រូវបានអនុវត្តក្នុងអំឡុងពេលនោះភាគីអាចរំលាយកិច្ចសន្យាបានភ្លាម[11] ។

ឧទាហរណ៍៖ ភាគីម្ចាស់ការ និងភាគីអ្នកម៉ៅការ បានចុះកិច្ចព្រមព្រៀងជាមួយគ្នាលើកិច្ចសន្យាសាងសង់ផ្ទះ ដោយភាគីអ្នកម៉ៅការ ត្រូវបំពេញការងារនេះឲ្យបានចប់រួចរាល់នៅត្រឹមថ្ងៃទី ៣០ ខែឧសភា ឆ្នាំ ២០២១ គិតចាប់ពីថ្ងៃទី ០១ ខែមករា ឆ្នាំ២០២១តទៅ សរុបមានរយៈពេលអនុវត្តសម្រាប់ការសាងសង់រយៈពេល គឺ០៥

[10] យោងតាមមាត្រា៦៦៣ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧

[11] យោងតាមមាត្រា៤០៨ នៃក្រមដដែល

ខែ (ប្រាំខែ)។ ក៏ប៉ុន្តែ ភាគី ខ មិនទាន់បានអនុវត្តការសាងសង់ទៅឲ្យ ក តាមកាលបរិច្ឆេទនៅឡើយទេ ។ នៅក្នុងករណីនេះប្រសិនបើ ភាគី ក ដាស់តឿន ភាគី ខ ឲ្យបំពេញការងារដែលមិនទាន់ហើយរបស់ខ្លួនដោយកំណត់អំឡុង ពេលសមរម្យសម្រាប់អនុវត្តកាតព្វកិច្ច ហើយ ភាគី ខ មិនអាចសម្រេចការងារនៅក្នុងអំឡុងពេលនោះ ភាគី ក អាចរំលាយកិច្ចសន្យាបាន ។

### ៣. ការរំលាយកិច្ចសន្យា ដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ច

ការរំលាយកិច្ចសន្យាដោយផ្អែកលើការមិនអនុវត្តកាតព្វកិច្ចមានអានុភាព នៅពេលដែលភាគីណា មួយយល់ឃើញថាភាគីដែលជាដៃគូរបស់ខ្លួន នៅក្នុងកិច្ចសន្យាមិនអនុវត្តកាតព្វកិច្ចរបស់ខ្លួន ដូចនេះភាគីដែលរងគ្រោះអាចធ្វើការប្តឹងសុំឱ្យរំលាយកិច្ចសន្យាបាន ហើយមូលហេតុត្រូវបានបង្ហាញយ៉ាងជាក់ច្បាស់ថាខ្លួនទទួលរងនូវការបាត់បង់ផលប្រយោជន៍ពីការមិនអនុវត្តកាតព្វកិច្ច ។

ភាគីម្ចាស់ការ និងភាគីអ្នកម៉ៅការអាចរំលាយកិច្ចសន្យាម៉ៅការ ដោយផ្អែកលើបញ្ញត្តិនៃការរំលាយកិច្ចសន្យាបានប្រសិនបើភាគីណាមួយនៃភាគីទាំងពីរបានបំពានកិច្ចសន្យាធ្ងន់ធ្ងរ ។ ក៏ប៉ុន្តែ ការសម្រេចការងារភ្លាមៗ ឬបន្ទាន់ គឺអាស្រ័យលើខ្លឹមសារនៃកិច្ចសន្យា ដូចជាការជួសជុលទៅដល់កន្លែងនោះភាគីមិនអាចរំលាយកិច្ចសន្យាបានទេ ក្រោយពីការសម្រេចការងាររួចហើយ ។

ដោយហេតុថា ការរំលាយកិច្ចសន្យានេះ គឺជាសិទ្ធិដែលបានកំណត់ដោយច្បាប់ទទួលស្គាល់ឲ្យភាគីម្ខាងនៃកិច្ចសន្យាអាចបដិសេធចោលនូវកិច្ចសន្យាដោយខ្លួនឯង ដូច្នេះវាមិនសមហេតុផលទេក្នុងការអនុញ្ញាតឲ្យភាគីម្ខាងរំលាយកិច្ចសន្យា ដោយមូលហេតុមកពីការមិនអនុវត្តកាតព្វកិច្ចបន្តិចបន្តួច។ ដូច្នេះហើយការរំលាយកិច្ចសន្យាអាចធ្វើទៅបានតែក្នុងករណីដែលមាន ការបំពានកិច្ចសន្យាយ៉ាងធ្ងន់ធ្ងរ ប៉ុណ្ណោះ ។ ម៉្យាងទៀត ដរាបណា អ្នកម៉ៅការ មិនបានបញ្ចប់ការងារ ភាគីម្ចាស់ការអាចរំលាយកិច្ចសន្យាម៉ៅការបាន នៅពេលណាមួយដោយការចេញសងទៅលើការខូតខាត ។

### ៤. ការរំលាយកិច្ចសន្យាដោយការក្ស័យធនរបស់ម្ចាស់ការ

ប្រសិនបើភាគីម្ចាស់ការ មានការក្ស័យធន តាមការវិនិច្ឆ័យរបស់ចៅក្រមនោះ អ្នកម៉ៅការ ឬអ្នកគ្រប់គ្រង ការក្ស័យធននោះ អាចលុបចោលកិច្ចសន្យានោះបាន ក្នុងករណីនេះ អ្នកម៉ៅការ អាចធ្វើអន្តរាគមន៍នៅក្នុងការ បែងចែកចំណែកណាមួយដែលពាក់ព័ន្ធនឹងប្រាក់ឈ្នួលលើការងារដែលគេបានបំពេញ ហើយនឹងសម្រាប់ការ ចំណាយផ្សេងទៀត ដែលមិនបានគិតបញ្ចូលទៅក្នុងប្រាក់ឈ្នួលនេះ។ ក្នុងករណីនេះមិនមានភាគីណាមួយអាច ស្នើសុំសំណងការខូតខាត ពីភាគីម្ខាងទៀតដែលបានកើតមានឡើងពីការលុបចោលកិច្ចសន្យានោះបានឡើយ។

ដូចនេះកិច្ចសន្យាម៉ៅការគឺជាកិច្ចសន្យាស្មុគស្មាញ ហើយទាមទារឱ្យមានការសរសេរជាលាយលក្ខណ៍អក្សរឱ្យបានត្រឹមត្រូវ ដែលក្នុងនោះត្រូវកំណត់ឱ្យបានច្បាស់អំពីសិទ្ធិ និងករណីកិច្ចរបស់ភាគីនីមួយៗ។ ប្រសិនបើមិនបានកំណត់នៅក្នុងកិច្ចសន្យាទេ ភាគីត្រូវតែគោរពទៅតាមបញ្ញត្តិដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឬនៅក្នុងច្បាប់ពិសេសប្រសិនបើមាន។ ក្នុងករណីដែលមានជម្លោះអំពីខ្លឹមសារនៃកិច្ចសន្យា ការបកស្រាយគឺត្រូវតែឈរលើស្មារតីនៃការព្រមព្រៀង និងត្រូវពិចារណាទៅលើទម្លាប់នៃការធ្វើកិច្ចសន្យាម៉ៅការ។

### ៥. ការព្រមព្រៀងរបស់ភាគី

ចំពោះការព្រមព្រៀងរបស់គូភាគី គឺស្មើតែគ្រប់កិច្ចសន្យាទាំងអស់ គូភាគីអាចរំលាយបាន ដោយស្ម័គ្រចិត្ត ពីគូភាគីនៃកិច្ចសន្យាទាំងអស់ ។ បើគូភាគីព្រមព្រៀងគ្នាថាមិនត្រូវបន្តទៅមុខ ដែលមើលទៅវាហាក់ដូចជាពិបាកបន្តទៅមុខ បើទោះបីជាបន្តធ្វើ ក៏លទ្ធផលការងារមិនល្អ ហើយការលើកឡើងមូលហេតុដែលជាសំអាង ធ្វើឲ្យភាគីម្ខាងទៀតទទួលយកបាននោះកិច្ចសន្យាម៉ៅការអាចឈានទៅដល់ការព្រមព្រៀងគ្នាមួយជាក់លាក់ ថាគួរតែបន្ត ឬមិនគួរបន្ត។ ហេតុដូចនេះ ប្រសិនបើគូភាគីព្រមព្រៀងគ្នាថាមិនត្រូវបន្តទៅមុខទៀតនោះ ហើយព្រមព្រៀងគ្នា រំលាយកិច្ចសន្យា នោះកិច្ចសន្យាគឺត្រូវរលត់ដោយការព្រមព្រៀងរបស់គូភាគី។ ការព្រមព្រៀងនេះអាចធ្វើឡើង ដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ដោយអាស្រ័យលើទំហំនៃការងារនោះ ។

### ៦. វិការៈនៅក្នុងកិច្ចសន្យា

ចំពោះករណីវិការៈនៃកិច្ចសន្យា គឺចង់សំដៅលើពេលដែលចុះកិច្ចសន្យាគូភាគីនៃកិច្ចសន្យាត្រូវពិនិត្យបានហ្មត់ចត់ និងយកចិត្តទុកដាក់ទៅលើខ្លឹមសារ និងកម្មវត្ថុនៅក្នុងកិច្ចសន្យាឲ្យបានច្បាស់លាស់។ នៅក្រោយពេលដែលកិច្ចសន្យាមានសុពលភាពហើយ ក្រោយពេលដែលគូភាគីបានចុះហត្ថលេខាលើកិច្ចសន្យានោះហើយ ការកែប្រែខ្លឹមសារ ឬកម្មវត្ថុនៅក្នុងកិច្ចសន្យា គឺមានជួបការលំបាកជាមិនខាន ដោយសារតែភាគីដែលទទួលបាននូវផលប្រយោជន៍ អាចបដិសេធដាច់ខាតចំពោះការស្នើសុំកែប្រែនោះ។ ក៏ប៉ុន្តែ ករណីនេះមិនមែនជាលក្ខខណ្ឌដាច់ខាតដែលមិនអាចធ្វើការកែប្រែ ឬមោឃភាពបាននោះទេ ប្រសិនបើភាគីដែលបាត់បង់ផលប្រយោជន៍ បានបង្ហាញនូវមូលហេតុ ឬក៏ជាចំណុចណាមួយច្បាស់លាស់ បញ្ជាក់ថាកិច្ចសន្យានេះកើតឡើងដោយការភាន់ច្រឡំ ដោយសារការបង្ខិតបង្ខំ ឬដោយមូលហេតុផ្សេងទៀត។

ដូចនេះ ការបន្លំបោកប្រាស់ដែលបង្កប់ដោយឧបាយកល អំពើបោកបញ្ឆោត អំពើបន្លំ ភូតភរប្រព្រឹត្តដោយភាគីណាមួយ ដែលជាហេតុបញ្ជាក់ច្បាស់ថា បើគ្មានកិច្ចកលទាំងនោះទេភាគីម្ខាងទៀតប្រាកដជាមិនធ្វើកិច្ចសន្យានោះឡើយ ទាំងនោះគឺជាវិការយ៉ាងសំខាន់សម្រាប់ភាគីដែលបាត់បង់ផលប្រយោជន៍ ប្តឹងសុំលុបកិច្ចសន្យានោះបាន។ (យោងតាមមាត្រា៣៤៥ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧)។

## ផ្នែកទី៣ ការអនុវត្តកាតព្វកិច្ចត្រឹមត្រូវ និងដល់កាលកំណត់នៃកិច្ចសន្យា

នៅក្នុងចំណុចនេះ យើងនឹងលើកឡើងអំពីការអនុវត្តកាតព្វកិច្ចត្រឹមត្រូវ គឺកាតព្វកិច្ចត្រូវបានបំពេញចប់សព្វគ្រប់ និង កិច្ចសន្យាអស់សុពលភាព ។

### ១. កិច្ចសន្យាអស់សុពលភាព

នៅពេលដែលកិច្ចសន្យានេះអស់សុពលភាព សិទ្ធិ និងករណីយកិច្ចរបស់ភាគីម្ចាស់ការ និងអ្នកម៉ៅការត្រូវបានរលត់ ហើយកិច្ចសន្យានេះត្រូវរលត់ដោយខ្លួនឯងតែម្តង។ ក្នុងន័យអស់សុពលភាពនេះដែរ គឺចង់សំដៅដល់ការផុតរលត់អាជ្ញាយុកាលនៃកិច្ចសន្យា ឬ ការព្រមព្រៀង ឬការព្រមព្រៀងគ្នាដោយគូភាគីថាកិច្ចសន្យានេះមិនអាចបន្តទៅទៀតបានដោយប្រការណាមួយ ឬដោយដីកាសម្រេចរបស់ស្ថាប័នមានសមត្ថកិច្ចណាមួយតម្រូវឱ្យកិច្ចសន្យានេះលែងអនុវត្តបានតទៅទៀត ។ លុះត្រាតែ កិច្ចសន្យាគឺបានផុតអាជ្ញាយុកាលហើយ ប៉ុន្តែគូភាគីទាំងពីរនៅតែឯកភាពគ្នាបន្តដោយស្ម័គ្រចិត្ត នោះកិច្ចសន្យានៅតែអាចមានសុពលភាពដដែល ។

យោងតាមក្រឹត្យច្បាប់លេខ៣៨ លើកលែងតែមានច្បាប់ចែងផ្សេងពីនេះ កាតព្វកិច្ចទាំងឡាយដែលកើតចេញពីកិច្ចសន្យា ត្រូវផុតអាជ្ញាយុកាល កាលបើភាគីមិនប្តឹងទាមទារឱ្យអនុវត្តក្នុងអំឡុងពេល ៥ឆ្នាំគិតពីថ្ងៃកំណត់កិច្ចសន្យា ឬបើគ្មានកំណត់ថ្ងៃទេត្រូវគិតពីថ្ងៃចុះកិច្ចសន្យា [12]។

អាជ្ញាយុកាលត្រូវបានផ្អាកសិន កាលបើភាគីកូនបំណុលអវត្តមានពីលំនៅដ្ឋាន ហើយអវត្តមាននេះត្រូវបានរដ្ឋអំណាចមូលដ្ឋានបញ្ជាក់ត្រឹមត្រូវ ចំពោះបណ្តឹងរបស់ភាគីកូនបំណុលក៏ត្រូវផ្អាកអាជ្ញាយុកាលនៃកិច្ចសន្យាដែរ[13] ។ កូនបំណុល ឬអ្នកនឹងលើកយកអាជ្ញាយុកាលមកតវ៉ាបានបើកូនបំណុល ឬអ្នកធានាមិនបានលើក យកអាជ្ញាយុកាលមកតវ៉ាទេ តុលាការត្រូវលើកយកជួសសាមីខ្លួន ភាគីកូនបំណុល ឬអ្នកធានាដែលបានបំពេញ កាតព្វកិច្ចដែលផុតអាជ្ញាយុកាលរួចទៅហើយ ពុំអាចទាមទារយកចំនួនទឹកប្រាក់ ឬតម្លៃនោះមកវិញបានឡើយ ។

### ២. កាតព្វកិច្ចត្រូវបានបំពេញចប់សព្វគ្រប់

ចំពោះការចុះកិច្ចសន្យាម៉ៅការ ប្រសិនបើជាអ្នកម៉ៅការសាងសង់ ផ្លូវ ថ្នល់ អ្នកម៉ៅការមិនទាន់រួច ផុតពីការទទួលខុសត្រូវនោះទេ គឺអ្នកម៉ៅការនៅមានកិច្ចសន្យាធានាលើគុណភាព និងតម្រូវឱ្យមានការ ជួសជុលមួយទៀត ដោយរយៈពេលនៃការជួសជុលនោះ គឺត្រូវមានការកំណត់ឱ្យបានច្បាស់លាស់ ។ ក្នុងករណីនេះ ភាគច្រើនគឺកើតមានចំពោះកិច្ចសន្យាម៉ៅការសាងសង់ផ្លូវ ស្ពានជាដើម ដែលជាទូទៅ អ្នកម៉ៅការ គឺស្ថាប័នរដ្ឋដែលតម្រូវ

[12] យោងតាមមាត្រា២៥ នៃក្រឹត្យ-ច្បាប់លេខ ៣៨ ក្រ.ច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា

[13] យោងតាមមាត្រា២៦ នៃក្រឹត្យ-ច្បាប់លេខ ដដែល

ឱ្យមានកិច្ចសន្យាធានាលើគុណភាព ។ ចំណោកឯ ការទទួលម៉ៅការ ពីក្រុមហ៊ុនឯកជនក៏ដូចគ្នាដែរ ដែលមាន ដូចជាការម៉ៅការសាងសង់ផ្ទះល្វែង ទីកន្លែងកំសាន្តជាដើម ។

ដូចនេះហើយ កាតព្វកិច្ចត្រូវបានបំពេញចប់សព្វគ្រប់ គឺមានន័យថា កិច្ចសន្យាដែលកើតចេញពីការព្រមព្រៀងដែលជាកិច្ចសន្យាម៉ៅការ ជាមួយនឹងកិច្ចសន្យាអមដែលមានរយៈពេលជួសជុល និង ពិនិត្យគុណភាព ត្រូវបានបំពេញចប់សព្វគ្រប់ នៅក្នុងពេលជាមួយនឹងកិច្ចសន្យាម៉ៅការ។

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន

ជាទូទៅនៅក្នុងសង្គមមួយដែលប្រកបទៅដោយការអភិវឌ្ឍន៍ទៅលើគ្រប់វិស័យ គឺជាប្រទេសដែលមានក្របខណ្ឌគតិយុត្តត្រឹមត្រូវ និងគ្រប់គ្រាន់ ដែលគ្រប់សកម្មភាព ឬប្រតិបត្តិពាណិជ្ជកម្មតូចធំ និងគ្រប់ការងារទាំងអស់ត្រូវតែមានច្បាប់ និងមានកិច្ចសន្យាត្រឹមត្រូវ ។ នៅក្នុងនោះប្រទេសកម្ពុជាយើងវិញ បច្ចុប្បន្ននេះមានអាជីវកម្មមួយចំនួននៅមិនទាន់ប្រតិបត្តិតាមច្បាប់បានមួយរយភាគរយនៅឡើយទេ ដូចជាមិនទាន់ចុះបញ្ជីត្រឹមត្រូវ រីឯការងារមួយចំនួននៅមិនទាន់មានកិច្ចសន្យានៅឡើយទេ ។ ការដែលពួកគេមិនព្រមធ្វើកិច្ចសន្យាអោយបានត្រឹមត្រូវច្បាស់លាស់ អាចបណ្តាលមកពី ពេលខ្លះម្ចាស់ការ មានបំណងចង់គេចវេសមិនមានទំនួលខុសត្រូវនិងប្រឈមមុខចំពោះចំណងច្បាប់ នៅពេលដែលមានបញ្ហាណាមួយបានកើតឡើង និងពេលខ្លះទៀតអាចកើតចេញពី អ្នកម៉ៅការ ដែលពួកគេមានបំណងចង់មានសេរីភាពក្នុងការផ្លាស់ប្តូរការងារនៅពេលដែលពួកគេចង់ ។

យ៉ាងណាមិញ បន្ទាប់ពីបានធ្វើការវែកញែក និងបកស្រាយលម្អិតទៅលើប្រធានបទស្តីពី **“របបគតិយុត្តនៃកិច្ចសន្យាម៉ៅការ”** ខាងលើដែលបានលម្អិតជាទិដ្ឋភាពជំពូកៗ ក្នុងនោះរួមមាន ការបង្កើតកិច្ចសន្យាម៉ៅការ កាតព្វកិច្ចរបស់គូភាគី និងការបញ្ចប់កិច្ចសន្យាម៉ៅការជាដើម ។ ជាមួយគ្នានេះដែរ ប្រធានខាងលើមួយនេះ ក៏បានពាំនាំ និងអំណះអំណាងថ្មីជាច្រើន ដើម្បីបំពេញបន្ថែមលើចន្លោះខ្វះខាតនានាស្ថិតនៅក្នុងក្របខណ្ឌនៃទំនាក់ទំនងការងារនៅកម្ពុជា។ មិនតែប៉ុណ្ណោះ អត្ថិភាពនៃភាពច្បាស់លាស់តាមរយៈការលើកយកនូវករណីសិក្សា និងភាពពិតជាក់ស្តែងនៃបញ្ហាដែលបានកើតឡើងរួចមកក្នុងទំនាក់ទំនងការងារ ក៏ត្រូវបានលើកយកមកធ្វើជាឧទាហរណ៍ ដើម្បីស្រាយបំភ្លឺ និងចូលរួមដោះស្រាយទំនាស់ផ្សេងៗដែលកើតមានឡើងក្នុងវិស័យការងារ។ គួរបញ្ជាក់ផងដែរថា ការសម្លឹងមើលនៃប្រធានបទនេះគឺផ្តោតយ៉ាងសំខាន់ទៅលើការកំណត់អត្ថិភាពនៃទំនាក់ទំនងការងាររបស់គូភាគីរវាងអ្នកម៉ៅការ និងអ្នកម្ចាស់ការ តាមរយៈកិច្ចសន្យាម៉ៅការ និងការដឹកនាំគ្រប់គ្រងរបស់ម្ចាស់ការហើយអ្វីដែលពិសេសនោះគឺអានុភាពខាងផ្លូវច្បាប់ ក្រោយពេលចុះកិច្ចសន្យាម៉ៅការរបស់គូភាគី។ ដោយសង្ខេប កិច្ចសន្យាម៉ៅការ គឺចង់សំដៅលើកិច្ចសន្យាមួយដែលភាគីម្ខាង ហៅថាអ្នកម៉ៅការមានករណីយកិច្ចសម្រេចការងារដែលព្រមព្រៀង ក៏ដូចជាមានកាតព្វកិច្ចនៅក្នុងការប្រគល់នូវកម្មវត្ថុដែលស្របទៅតាមច្បាប់ទៅ អោយម្ចាស់ការ ហើយភាគីម្ខាងទៀត ហៅថាម្ចាស់ការ មានករណីយកិច្ចផ្តល់កម្រៃ ចំពោះលទ្ធផលនៃការងារដែលបានធ្វើនោះ ។ ម្យ៉ាងវិញទៀត ទោះបីជាគូភាគីបានព្រមព្រៀងគ្នាធ្វើនូវកិច្ចសន្យាពិសេសមិនទទួលខុសត្រូវក្នុងការធានាក៏ដោយ ចំពោះហេតុការណ៍ដែលបានដឹងហើយ តែបែរជាមិនបានរាយការណ៍ប្រាប់ទេនោះ អ្នកម៉ៅការមិនអាចរួចផុតពីការទទួលខុសត្រូវ ឬ ការកម្រិតការទទួលខុសត្រូវបាន ។ ម្យ៉ាងទៀតម្ចាស់ការ

អាចរំលាយកិច្ចសន្យា នៅពេលណាក៏បាន ដោយសងសំណងនៃការខូចខាត រហូតដល់ពេលដែលអ្នកម៉ៅការបានសម្រេចការងារ ។

សរុបជារួមមក កិច្ចសន្យាម៉ៅការ ជាកិច្ចសន្យាដែលធ្វើឡើងជាដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរឲ្យបានត្រឹមត្រូវ ដោយកំណត់ឲ្យបានច្បាស់អំពីសិទ្ធិ និងករណីយកិច្ចរបស់ភាគីនីមួយៗ។ ប្រសិនបើមិនបានកំណត់នៅក្នុងកិច្ចសន្យាទេ ភាគីត្រូវតែគោរពទៅតាមបញ្ញត្តិដែលបានចែងនៅក្នុងក្រមរដ្ឋប្បវេណី ឬនៅក្នុងច្បាប់ពិសេសប្រសិនបើមាន ។

# អនុសាសន៍

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ននេះ ការងារម៉ៅការដូចជាគម្រោងសាងសង់ គឺមានការកើនឡើងជាលំដាប់ មានទាំងភូមិគ្រឹះ វីឡា ផ្សារទំនើប និងហេដ្ឋារចនាសម្ព័ន្ធ នានា ។ ចំពោះការសាងសង់សំណង់ធំៗទាំងនោះ គឺនឹងមានការបង្កើតនូវកិច្ចសន្យារវាងម្ចាស់ការ និងអ្នកម៉ៅការ ដើម្បីចងភ្ជាប់នូវកាតព្វកិច្ចរបស់ភាគីនៃកិច្ចសន្យាដែលនោះហៅថា កិច្ចសន្យាម៉ៅការ ។ បើយោងតាមមាត្រា ៦៥២ នៃក្រមរដ្ឋប្បវេណី កិច្ចសន្យាម៉ៅការជាកិច្ចសន្យាមួយដែលភាគីម្ខាង ដែលហៅថាអ្នកម៉ៅការ មានករណីយកិច្ចសម្រេចការងារដែលព្រមព្រៀង ហើយភាគីម្ខាងទៀត ហៅថាម្ចាស់ការ មានករណីយកិច្ចផ្តល់កម្រៃលើលទ្ធផលនៃការងារដែលបានធ្វើ ។ សរុបន័យ អោយខ្លឹមកកិច្ចសន្យាម៉ៅការគឺជាការព្រមព្រៀងរវាងម្ចាស់ការ និងអ្នកម៉ៅការឱ្យសម្រេចលទ្ធផលតាមការចង់បានរបស់ម្ចាស់ការ ដោយម្ចាស់ការនឹងបង់ប្រាក់ថ្លៃឈ្នួល ទៅអោយអ្នកម៉ៅការតាមការព្រមព្រៀង ។ កិច្ចសន្យាម៉ៅការ គឺមានច្រើនទម្រង់ណាស់នៅក្នុងសកម្មភាពប្រចាំថ្ងៃ មានដូចជាការម៉ៅការអោយសាងសង់ អគារម៉ៅការអោយជួសជុលផ្ទះ ធ្វើរបងផ្ទះ ម៉ៅការជីកស្រះ ប៉ុន្តែសកម្មភាពដែលមានច្រើនជាងគេ គឺម៉ៅការសាង សង់។ យើងអាចសង្កេតឃើញថា កិច្ចសន្យាអាចធ្វើឡើងជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ក៏បាន ដរាបណាសំណើ និង ស្ទីការត្រូវគ្នា ទើបមានអានុភាពអនុវត្ត និងចងកាតព្វកិច្ចភាគីទាំងអស់ ។ ផ្ទុយទៅវិញ កិច្ចសន្យាសព្វថ្ងៃចាំបាច់ណាស់ត្រូវតែបង្កើតកិច្ចសន្យាជាលាយលក្ខណ៍អក្សរ។ ដោយហេតុថា កិច្ចសន្យាដែលធ្វើជាលាយ លក្ខណ៍អក្សរបានដើរតួនាទីយ៉ាងសំខាន់ក្នុងប្រតិបត្តិការអាជីវកម្មជាច្រើន ដែលកំពុងប្រតិបត្តិនៅក្នុងប្រទេស កម្ពុជា ជាពិសេស គឺការម៉ៅការ ។ កិច្ចសន្យាជាលាយលក្ខណ៍អក្សរមិនត្រឹមតែធ្វើអោយកិច្ចព្រមព្រៀងរវាងភាគី ពាក់ព័ន្ធផ្សារភ្ជាប់គ្នា ដោយស្របច្បាប់ប៉ុណ្ណោះទេ កិច្ចសន្យានេះផងដែរក៏មានតួនាទីជាកំណត់ត្រា និងឯកសារ ពិគ្រោះ ដែលជាផ្នែកមួយនៃគោលនយោបាយអាជីវកម្ម ដើម្បីធានាសុវត្ថិភាព សន្តិភាព សន្តិសុខរបស់ភាគីនៃ កិច្ចសន្យា។ លើសពីនេះទៅទៀត កិច្ចសន្យាជាលាយលក្ខណ៍អក្សរ អាចជាភស្តុតាងយ៉ាងសំខាន់នៅក្នុងករណី មានការយល់ច្រឡំ ពាក្យបណ្តឹង ការរំលោភបំពាន ឈ្លានពាន ឬជម្លោះដែលអាចកើតឡើងនាពេលអនាគតដែល ត្រូវការដោះស្រាយតាមនីតិវិធីវិវាទ ឬ នីតិវិធីផ្សះផ្សារ ។ ជាពិសេស នៅក្នុងទំនាក់ទំនងអាជីវកម្មធំៗ ដែលមាន លក្ខណៈស្មុគស្មាញ រយៈពេលវែង កម្មវត្ថុ និងវិសាលភាពនៃកិច្ចសន្យាមានទំហំធំ ឬមិនអាចកំណត់បាន រួមជាមួយនឹង ចំនួនទឹកប្រាក់នៃកិច្ចសន្យាមានចំនួនច្រើនផងដែរនោះ គឺពិតជាចាំបាច់ណាស់នៅក្នុងការ ធ្វើកិច្ចសន្យាជាលាយលក្ខណ៍អក្សរ ព្រោះវាមានភាពច្បាស់លាស់ អ្វីដែលសំខាន់នោះគឺស្របច្បាប់។ បន្ថែមពីនេះ ទៀត ពេលកិច្ចសន្យាជាលាយលក្ខណ៍អក្សរក្នុងទំនាក់ទំនងអាជីវកម្មត្រូវបានបង្កើតឡើង វាបានចងភ្ជាប់គូភាគី ទាំងសងខាងទៅនឹងកាតព្វកិច្ច ព្រមទាំងមានលក្ខណៈចាប់បង្ខំឱ្យគូភាគីធ្វើការអនុវត្តនូវ

កាតព្វកិច្ចផ្សេងៗ ដូចបានចែងនៅក្នុងកិច្ចសន្យាផងដែរ។ ហេតុដូចនេះហើយគូភាគីទាំងពីររវាងអ្នកម៉ៅការ និង ម្ចាស់ការគប្បីចាំបាច់ បង្កើតកិច្ចសន្យាជាលាយលក្ខណ៍អក្សរ នៅពេលធ្វើកិច្ចព្រមព្រៀងដែលជាទំនាក់ទំនង អាជីវកម្ម ឬជាទំនាក់ទំនងអាជីកម្មផ្សេងទៀតរបស់ខ្លួន ព្រោះដើម្បីអោយទំនាក់ទំនងអាជីវកម្មមានច្បាស់លាស់ និងរលូនទៅមុខ ។

# ឯកសារយោង

# ឯកសារយោង


**១. បទដ្ឋានគតិយុត្ត**

**១.១ ក្រម**

- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ៣ គន្លឹទី ៥, ឆ្នាំ២០១០, ក្រសួងយុត្តិធម៌ ភ្នំពេញ កម្ពុជា

- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ១ គន្លឹទី ១, ឆ្នាំ២០០៧, ក្រសួងយុត្តិធម៌ ភ្នំពេញ កម្ពុជា

**១.២ ច្បាប់**

ច្បាប់ស្តីពីសំណង់ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១១៩/០១៩ ចុះថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១៩

**១.៣ ក្រឹត្យ-ច្បាប់**

ក្រឹត្យ-ច្បាប់ លេខ ៣៨ ក្រ.ច ស្តីពី កិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ចុះថ្ងៃទី ២៨ ខែតុលា ឆ្នាំ១៩៨៨

**២. របាយការណ៍**

- គម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់និងតុលាការរបស់ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជាមេរៀនស្តីពីក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ ឆ្នាំ២០១៥

**៣. គេហទំព័រ និងបណ្តាញសង្គមផ្សេងៗ**

- http://legalcodelawfirm.com បានចូលពិគ្រោះនៅម៉ោង៩:០០នាទីយប់ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២២
- http://www.camlaw.com.kh បានចូលពិគ្រោះនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២
- https://www.jica.go.jp/project/cambodia/0701047/04/ku57pq00001spnva-att/clause02_k.pdf បានចូលពិគ្រោះនៅម៉ោង១០:៣០នាទីព្រឹកថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២២
- https://www.jica.go.jp/project/english/cambodia/025/materials/c8h0vm0000c54sbn-att/seminar01_02.pdfបានចូលពិគ្រោះនៅម៉ោង៣រសៀល ថ្ងៃទី៣ ខែកក្កដា ឆ្នាំ ២០២២
- https://khmer4eversite.files.wordpress.com បានចូលពិគ្រោះនៅម៉ោង៩:០០នាទីយប់ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២២

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១ ៖** គំរូនៃកិច្ចសន្យាម៉ៅការ
- **ឧបសម្ព័ន្ធទី២ ៖** គំរូនៃកិច្ចសន្យាចាក់ថ្ម
- **ឧបសម្ព័ន្ធទី៣ ៖** គំរូនៃកិច្ចសន្យាម៉ៅការ និងជួសជុលរបស់ក្រុមហ៊ុនឯកជន
- **ឧបសម្ព័ន្ធទី៤ ៖** ពាក្យស្នើសុំលិខិតអនុញ្ញាតសាងសង់

# ឧបសម្ព័ន្ធទី១
# គំរូកិច្ចសន្យាម៉ៅការ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យាម៉ៅការ

កិច្ចសន្យាម៉ៅការ ("**កិច្ចសន្យា**") ធ្វើនៅថ្ងៃទី ...... ខែ ............. ឆ្នាំ ................ ដោយ និង រវាង:
លោក ............... ជាពលរដ្ឋខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ......................... មានទីលំនៅផ្ទះលេខ ................ ផ្លូវ ........ សង្កាត់ ............ ខ័ណ្ឌ ....................... រាជធានី ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ពីពេលនេះតទៅហៅថា ("**ម្ចាស់ការ**")

**និង**

លោក ................. ជាពលរដ្ឋខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ ........................ មានទីលំនៅផ្ទះលេខ ............. ផ្លូវ.......... សង្កាត់ .................. ខ័ណ្ឌ ...................រាជធានី ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ពីពេលនេះតទៅហៅថា ("**អ្នកម៉ៅការ**")

បន្ទាប់ពីពេលនេះតទៅម្ចាស់ការនិងអ្នកម៉ៅការហៅជារួមថា ("**ភាគីទាំងពីរ**")

## កិច្ចព្រមព្រៀង

ភាគីទាំងពីរព្រមព្រៀងគ្នាដូចតទៅ

**ប្រការ ១ កម្មវត្ថុនៃកិច្ចសន្យា**

១.១ អ្នកម៉ៅការ បានសំរេចប្រគល់ ការសាងសង់ផ្ទះវីឡាមួយ ដែលមានទីតាំងនៅដីឡូត៍លេខ .......... ផ្លូវ ................ សង្កាត់ ...................... ខ័ណ្ឌ .................. ភ្នំពេញ ដែលនៅជិតអាស័យដ្ឋានបច្ចុប្បន្នរបស់ម្ចាស់ការទៅអោយអ្នកម៉ៅការ ។

១.២ អ្នកម៉ៅការព្រមទទួលយកការងារសាងសង់ផ្ទះវីឡាពីម្ចាស់ការ ។

**ប្រការ ២ រយៈពេលនៃការសាងសង់**

ភាគីទាំងពីរបានព្រមព្រៀងគ្នាថារយៈពេលនៃការសាងសង់គឺត្រូវចំណាយពេល១ឆ្នាំ គិតចាប់ពីថ្ងៃ........... ខែ ............ ឆ្នាំ..................... ដល់ ថ្ងៃទី................ ខែ .................ឆ្នាំ...........................។

**ប្រការ ៣ កាតព្វកិច្ចរបស់ម្ចាស់ការ**

៣.១ ទទួលបន្ទុកក្នុងការស្នើសុំលិខិតអនុញ្ញាតសាងសង់និងលិខិតផ្សេងៗពីអាជ្ញាធរពាក់ព័ន្ធ

៣.២ ផ្តល់ពត៌មានសំខាន់ៗដែលមានសារៈសំខាន់ដល់ការសាងសង់

៣.៣ ត្រូវប្រគល់លុយទៅតាមកាលកំណត់ដែលមានចែងនៅកិច្ចសន្យា

៣.៤ ត្រូវបង្កភាពងាយស្រួលដល់អ្នកម៉ៅការក្នុងការអនុវត្តការងារ និងមិនមានការហាមឃាត់ រឺរំខានដល់ដំណើរការសាងសង់

៣.៥ ត្រូវទទួលខុសត្រូវលើតតិយជនដែលរងគ្រោះដោយសារសំណង់ផ្ទះវីឡាក្នុងអំឡុងពេលសាងសង់ និងចេញសោហ៊ុយព្យាបាល ។

**ប្រការ ៤ កាតព្វកិច្ចរបស់អ្នកម៉ៅការ**

៤.១ ត្រូវអនុវត្តការងារឲ្យតាមបានត្រឹមត្រូវតាមមាត្រដ្ឋានសំណង់ បច្ចេកទេសសំណង់ និង គុណភាពសំណង់

៤.២ មើលថែរក្សាសំណង់ និងសំភារៈសាងសង់ដោយខ្លួនឯង

៤.៣ ត្រូវសាងសង់ឲ្យទាន់ពេលវេលាតាមការកំណត់របស់កិច្ចសន្យា

៤.៤ ត្រូវផ្គត់ផ្គង់សំភារៈនៅក្នុង និងក្រៅផ្ទះវីឡា

៤.៥ ត្រូវផ្គត់ផ្គង់ប្រព័ន្ធទឹក នឹង ភ្លើងដល់ការសាងសង់ ។

**ប្រការ ៥ ទឹកប្រាក់នៃការសាងសង់ លក្ខខណ្ឌ និងរយៈពេលក្នុងការបង់ប្រាក់**

៥.១ ការសាងសង់មានទឹកប្រាក់ចំណាយសរុប ២០០.០០០ (ម្ភៃម៉ឺនដុល្លាអាមេរិច)

៥.២ ការបង់ប្រាក់ត្រូវធ្វើជា ៥ដំណាក់កាល

- ដំណាក់កាលទី១ ៣០% ចាប់ផ្តើមសាងសង់ នឹងបើកជូន៦០.០០០$ (ប្រាំមួយម៉ឺនដុល្លាអាមេរិច)
- ដំណាក់កាលទី២ ២០% ចាក់ជាន់ទីមួយរួច នឹងបើកជូន៤០.០០០$ (បួនម៉ឺនដុល្លាអាមេរិច)
- ដំណាក់កាលទី៣ ២០% ចាក់ជាន់ទីពីររួច នឹងបើកជូន ៤០.០០០$ (បួនម៉ឺនដុល្លាអាមេរិច)
- ដំណាក់កាលទី៤ ២០% ការ៉ូ លាបថ្នាំ សំភារៈ នឹងបើកជូន ៤០.០០០$ (បួនម៉ឺនដុល្លាអាមេរិច)
- ដំណាក់កាលទី៥ ១០% មួយឆ្នាំក្រោយពេលសង់រួច នឹងបើកជូន ២០.០០០$ (ពីរម៉ឺនដុល្លាអាមេរិច)

**ប្រការ ៦ ខសន្យាសើរើតំលៃ**

៦.១ កិច្ចសន្យានេះចំណាយអស់រយៈពេលមួយឆ្នាំ និងទឹកប្រាក់ចំនួន ២០០.០០០ដុល្លាអាមេរិច ដូច្នេះគូភាគីទាំងពីរព្រមព្រៀងក្នុងការអនុវត្តខសន្យាសើរើតំលៃ ។ ម្ចាស់ការមានកាតព្វកិច្ចចំពោះអ្នកម៉ៅការនូវការខាតបង់នៃការសាងសង់ដែលកើតឡើងដោយសារការឡើងថ្លៃសំភារៈសំណង់នៅលើទីផ្សារ ដែលបានកើតឡើងក្នុងពេលគិតចាប់ពីខែទី ៧ ពីថ្ងៃទី១ ខែកក្កដា ឆ្នាំ២០១២ ។ ការសើរើតំលៃនឹងពុំអាចធ្វើឡើង ប្រសិនបើការខាតបង់ស្ថិតនៅក្រោមរយៈពេល ៦ខែដំបូងនៃកិច្ចសន្យា ។ អ្នកម៉ៅការមានកាតព្វកិច្ចផ្តល់ពត៌មាន គ្រប់ព្រឹត្តការណ៍ទាំងអស់ដែលនាំឲ្យមានការអនុវត្តការសើរើតំលៃក្នុងរយៈពេល ១សប្តាហ៍គិតពីថ្ងៃនៃសំភារៈឡើងថ្លៃ តាមរយៈលិខិតអនុសិទ្ធ ។ ការមិនគោរពកាតព្វកិច្ចនេះ និងត្រូវទទួលទណ្ឌកម្មនៃការផ្ញោះសិទ្ធទទួលបានការសើរើតំលៃ ។

៦.២ ការសើរើនោះនឹងកែប្រែទៅតាមតំលៃនៃការកើនឡើងសំភារៈដោយគិតជាភាគរយ នឹងតាមការព្រមព្រៀងរបស់ភាគីទាំងពីរ ។

៦.៣ បើសិនជាតំលៃនៃសំភារៈធ្លាក់ចុះ នោះការអនុវត្តត្រូវធ្វើដូចកថាខណ្ឌ ៦.១ ដែរតែរយៈពេលនៃការសើរើត្រូវគិតពីខែទី៧ ទៅរហូតដល់បញ្ចប់កិច្ចសន្យា នឹងត្រូវមានការជូនដំណឹងពីអ្នកម៉ៅការ ។ ការសើរើតំលៃត្រូវគិតតាមការថយចុះជាភាគរយនៃតំលៃនៃសំភារៈ នឹងតាមការព្រមព្រៀងរបស់ភាគីទាំងពីរ ។

**ប្រការ ៧ ការធានាវិការៈ និងការទទួលខុសត្រូវក្នុងកិច្ចសន្យា និងក្រោយពេលបញ្ចប់កិច្ចសន្យា**

៧.១ អ្នកម៉ៅការមានកាតព្វកិច្ចធានាថាត្រូវមានលក្ខណៈដូចគ្នារវាងកិច្ចសន្យា និងសំណង់ បើការងារនោះពុំត្រឹមត្រូវក្នុងការប្រើប្រាស់ជាប្រក្រតីទេ ត្រូវចាត់ទុកជាការងារមានវិការៈ ។

៧.២ អ្នកម៉ៅការត្រូវទទួលខុសត្រូវលើការសាងសង់របស់ខ្លួនក្នុងអំឡុងពេលសាងសង់ បើសិនជាខុសពីប្លង់ស្ថាបត្យកម្មនៃផ្ទះវីឡា ។ ចំពោះហេតុការណ៍ដែលបានដឹងហើយ តែបែរជាមិនបានរាយការណ៍ប្រាប់ទេនោះ អ្នកម៉ៅការមិនអាចរួចផុតពីការទទួលខុសត្រូវ ឬ ការកម្រិតការទទួលខុសត្រូវបានឡើយ ។

៧.៣ អ្នកម៉ៅការអាចបដិសេធបានបើការចំណាយសោហ៊ុយលើការជួសជុលច្រើនហួសហេតុ បើប្រៀបធៀបទៅនឹងការខូចខាតផលប្រយោជន៍ដោយវិការៈនោះ ។

៧.៤ អ្នកម៉ៅការយល់ព្រមទទួលខុសត្រូវក្នុងករណីមានការយឺតយ៉ាវដែលបណ្តាលមកពីការសាងសង់របស់ខ្លួន ដោយមិនទាមទារថ្លៃឈ្នួលបន្ថែម ។

៧.៥ បើអ្នកម៉ៅការបានចាប់ផ្តើមធ្វើការងារនោះឡើងវិញ អ្នកម៉ៅការនោះអាចទាមទារឲ្យម្ចាស់ការសងការងារដែលមានវិការៈមកវិញបាន

៧.៦ ម្ចាស់ការអាចទាមទារសំណងនៃការខូចខាតបើការងារមានវិការៈ ក្នុងករណីនេះអ្នកម៉ៅការអាចជួសជុលវិការៈនៃការងារនោះ រឺ អាចធ្វើការងារសារជាថ្មី ។

៧.៧ ភាគីទាំងពីរយល់ព្រមកំណត់រយៈពេល ១ឆ្នាំក្នុងការធានាលើវិការៈកំបាំង និង មើលឃើញផ្ទាល់ភ្នែកលើការជួសជុល ឯថ្លៃសំភារៈត្រូវចេញដោយអ្នកម៉ៅការ ប៉ុន្តែក្នុងករណីដែលវិការៈកើតឡើងពីការសាងសង់របស់អ្នកម៉ៅការតែប៉ុណ្ណោះ ។

**ប្រការ ៨ ការជូនដំណឹងជាមុនចំពោះការខកខានក្នុងការអនុវត្តកិច្ចសន្យា**

៨.១ ភាគីទាំងពីរព្រមព្រៀងអនុវត្តកិច្ចសន្យានេះទៅនឹងលក្ខខណ្ឌបង្អង់បន្តការសាងសង់របស់អ្នកម៉ៅការ ។ ការផ្តល់ដំណឹងនេះត្រូវជូនដំណឹងមុន ២ខែនៃការបង្អង់ការអនុវត្តកិច្ចសន្យា តាមរយៈការជូនដំណឹងផ្ទាល់មាត់ រឺលិខិតជាលាយលក្ខអក្សរ ទៅម្ចាស់ការ ។ ភាគីទាំងពីរព្រមព្រៀងគ្នាថាលក្ខខណ្ឌបង្អង់នេះត្រូវបានចែងក្នុងផលប្រយោជន៍របស់អ្នកម៉ៅការ ។

៨.២ ភាគីទាំងពីរព្រមព្រៀងអនុវត្តកិច្ចសន្យានេះទៅនឹងលក្ខខណ្ឌបង្អង់ការបង់ប្រាក់តាមការកំណត់របស់ម្ចាស់ការ ។ ការផ្តល់ដំណឹងនេះត្រូវជូនដំណឹងមុន ២ខែនៃការបង្អង់ការអនុវត្តកិច្ចសន្យា

តាមរយៈការជូនដំណឹងផ្ទាល់មាត់ រឺលិខិតជាលាយលក្ខអក្សរ ទៅអ្នកម៉ៅការ ។ ភាគីទាំងពីរព្រមព្រៀងគ្នាថាលក្ខខណ្ឌបង្អង់នេះត្រូវបានចែងក្នុងផលប្រយោជន៍របស់ម្ចាស់ការ ។

**ប្រការ ៩ ការរំលាយនឹងមូលហេតុ**

៩.១ ម្ចាស់ការអាចរំលាយកិច្ចសន្យា នៅពេលណាក៏បានដោយសងសំណងនៃការខូចខាតរហូតដល់ពេលដែលអ្នកម៉ៅការបានសម្រេចការងារ ។

៩.២ ម្ចាស់ការអាចរំលាយកិច្ចសន្យាដោយយកមូលហេតុវិការៈធ្ងន់ធ្ងរនៃការងារ និងក្នុងករណីដែលការអនុវត្តការងារឲ្យពេញលេញមិនបានសម្រេច ឬ ក្នុងករណីដែលការអនុវត្តការងារឲ្យពេញលេញមិនបានសម្រេច ឬ ក្នុងករណីដែលវាយតំលៃថា ការអនុវត្តការងារឲ្យពេញលេញដោយអ្នកម៉ៅការ នឹងធ្វើឲ្យមានការខូចខាតផលប្រយោជន៍ដោយមិនត្រឹមត្រូវ ។

៩.៣ អ្នកម៉ៅការអាចបញ្ចប់ការងាររបស់ខ្លួនមុនពេលកំណត់តែភាគីទាំងពីរបានព្រមព្រៀងគ្នាថាអ្នកម៉ៅការចាស់ត្រូវរកអ្នកម៉ៅការថ្មីដែលមកបន្តការងាររបស់ខ្លួននឹងមានសម្ថតភាពដូចខ្លួន ។ អ្នកម៉ៅការថ្មីត្រូវបញ្ចប់ការងារតាមការកំណត់ ។

**ប្រការ ១០ ច្បាប់គ្រប់គ្រងនឹងការដោះស្រាយវិវាទ**

កិច្ចសន្យានេះត្រូវគ្រប់គ្រងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បើសិនជាមានវិវាទកើតឡើងរវាងបណ្តាភាគីក្នុងការបកស្រាយកិច្ចសន្យានេះ ឬ លើសិទ្ធ កាតព្វកិច្ច ឬ ការទទួលខុសត្រូវរបស់ភាគី ឬ លើបញ្ហាណាមួយ ភាគីទាំងពីរត្រូវចរចារគ្នាជាមុនសិនរយៈពេល១ខែបន្ទាប់ពីមានបញ្ហា បើនៅតែមិនអាចដោះស្រាយបាន ភាគីទាំងពីរព្រមព្រៀងគ្នាដោះស្រាយវិវាទតាមផ្លូវតុលាការ ។

កិច្ចសន្យានេះត្រូវបានធ្វើឡើងចំនួន ពីរ ច្បាប់ជាភាសាខ្មែរ ដោយមួយច្បាប់រក្សាទុកដោយ ម្ចាស់ការ និងមួយច្បាប់ទៀតរក្សាទុកដោយអ្នកម៉ៅការ ។

**ភាគីទាំងពីរបានយល់ព្រម និងចុះហត្ថលេខាលើកិច្ចសន្យានេះ**

| **ម្ចាស់ការ** | **អ្នកម៉ៅការ** |
| --- | --- |
| ______________________ | ______________________ |
| **លោក** ................................ | **លោក** ............................................ |
| **សាក្សី** | **សាក្សី** |
| ______________________ | ______________________ |

# ឧបសម្ព័ន្ធទី២

# គំរូកិច្ចសន្យាម៉ៅការចាក់ថ្ម

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# <u>កិច្ចសន្យាលើការលក់ថ្ម</u>

កិច្ចសន្យានេះ ត្រូវបានធ្វើឡើងនៅថ្ងៃទី.......ខែ...........ឆ្នាំ.............

**រវាង**

- លោក .......................... អាយុ........... ឆ្នាំ សញ្ជាតិ ........... ជនជាតិ........... កាន់លិខិតឆ្លងដែនលេខ......................... ចុះថ្ងៃទី......ខែ...........ឆ្នាំ...........មានអាសយដ្ឋានបច្ចុប្បន្ន នៅផ្ទះលេខ ....... ផ្លូវលេខ .................... សង្កាត់.................... ខណ................... រាជធានីភ្នំពេញ ដែលចាប់ពីពេលនេះតទៅហៅថា **ភាគី "ក"** ។

**និង**

- លោក.......................... អាយុ........... ឆ្នាំ ជនជាតិ........... សញ្ជាតិ........... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ......................... ចុះថ្ងៃទី......ខែ...........ឆ្នាំ....................មានអាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ.......ភូមិ....... សង្កាត់ ............................ ខណ............................ រាជធានីភ្នំពេញ និងលោក......................... អាយុ........... ឆ្នាំ ជនជាតិ .................. សញ្ជាតិ.................... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ...................... ចុះថ្ងៃទី......ខែ...........ឆ្នាំ...................មានអាសយដ្ឋានបច្ចុប្បន្នផ្ទះលេខ......................... ផ្លូវលេខ ........... សង្កាត់ ......................... ខណ្ឌ......................... រាជធានីភ្នំពេញ ជាតំណាងអោយក្រុមហ៊ុន................................................ ដែលចាប់ពីពេលនេះតទៅហៅកាត់ថា" **ភាគី ខ**" ។

**បុព្វកថា**

***ដោយហេតុថា*** ភាគី ក ជាម្ចាស់ការដ្ឋានថ្មស្ថិតនៅ........ ស្រុក....... ខេត្ត......... និងបានទទួលអាជ្ញាប័ណ្ណក្នុងការធ្វើអាជីវកម្មដីកថ្ម ស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា សន្យាថា និងផ្គត់ផ្គង់ថ្មប្រភេទ..............ដែលចាប់ពីពេលនេះតទៅហៅកាត់ថា **ថ្ម** អោយដល់ភាគី ខ ហើយភាគី ខ មានបំណងក្នុងការទិញថ្មពីភាគី ក ដើម្បីចាក់បំពេញផ្លូវស្ថិតនៅភូមិ......... សង្កាត់............ ក្រុង.............. ខេត្ត.......................។

ក្រោយពីបានពិភាក្សាគ្នា ភាគីទាំងពីរ បានព្រមព្រៀងគ្នាតាមប្រការដូចខាងក្រោម:

**ប្រការ ១ កម្មវត្ថុនៃកិច្ចសន្យា**

កម្មវត្ថុចម្បងនៃកិច្ចសន្យានេះ គឺជាការទិញលក់ថ្មប្រភេទ...................ដែលមានការធ្វើពិសោធត្រឹមត្រូវ ពីអ្នកបច្ចេកទេស ដោយភាគី ក គឺជាអ្នកផ្គត់ផ្គង់ថ្មអោយដល់ភាគី ខ អនុលោមតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យានេះ ។

**ប្រការ ១ ការកំណត់ពេលវេលា**

១-១ ភាគី ក ត្រូវចាប់ផ្តើមការងារដឹកថ្មពីការដ្ឋានថ្មស្ថិតនៅឃុំ...... ស្រុក...... ខេត្ត........ ដើម្បីចាក់បំពេញទីតាំងផ្លូវស្ថិតនៅភូមិ........ សង្កាត់......... ក្រុង.......... ខេត្ត......... ចាប់ពីថ្ងៃទី.....ខែ.........ឆ្នាំ........ និងភាគី ក ត្រូវបញ្ចប់ការងារនៅត្រឹមថ្ងៃ ឬនៅមុនថ្ងៃទី........ខែ............ឆ្នាំ..............ជាកំហិត ។

១-២ ប្រសិនបើកាលៈទេសៈពិសេសដែលរំខានដល់ការងាររបស់ភាគី ក តាមស្ថានភាពជាក់ស្តែង ភាគី ក អាចទាមទារអោយមានការពន្យាពេល ដើម្បីបញ្ចប់គម្រោងការងារ ភាគី ក អាចស្នើសុំ ហើយភាគី ខ ត្រូវផ្តល់ឱ្យនូវការពន្យាពេលសមរម្យមួយ តាមការព្រមព្រៀងគ្នាជាថ្មី សម្រាប់ការបញ្ចប់គម្រោងការងារចាក់ថ្ម ។ ស្ថានភាពដែលអាចចាត់ទុកជា កាលៈទេសៈពិសេសរួមមាន ការរំខានដែលកើតឡើងពីករណីប្រធានសក្តិ ឬសង្គ្រាមស៊ីវិល ឬភាពចលាចលក្នុងសង្គម ឬការហាមឃាត់ដោយអាជ្ញាធរមានសមត្ថកិច្ច ឬដោយច្បាប់ពិសេសណាមួយ ។

**ប្រការ ២ ដំណើរការការងារ ប្រភេទថ្ម និងបរិមាណ**

១-៣ ភាគី ក យល់ព្រមដឹកថ្មពីការដ្ឋានថ្មស្ថិតនៅ........ ស្រុក........ ខេត្ត........ ដើម្បីចាក់បំពេញទីតាំងផ្លូវស្ថិតនៅភូមិ.......... សង្កាត់............ ក្រុង......... ខេត្តកណ្តាល **មានចំហំ............ (..............)ម៉ែត្រគីប** តាមកាលបរិច្ឆេទដែលមានចែងក្នុងប្រការ ១ ខាងលើ ។

២-១ ភាគី ក និងបំពេញការងារដឹកថ្ម មកចាក់លើទីតាំងផ្លូវរបស់ភាគី ខ ខាងលើ ដោយប្រើប្រាស់ថ្មប្រភេទ..................តាមបរិមាណកំណត់ខាងលើ ។ ការត្រួតពិនិត្យលើគុណភាព និងបរិមាណថ្ម គឺអនុលោមតាមការត្រួតពិនិត្យជាក់ស្តែងរវាងភាគី ក និងភាគី ខ រួមជាមួយនឹងអ្នកជំនាញ ។

**ប្រការ ៣ តម្លៃថ្ម និងការទូទាត់ប្រាក់**

៣-១ តម្លៃនៃប្រភេទថ្មតាមកិច្ចសន្យានេះ **គឺមានតម្លៃចំនួន........ (...............) ដុល្លារអាមេរិក ក្នុងបរិមាណ ....... (.......................) ម៉ែត្រគីប**។ រាល់ការបង់ប្រាក់ ភាគី ខ អាចបង់ជាសាច់ប្រាក់សុទ្ធ ឬតាមរយៈមូលប្បទានបត្រដែលមានសាច់ប្រាក់គ្រប់គ្រាន់។

៣-២ នៅថ្ងៃចុះកិច្ចសន្យានេះ ភាគី ខ ត្រូវបង់ប្រាក់កក់ចំនួន.......................................ដុល្លារអាមេរិក អោយទៅភាគី ក ដើម្បីជាការធានាដល់ការមិនអនុវត្តកាតព្វកិច្ចបង់ប្រាក់។

៣-៣ ភាគី ខ ត្រូវបង់ប្រាក់ថ្លៃថ្ម ក្នុងរយៈពេល ០២ (ពីរ) សប្តាហ៍ម្តង ដោយភាគី ក ត្រូវចេញវិក្កយបត្របញ្ជាក់ពីបរិមាណ និងតម្លៃដែលត្រូវបង់ រួចហើយប្រគល់អោយភាគី ខ ។ ភាគី ខ មានរយៈពេល ០១ (មួយ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃទទួលបានវិក្កយបត្រ ក្នុងការរៀបចំទឹកប្រាក់ សម្រាប់បង់ថ្លៃថ្មដល់ភាគី ក។ ក្នុងករណីភាគី ខ មិនបានបង់ប្រាក់ថ្លៃថ្មដល់ភាគី ក តាមវិក្កយបត្រដែលភាគី ក ប្រគល់អោយទេ ភាគី ក មានសិទ្ធិផ្អាកការដឹកថ្មជាបណ្តោះអាសន្នសិន រហូតទាល់តែភាគី ខ បង់ប្រាក់ថ្លៃថ្មគ្រប់ចំនួនអោយដល់ភាគី ក។ ការផ្អាកដឹកថ្មជាបណ្តោះអាសន្ននេះ មិនអាចលើសពីរយៈពេល ០១ (មួយ) សប្តាហ៍ឡើយ បើរយៈពេលផ្អាក ០១ (មួយ) សប្តាហ៍ បានកន្លងផុតទៅ ភាគី ខ នៅតែមិនបង់ប្រាក់ថ្លៃថ្មទៀត ភាគី ក មានសិទ្ធិរំលាយកិច្ចសន្យានេះ ជាឯកតោភាគី ដោយមិនប្រគល់ប្រាក់កក់ខាងលើ អោយភាគី ខ វិញឡើយ។

## ប្រការ ៤ សិទ្ធិ និងកាតព្វកិច្ចរបស់ភាគី ខ

៤-១ ភាគី ខ ត្រូវផ្តល់ទៅឱ្យភាគី ក នូវលទ្ធភាពក្នុងការចូលទៅកាន់ទីតាំងដីដោយគ្មានឧបសគ្គ នៅក្នុងពេលម៉ោងធ្វើការ ( ៨:០០ ព្រឹក ដល់ ៥:០០ល្ងាច ) ពីថ្ងៃ.........ដល់ថ្ងៃ........... លើកលែងថ្ងៃឈប់សម្រាក ឬពេលផ្សេងទៀត ដែលភាគីអាចនឹងព្រមព្រៀងគ្នាដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរបាន។

៤-២ ភាគី ខ ត្រូវបង់ប្រាក់ជូនអ្នកភាគី ក តាមការកំណត់ដូចដែលមានចែងក្នុងប្រការ ៣ ខាងលើ និងតាមចំនួន ដែលមានក្នុងវិក្កយបត្រចេញដោយភាគី ក អោយបានទាន់ពេលវេលា។

៤-៣ ភាគី ខ ឬតំណាង ត្រូវចូលរួមពិនិត្យពីបរិមាណ និងគុណភាពថ្ម ជាមួយភាគី ក ដើម្បីកំណត់អំពីកិរិតនៃការងារចាក់ថ្ម ដែលបានភាគី ក បានសម្រេច ក្នុងគោលបំណងធ្វើការទូទាត់ប្រាក់ដល់ភាគី ក។

៤-៤ រាល់ការចំណាយលើការបង់ពន្ធ ឬសួយសារអាករផ្សេងៗ ដែលតម្រូវដោយអាជ្ញាធរមានសមត្ថកិច្ច គឺជាបន្ទុករបស់ភាគី ខ ។

## ប្រការ ៥ សិទ្ធិ និងភារកិច្ចរបស់ភាគី ក

៥-១ ភាគី ក ត្រូវប្រើប្រាស់នូវកំលាំងពលកម្ម សម្ភារៈ ឧបករណ៍ គ្រឿងម៉ាស៊ីន និងសេវាផ្សេងទៀត ដែលចាំបាច់សម្រាប់ការបំពេញការងាររបស់ខ្លួន។ រាល់ការចំណាយ លើការជួលកំលាំងពលកម្ម សម្ភារៈ ឧបករណ៍ គ្រឿងចក្រ និងសេវាដឹកជញ្ជូនថ្ម ពីការដ្ឋានថ្មស្ថិតនៅឃុំ......... ស្រុក........ ខេត្ត............. រួមទាំងការចំណាយផ្សេងៗ តាមផ្លូវក្នុងពេលដឹកជញ្ជូនថ្ម គឺជាបន្ទុករបស់ភាគី ក។

៥-២ ភាគី ក ត្រូវទទួលខុសត្រូវក្នុងការទទួល និងចំណាយ សម្រាប់រាល់លិខិតអនុញ្ញាត អាជ្ញាប័ណ្ណ និងវិញ្ញាបនប័ត្រនានា ដែលចាំបាច់សំរាប់អនុវត្តការងារដឹកថ្មរបស់ខ្លួន។

៥-៣ ភាគី ក ត្រូវផ្តល់នូវសេចក្តីជូនដំណឹងទាំងអស់ ដែលត្រូវបានតម្រូវ និងអនុវត្តទៅតាមច្បាប់ បទបញ្ជា វិធាន បទប្បញ្ញត្តិ និងសេចក្តីបង្គាប់ទាំងអស់ របស់អាជ្ញាធរមានសមត្ថកិច្ច ដែលមានអនុភាពនៅក្នុងអំឡុងពេលនៃការអនុវត្តកិច្ចសន្យានេះ ហើយដែលមានការពាក់ព័ន្ធទៅនឹងការងារ ការការពារសុខភាពសាធារណៈ ឬការបង្កើនសុវត្ថិភាព។ ភាគី ក ទទួលខុសត្រូវតែចំពោះព្យសនកម្មដែលកើតចេញមកពីការធ្វេសប្រហែស និងកំហុសរបស់ខ្លួនតែប៉ុណ្ណោះ ក្នុងពេលដឹកជញ្ជូនថ្ម។

៥-៤ ភាគី ក ត្រូវមានវិធានការការពារទ្រព្យសម្បត្តិរបស់ភាគី ខ និងទ្រព្យសម្បត្តិរបស់តតិយជន ដែលមាននៅក្នុងទីតាំងការដ្ឋានភាគី ខ ពីការរងការខូចខាតដោយចៃដន្យដោយសារការបំពេញភារកិច្ចរបស់ខ្លួនតាមរយៈកិច្ចសន្យានេះ។

៥-៥ ភាគី ក មានកាតព្វកិច្ចប្រគល់ប្រាក់កក់ ដូចមានចែងក្នុងចំណុច ៣-២ ខាងលើ អោយដល់ភាគី ខ ក្នុងករណីដែលកិច្ចសន្យាត្រូវបានបញ្ចប់ទៅដោយខ្លួន លើកលែងតែភាគី ខ នៅជំពាក់ប្រាក់ថ្លៃថ្មមួយចំនួន ភាគី ក មានសិទ្ធិកាត់យកប្រាក់ជំពាក់ពីប្រាក់កក់នេះបាន។

## ប្រការ ៦ អវសានប្បញ្ញត្តិ

កិច្ចសន្យានេះ ត្រូវបានបង្កើតឡើង តាមការព្រមព្រៀងរបស់ភាគីទាំងពីរ ដោយឆន្ទៈសេរី ។ ភាគីទាំងពីរបានយល់ព្រមដោះស្រាយវិវាទ ដែលកើតឡើងពីការបកស្រាយ និងការមិនអនុវត្តតាមកិច្ចសន្យានេះ ដោយការសម្រុះសម្រួលគ្នា។ ក្នុងករណី មិនអាចដោះស្រាយវិវាទ តាមរយៈការសម្រុះសម្រួលទេ ភាគីទាំងពីរ យល់ព្រមបញ្ជូនវិវាទទៅដោះស្រាយនៅតុលាការនៃព្រះរាជាណាចក្រកម្ពុជា។ កិច្ចសន្យានេះ ត្រូវបានធ្វើឡើងជាភាសាខ្មែរចំនួន ៣ ច្បាប់ដើម ដែលមានតម្លៃគតិយុត្តដូចគ្នា និងត្រូវបានរក្សា

ទុកដោយភាគី ក ចំនួន ១ ច្បាប់ដើម ភាគី ខ ចំនួន ១ ច្បាប់ដើម និងមេធាវីចំនួន ១ ច្បាប់ដើម ។
កិច្ចសន្យានេះ មានអានុភាពចាប់ពីថ្ងៃផ្តិតមេដៃស្នាមនេះតទៅ ។

**ស្នាមមេដៃស្តាំភាគី ក** **ស្នាមមេដៃស្តាំភាគី ខ**

........................................ ........................................ ........................................

**បានឃើញ និងបញ្ជាក់ថា**

គូភាគីពិតជាបានយល់ព្រមផ្តិតមេដៃស្តាំ នៅចំពោះមុខយើងជាមេធាវីពិតប្រាកដមែន ។

រាជធានីភ្នំពេញ, ថ្ងៃទី....... ខែ.......... ឆ្នាំ............

**ហត្ថលេខា និងត្រា**

# ឧបសម្ព័ន្ធទី៣
# គំរូកិច្ចសន្យាម៉ៅការ និងជួសជុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចសន្យាម៉ៅការសំណង់ និងជួសជុល

[redacted]

កិច្ចសន្យាម៉ៅការសាងសង់នេះ ធ្វើនៅ......... ថ្ងៃទី ......... ខែ............... ឆ្នាំ............... រវាង៖

លោកស្រី [redacted] ភេទ [redacted] សញ្ជាតិ **ខ្មែរ** ជនជាតិ [redacted] កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិ...**ខ្មែរ**....លេខ [redacted] មានអាសយដ្ឋាន ផ្ទះលេខ [redacted] ផ្លូវលេខ [redacted] ភូមិ [redacted] ឃុំ [redacted] ស្រុក [redacted] ខេត្ត [redacted] (ជាម្ចាស់សំណង់) តទៅហៅកាត់ថា ភាគី"ក" ។

**និង**

លោក [redacted] ភេទ [redacted] សញ្ជាតិ **ខ្មែរ** ជនជាតិ **ខ្មែរ** កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិ ខ្មែរ លេខ... [redacted] មានអាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ [redacted] ផ្លូវលេខ [redacted] ភូមិ... [redacted] ...សង្កាត់ [redacted] ខណ្ឌ [redacted] រាជធានី [redacted] (ជាអ្នកម៉ៅការសាងសង់) តទៅហៅកាត់ថា **ភាគី"ខ"** ។

ភាគី "ក" និង ភាគី "ខ" បានព្រមព្រៀងគ្នាតាមលក្ខខណ្ឌដូចខាងក្រោម ៖

## ប្រការ១ ៖ កម្មវត្ថុនៃកិច្ចសន្យា

**ភាគី"ក"** បានយល់ព្រមឲ្យ **ភាគី"ខ"** ទទួលម៉ៅការសាងសង់របង និងជួសជុលអគារសាលារៀន (សម្ភារ និងពលកម្ម) មានអាសយដ្ឋានផ្ទះលេខ [redacted] ផ្លូវលេខ [redacted] ភូមិ [redacted] សង្កាត់ [redacted] ខណ្ឌ [redacted] រាជធានី [redacted] ដូចមានលម្អិតនៅក្នុងឧបសម្ព័ន្ធទី១ (ប្លង់ស្ថាបត្យកម្ម) និង **តារាងសម្រង់តម្លៃ (ឧបសម្ព័ន្ធទី២) ដែលមានភ្ជាប់នៅក្នុងកិច្ចសន្យា។**

## ប្រការ២ ៖ តម្លៃនៃកិច្ចសន្យាម៉ៅការសាងសង់

កិច្ចសន្យានេះ មានទឹកប្រាក់សរុបចំនួន [redacted]) ដោយមានលម្អិតនៅក្នុងឧបសម្ព័ន្ធទី១ (ប្លង់ស្ថាបត្យកម្ម), និង**តារាងសម្រង់តម្លៃ (ឧបសម្ព័ន្ធទី២) ដែលមានភ្ជាប់នៅក្នុងកិច្ចសន្យានេះ** ។ ចំនួនទឹកប្រាក់ខាងលើមិនបូកបញ្ចូលអាករលើតម្លៃបន្ថែម (VAT) និងពន្ធគ្រប់ប្រភេទ នៃព្រះរាជាណាចក្រកម្ពុជា ។

## ប្រការ៣ ៖ ការទូទាត់ប្រាក់សាងសង់

ការទូទាត់ប្រាក់ អាចត្រូវធ្វើឡើងតាមរយៈ ជាសាច់ប្រាក់ ឬ ដោយផ្ទេរតាមគណនីធនាគារ ABA មានលេខគណនី [redacted] ហើយមិនអាចប្រើប្រាស់ជាសែកធនាគារបានទេ។

ការទូទាត់ប្រាក់សាងសង់ត្រូវបែងចែកជា៤ដំណាក់កាលដូចខាងក្រោម៖

(មានភ្ជាប់មកជាមួយតារាងបើកប្រាក់រួម)

- **ដំណាក់កាលទី១៖** ភាគី"ក" ត្រូវបង់ប្រាក់30% ស្មើនឹងចំនួន [redacted] ជូនភាគី"ខ" នៅថ្ងៃចុះហត្ថលេខាលើកិច្ចសន្យា។
- **ដំណាក់កាលទី២៖** ភាគី"ក" ត្រូវបង់ប្រាក់40% ស្មើនឹងចំនួន [redacted]) ជូនភាគី"ខ" នៅពេលដែល ភាគី"ខ" បានបញ្ចប់ការងារដូចខាងក្រោម៖

| Code | Task Name | Take Complete |
|---|---|---|
| **00** | **Project Tux Global Institute Renovation** | |
| **2** | **Building 2 Floor** | |
| 2.1 | Masonry Works | Completed |
| 2.2 | CEILING WORKS | 50% |
| 2.5 | DOORS AND WINDOWS | 10% |
| 2.6 | PAINTING WORKS | 10% |
| 2A.1 | Masonry & Roofing Cover Works | 10% |
| **3** | **Building 3 Floor** | |
| 3.1 | Demolish Work | Completed |
| 3.2 | Concrete Work | Completed |
| 3.3 | Masonry & Roofing Cover Works | 50% |
| **4** | **Office 2 Floor (Exterior)** | |
| 4.1 | Zinc, Gutter | Completed |
| **5** | **Office 3 Floor (Exterior)** | |
| 5.1 | Zinc, Gutter | Completed |
| **7** | **Fence** | |
| 7.1 | Excavation & Backfilling Work | Completed |
| 7.2 | Concrete Work | 50% |
| 7.3 | Masonry Works | 10% |

- ដំណាក់កាលទី៣៖ ភាគី"ក" ត្រូវបង់ប្រាក់20% ស្មើនឹងចំនួន [redacted] ជូនភាគី"ខ" នៅពេលដែល ភាគី"ខ" បានបញ្ចប់ការងារដូចខាងក្រោម៖

| Code | Task Name | Take Complete |
|---|---|---|
| **1** | **Landscape** | |
| 1.1 | Demolish Work | Completed |
| 1.2 | Excavation and Fill | Completed |
| **2** | **Building 2 Floor** | |
| 2.2 | CEILING WORKS | Completed |
| 2.3 | Floor Finishing | Completed |
| 2.4 | Skirting | Completed |
| 2.5 | DOORS AND WINDOWS | Completed |
| 2.6 | PAINTING WORKS | 50% |
| 2.7 | Furniture works | 50% |
| **2A** | **Building 2 Floor (Renovate Existing Toilet Building)** | |
| 2A.1 | Masonry & Roofing Cover Works | Completed |
| 2A.2 | CEILING WORKS | Completed |
| 2A.3 | DOORS AND WINDOWS | Completed |
| 2A.4 | PAINTING WORKS | Completed |
| **3** | **Building 3 Floor** | |
| 3.3 | Masonry & Roofing Cover Works | Completed |
| 3.4 | CEILING WORKS | Completed |
| 3.5 | Floor Finishing | Completed |
| 3.7 | Skirting | Completed |
| 3.6 | Wall Finishing | 50% |
| 3.8 | DOORS AND WINDOWS | 10% |
| 3.9 | PAINTING WORKS | 50% |
| 3.10 | Furniture works | 50% |
| **4** | **Office 2 Floor (Exterior)** | |
| 4.2 | Smart board | Completed |
| 4.3 | Ceiling wood décor | Completed |
| **5** | **Office 3 Floor (Exterior)** | |
| 5.2 | Smart board | Completed |
| 5.3 | Ceiling wood décor | Completed |
| **7** | **Fence** | |
| 7.2 | Concrete Work | Completed |
| 7.3 | Masonry Works | Completed |
| 7.4 | PAINTING WORKS | Completed |
| 7.5 | Wall Finishing | Completed |
| 7.6 | Gate & Metal Security Grill | Completed |
| 7.7 | Miscellaneous and Specialty works | Completed |

- ដំណាក់កាលទី៤៖ ភាគី"ក" ត្រូវបង់ប្រាក់ 7% ស្មើនឹងចំនួន [redacted]) ជូនភាគី"ខ" នៅពេលដែល ភាគី"ខ" បានបញ្ចប់ការងារដូចខាងក្រោម៖

| Code | Task Name | Take Complete |
|---|---|---|
| **00** | **Project Tux Global Institute Renovation** | |
| **1** | **Landscape** | |
| 1.3 | Concrete Work | Completed |
| 1.4 | Floor Finishing | Completed |
| 1.5 | MISCELLANEOUS WORKS | Completed |
| **2** | **Building 2 Floor** | |
| 2.6 | PAINTING WORKS | Completed |
| 2.7 | Furniture works | Completed |
| 2.8 | MISCELLANEOUS WORKS | Completed |
| **3** | **Building 3 Floor** | |
| 3.6 | Wall Finishing | Completed |
| 3.8 | DOORS AND WINDOWS | Completed |
| 3.9 | PAINTING WORKS | Completed |
| 3.10 | Furniture works | Completed |
| 5.4 | Alucarbon | Completed |

- **ដំណាក់កាលចុងក្រោយ៖ ភាគី"ខ"** យល់ព្រមតម្កល់ប្រាក់ 3% ស្មើនឹងចំនួន [redacted] ជាប្រាក់ធានាគុណភាពសំណង់ ទុកនៅ ភាគី"ក" រយៈពេល ៣ខែ គិតចាប់តាំងពីថ្ងៃដែល**ភាគី"ខ"** បានប្រគល់គម្រោង ជូន ភាគី"ក" និងបានពិនិត្យ និងទទួលស្គាល់ថាការងារសាងសង់ស្របតាមឧបសម្ព័ន្ធទី១ (**ប្លង់ស្ថាបត្យកម្ម**), និងតារាងសម្រង់តម្លៃ (**ឧបសម្ព័ន្ធទី២**) ដែលមានភ្ជាប់នៅក្នុងកិច្ចសន្យានេះ ។ ប្រាក់តម្កល់នេះ ត្រូវទូទាត់មកឲ្យភាគី"ខ"វិញ នៅពេលផុតកំណត់សុពលភាពធានា យ៉ាងយូរបំផុត៧ថ្ងៃ។

## ប្រការ៤ ៖ ការធានាលើគុណភាពសំណង់

- **ការធានាលើគុណភាពសំណង់ : ភាគី "ខ"** ធានាលើគុណភាពសំភារៈបំពាក់ថ្មីលើសំណង់ចាស់ (មិនធានាលើការបាក់បែកប្រេះស្រាំបេតុង ឬស្រុតគ្រឹះលើសំណង់ចាស់ទេ) រយៈពេល3ខែ នឹងធ្វើការជួសជុសឡើងវិញ (ក្នុងលក្ខខណ្ឌបម្រើបម្រាស់តាមបទដ្ឋានបច្ចេកទេសត្រឹមត្រូវ) ទៅឲ្យ ភាគី"ក"។

## ប្រការ៥ ៖ រយៈពេលនៃការអនុវត្តន៍ការងារ

### ១. រយៈពេលដំណើរការការងារ

ភាគី"ខ" ត្រូវចាប់ផ្តើមការងាររបស់ខ្លួនយ៉ាងយូរ ៧ថ្ងៃ(ប្រាំពីរថ្ងៃ) បន្ទាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចសន្យានេះ។

ភាគី"ខ" ត្រូវបញ្ចប់ការងារសាងសង់ឲ្យបានក្នុងរយៈពេល ៤ខែ (បួនខែ) គិតចាប់ពីថ្ងៃចុះហត្ថលេខាលើកិច្ចន្យា នេះ ដោយស្របតាមឧបសម្ព័ន្ធទី១ (**ប្លង់ស្ថាបត្យកម្ម**), និងតារាងសម្រង់តម្លៃ (**ឧបសម្ព័ន្ធទី២**) ដែលមានភ្ជាប់នៅ

ក្នុងកិច្ចសន្យានេះ គិតចាប់ពីថ្ងៃទី........ ខែ.............. ឆ្នាំ.............. ដោយមិនរាប់បញ្ចូល ថ្ងៃបុណ្យជាតិតូចៗ និងថ្ងៃឈប់សម្រាកចុងសប្តាហ៍ និងឈប់សម្រាកតែ បុណ្យជាតិធំៗ បុណ្យប្រពៃណីចូលឆ្នាំខ្មែរ បុណ្យភ្ជុំបិណ្ឌ អុំទូក។

**២. ករណីប្រធានស័ក្តិ ឬ ហេតុចៃដន្យ**

ក្នុងករណីប្រធានស័ក្តិ (មានព្រឹត្តិការណ៍បណ្តាលមកពីគ្រោះធម្មជាតិ បាតុភាពនយោបាយ ដូចជា សង្គ្រាម វិបត្តិការណ៍យោធា វិធានការណ៍សន្តិសុខរបស់រាជរដ្ឋាភិបាល ជម្ងឺឆ្លងគ្រប់ប្រភេទ) ដែលធ្វើឲ្យផ្អាក នឹងមិនអាចបំពេញការងាររបស់ខ្លួនដោយរលូនបាន ភាគី"ក" និង ភាគី"ខ" នឹងសម្របសម្រួលគ្នា ដើម្បីផ្អាកការសាងសង់នេះជាបណ្តោះអាសន្ន។ ក្នុងករណីនេះ ភាគី"ក" ត្រូវធ្វើការទូទាត់ប្រាក់ដែលនៅសេសសល់មកឲ្យ ភាគី"ខ" ទៅតាមលទ្ធផលការងារ ដែល ភាគី"ខ" បានធ្វើហើយជាក់ស្តែង មុនការសម្រេចពន្យាពេលនេះ។ នៅពេលដែលស្ថានភាពអាក្រក់នេះបានត្រលប់មកធម្មតាវិញ ភាគីទាំងពីរត្រូវបន្តអនុវត្តកិច្ចសន្យានេះឡើងវិញ ដោយត្រូវជជែកពិភាក្សា និងព្រមព្រៀងគ្នា ដើម្បីបន្តការងាររហូតអាចសម្រេចការសាងសង់គម្រោងទាំងមូលជោគជ័យ ទើបអាចបញ្ចប់កិច្ចសន្យាជាស្ថាពរ។

ប្រសិនបើមានការយឺតយ៉ាវក្នុងការបំពេញការងារ ដោយករណីប្រធានស័ក្តិ ដែលមិនមែនជាការបង្កដោយភាគីណាមួយ នោះភាគីទាំងពីរ នឹងធ្វើការសម្របសម្រួលពេលវេលាសាងសង់តាមការចាំបាច់។

**៣. ការកែប្រែ ការរុះរើ ឬការសាងសង់ឡើងវិញ**

ក្នុងករណីដែលភាគី "ក" មានការកែប្រែខុសពី ឧបសម្ព័ន្ធទី១ (**ប្លង់ស្ថាបត្យកម្ម**), និងតារាងសម្រង់តម្លៃ (**ឧបសម្ព័ន្ធទី២**) ដោយតម្រូវឲ្យមានការរុះរើ ឬមានការសងសង់ឡើងវិញ ភាគី "ក" ត្រូវរ៉ាប់រងទូទាត់តម្លៃទាំងសម្ភារនិងពលកម្មមកឲ្យ ភាគី"ខ"លើទំហំការងារជាក់ស្តែង ដោយមានការព្រមព្រៀងគ្នាជាមុន។

**ប្រការ៥ ៖ សិទ្ធិ និងភារកិច្ចរបស់ភាគី "ក"**

- ភាគី"ក" ត្រូវទទួលបន្ទុកទៅលើការស្នើសុំឯកសារគតិយុត្តិគ្រប់ប្រភេទដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជាបានកំណត់ ក្នុងក្របខណ្ឌនៃការសាងសង់ផ្ទះ មានដូចជា លិខិតអនុញ្ញាតសាងសង់ លិខិតអនុញ្ញាតបើកការដ្ឋានសាងសង់ និងលិខិតអនុញ្ញាតបិទការដ្ឋានសាងសង់។
- ភាគី"ក" ត្រូវធ្វើការឆ្លើយតបឲ្យបានឆាប់រហ័ស និងទាន់ពេល រាល់ការងារណាដែលជាកាតព្វកិច្ច ឬ ភារៈកិច្ចរបស់ ភាគី "ក" ដើម្បីជៀសវាងការពន្យារពេល ឬមានអាក់ខានដល់ដំណើរការសាងសង់។
- ភាគី"ក" ត្រូវប្រគល់សិទ្ធិក្នុងការគ្រប់គ្រងការដ្ឋានទាំងស្រុង ទៅឲ្យភាគី "ខ" នៅក្នុងកំឡុងពេលនៃការអនុវត្តកិច្ចសន្យានេះ។
- ក្នុងកំឡុងពេលបំពេញការងារ ភាគី"ក" នឹងមិនជ្រៀតជ្រែក ធ្វើអន្តរាគមន៍ ឬ អនុញ្ញាតឲ្យអ្នកដទៃចូលជ្រៀតជ្រែក បញ្ឈប់ បង្អាក់ ឬ ពន្យាពេលការបំពេញការងារសាងសង់ ដោយគ្មានមូលហេតុសមរម្យឡើយ។
- ភាគី"ក" មានសិទ្ធិត្រួតពិនិត្យ ឬ ជួលអ្នកជំនាញផ្ទាល់ខ្លួន ដើម្បីធ្វើការត្រួតពិនិត្យ និងផ្តល់យោបល់បន្ថែមលើការងារដែលភាគី"ខ"បានធ្វើរួច។ ករណីដែលរកឃើញកំហុសឆ្គងដែលត្រូវធ្វើការកែតម្រូវ ភាគី"ក" ត្រូវជូនដំណឹងអំពីករណីនេះទៅភាគី"ខ" ដើម្បីធ្វើការកែតម្រូវឲ្យទាន់ពេលវេលា។ ភាគី"ក" ត្រូវធ្វើការផ្តល់ដំណឹងជាមុនជូនភាគី"ខ" នៅពេលចុះពិនិត្យមើលការដ្ឋាន ដោយត្រូវមានការចូលរួមពីសំណាក់ភាគី"ខ"។ ក្នុងករណីជួលអ្នកជំនាញផ្ទាល់ខ្លួន (ដូចមានរៀបរាប់ខាងលើ) អ្នកជំនាញទាំងអស់ត្រូវស្វែងយល់ឲ្យបាន

ស៊ុជម្រៅជាមុនសិន អំពីលក្ខខណ្ឌការងារដែល ភាគី"ក" និង ភាគី"ខ" បានព្រមព្រៀងគ្នាពីដំបូង ទើបអាចចុះពិនិត្យ និងវាយតម្លៃការងារបាន។

- ភាគី"ក" ត្រូវភ្ជាប់ចរន្តអគ្គិសនី និងតបណ្តាញទឹកស្អាត ឲ្យបានមុនថ្ងៃបើកការដ្ឋានសាងសង់ ដើម្បីឲ្យភាគី"ខ" អាចអនុវត្តការងារទៅបានយ៉ាងរលូន។ ការយឺតយ៉ាវដែលបណ្តាមកពីការភ្ជាប់ចរន្តអគ្គិសនី និងតបណ្តាញទឹកស្អាត ជាមូលហេតុចាំបាច់ដែលអាចឲ្យភាគី"ខ" មានសិទ្ធិស្នើសុំពន្យាពេលបញ្ចប់កិច្ចសន្យានេះបាន។
- ការចំណាយទៅលើអធិការកិច្ច ពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច នៅមុនពេល កំឡុងពេល និងក្រោយពេលសាងសង់ ជាបន្ទុករបស់ភាគី"ក"

**ប្រការ៦ ៖ សិទ្ធិ និងភាតព្វកិច្ចរបស់ភាគី "ខ"**

- ភាគី"ខ" សន្យាអនុវត្តការងារស្របតាមជំនាញស្តង់ដារវិជ្ជាជីវៈក្នុងក្របខណ្ឌបច្ចេកទេសសំណង់ ដោយការយកចិត្តទុកដាក់។
- ភាគី"ខ" ត្រូវធានាថាការសាងសង់នឹងបញ្ចប់ទាន់ពេលវេលា ។
- ភាគី"ខ" មានសិទ្ធិផ្តាច់មុខក្នុងការគ្រប់គ្រងការដ្ឋានទាំងស្រុងនៅក្នុងកំឡុងពេលនៃការអនុវត្តកិច្ចសន្យា
- ភាគី"ខ" ត្រូវធានាខុសត្រូវចំពោះសុវត្ថិភាពកម្មករ និងជាងជំនាញរបស់ខ្លួន ដោយមានបំពាក់នូវសម្ភារបរិក្ខាបច្ចេកទេសសំណង់ដែលចាំបាច់ នៅក្នុងបរិវេណអនុវត្តការសាងសង់។
- ភាគី"ខ" ត្រូវធ្វើការហ៊ុំពទ្ធ័ការដ្ឋានសាងសង់ឲ្យបានសមរម្យ។
- ភាគី"ខ" មានសិទ្ធិស្នើសុំការទូទាត់ប្រាក់តាមដំណាក់កាលពីភាគី"ក" ដែលបានព្រមព្រៀងគ្នារួចហើយក្រោយពេលដែលខ្លួនបានបញ្ចប់ការងារតាមលក្ខខណ្ឌរួចរាល់។
- ក្នុងអំឡុងពេលអនុវត្តការងាររបស់ខ្លួន ភាគី"ខ" ដែលជាអ្នកគ្រប់គ្រងការដ្ឋាន ត្រូវទទួលរ៉ាប់រងចំពោះបញ្ហាអនាម័យនៅក្នុងបរិវេណបំពេញការងាររបស់ខ្លួន។
- ភាគី"ខ" ត្រូវទទួលខុសត្រូវចំពោះគ្រោះថ្នាក់ការងារផ្សេងៗទៅលើកម្មករ និងជាងជំនាញរបស់ខ្លួន នៅក្នុងបរិវេណការដ្ឋានរបស់ខ្លួនដែលកំពុងបំពេញការងារ។ ចំពោះគ្រោះថ្នាក់ណាដែលកើតចេញពីចេតនារបស់កម្មករ នោះ ភាគី"ខ" នឹងចូលរួមដោះស្រាយទៅតាមនីតិវិធីច្បាប់។
- ភាគី"ខ" មានសិទ្ធិទាមទារឲ្យមានការទទួលខុសត្រូវពីជនណាម្នាក់ ដែលមានចេតនាក្នុងការបង្កគ្រោះថ្នាក់ការងារ ឬអសុវត្ថិភាពដល់កម្មករ និងសំណង់ទាំងមូល។

**ប្រការ៧ ៖ ការទទួលខុសត្រូវទៅលើអំពើខុសច្បាប់ដែលកើតមានឡើង**

ភាគី"ខ" មិនអាចប្រើប្រាស់ទីតាំងការដ្ឋានសាងសង់នេះ ដើម្បីធ្វើអាជីវកម្ម ឬ ប្រព្រឹត្តអំពើទាំងឡាយណាដែលប្រឆាំងនឹងច្បាប់រដ្ឋដោយចេតនាឡើយ។

ភាគី"ខ"នឹងមិនទទួលខុសត្រូវចំពោះអំពើខុសច្បាប់ទាំងឡាយណា ដែលប្រព្រឹត្តឡើងដោយ ភាគី"ក" ឬ ភាគីទី៣ នៅទីតាំងការដ្ឋាន ដែលមិនមែនជាភាគី"ក" ឬ ភាគី"ខ" ឡើយ។

**ប្រការ៨ ៖ ការបញ្ចប់កិច្ចសន្យាមុនពេលកំណត់**

កិច្ចសន្យានេះនឹងត្រូវបញ្ចប់ដោយស្វ័យប្រវត្តិ នៅពេលដែលភាគីទាំងពីរបានបំពេញកាតព្វកិច្ចទាំងអស់រៀងៗខ្លួន តាមកិច្ចសន្យានេះ។ កិច្ចសន្យានេះអាចត្រូវបានបញ្ចប់មុនកាលកំណត់ ក្នុងករណីដូចខាងក្រោម៖

- ភាគី"ខ" បានបញ្ចប់ការងារសាងសង់ទាំងស្រុងមុនពេលកំណត់។ ក្នុងករណីនេះ ភាគី"ក" ត្រូវទូទាត់ប្រាក់តាមដំណាក់កាលដែលនៅសល់ជូនភាគី"ខ" យ៉ាងយូរបំផុត ត្រឹមថ្ងៃទី......ខែ.........ឆ្នាំ......... លើកលែងតែប្រាក់ធានាគុណភាពសំណង់ ។
- ប្រសិនបើភាគីទាំងពីរ បានបំពានប្រការណាមួយនៃកិច្ចសន្យា ឬដោយគ្រប់រូបភាពណាមួយ ដែលធ្វើឲ្យមានការអាក់ខានដល់ដំណើរការសាងសង់ និងធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរ ដល់ការសាងសង់ និងបទដ្ឋានបច្ចេកទេសរបស់សំណង់ទាំងមូល ក្នុងករណីនេះ ភាគីទាំងពីរត្រូវធ្វើការសម្របសម្រួលឲ្យអស់លទ្ធភាព ដើម្បីធ្វើការវាយតម្លៃអំពីទំហំខូចខាតការងារ ដែលបណ្តាលមកពីភាគីណាមួយ ទោះដោយចេតនា ឬ អចេតនាក្តី ក្នុងគោលដៅដោះស្រាយសំណងខូចខាតឲ្យបានសមរម្យជូនភាគីរងគ្រោះ។

**ប្រការ៩ ៖ អំពីបទបញ្ញត្តិ និងសមត្ថកិច្ចតុលាការ**

កិច្ចសន្យានេះ ត្រូវស្ថិតនៅក្រោមច្បាប់ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា។

ក្នុងករណីមានវិវាទកើតឡើង ភាគីទាំងពីរត្រូវព្យាយាមពិភាក្សាគ្នា រកដំណោះស្រាយដោយសន្តិវិធីក្នុងស្មារតីយោគយល់គ្នាខ្ពស់បំផុត។ ប៉ុន្តែ បើមិនអាចដោះស្រាយដោយការចរចាបាន ភាគីទាំងពីរត្រូវធ្វើការដោះស្រាយ ដោយការស្វែងរកភាគីទី៣(មានការឯកភាពទាំងសងខាង)ដែលជាអ្នកបច្ចេកទេសចូលរួមសម្របសម្រួល និងដោះស្រាយវិវាទ។ ប្រសិនបើការដោះស្រាយវិវាទ ដោយការចរចា មិនអាចឈានទៅរកការព្រមព្រៀងណាមួយបានទេ ភាគីទាំងពីរត្រូវធ្វើការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ១០ ៖ អវសានបញ្ញត្តិ**

កិច្ចសន្យានេះធ្វើឡើងជាភាសាខ្មែរ មានពីរច្បាប់ មួយច្បាប់មាន៧ទំព័រ ដែលមានអានុភាពស្មើគ្នាចំពោះមុខច្បាប់។ ភាគីនីមួយៗរក្សាទុកម្នាក់មួយច្បាប់។

កិច្ចសន្យានេះអាចមានសុពលភាពទៅបាន លុះត្រាតែគ្មានការកោសលុប។ រាល់ការកែប្រែប្រការណាមួយនៃកិច្ចសន្យានេះ ត្រូវធ្វើឡើងដោយការព្រមព្រៀងជាលាយលក្ខណ៍អក្សររវាងពីភាគីទាំងពីរ។

ភាគីទាំងពីរ បានអាន និងយល់ច្បាស់ពីខ្លឹមសារ និងលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា និងបានព្រមព្រៀងគ្នាផ្តិតមេដៃលើកិច្ចសន្យានេះ។

ធ្វើនៅ ............... ថ្ងៃទី......... ខែ ............... ឆ្នាំ...............

**ស្នាមមេដៃស្តាំភាគី "ក"** **ស្នាមមេដៃស្តាំ** **ស្នាមមេដៃស្តាំភាគី "ខ"**

សាក្សីទី១ សាក្សីទី២

# ឧបសម្ព័ន្ធទី៤
# ពាក្យស្នើសុំលិខិតអនុញ្ញាត
# សាងសង់

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# ពាក្យសុំលិខិតអនុញ្ញាតសាងសង់

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ........................................... ភេទ........ កើតឆ្នាំ........... សញ្ជាតិ........... មុខរបរសព្វថ្ងៃ........................ទីលំនៅបច្ចុប្បន្នផ្ទះលេខ...........ផ្លូវ.................ភូមិ................................ ឃុំ/សង្កាត់............................ក្រុង/ស្រុក/ខណ្ឌ............................ រាជធានី/ខេត្ត..........................។

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ..................................... ភេទ........... កើតឆ្នាំ.............. សញ្ជាតិ........... មុខរបរសព្វថ្ងៃ..............................ទីលំនៅបច្ចុប្បន្នផ្ទះលេខ..............ផ្លូវ..............ភូមិ....................... ឃុំ/សង្កាត់............................ក្រុង/ស្រុក/ខណ្ឌ............................ រាជធានី/ខេត្ត..........................។

**សូមគោរពជូន**

**ឯកឧត្តមអភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ**

**តាមរយៈ** : - ចៅសង្កាត់.........................................................
- អភិបាលខណ្ឌ.....................................................
- ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី រាជធានីភ្នំពេញ

**កម្មវត្ថុ** : សំណើសុំ........................................................ លើដីឡូតិ៍/ក្បាលដីលេខ.....................
ផ្លូវលេខ........ ភូមិ....................សង្កាត់....................ខណ្ឌ.....................រាជធានីភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមជម្រាបជូន **ឯកឧត្តមអភិបាល** មេត្តាជ្រាបថា:..........
.................................................................................................................................
.................................................................................................................................
.............................................................................................................។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម** មេត្តាពិនិត្យ និងអនុញ្ញាតច្បាប់ឱ្យដល់ ខ្ញុំបាទ/នាងខ្ញុំ..........................................................................................ដោយអនុគ្រោះ។

សូម **ឯកឧត្តម** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ.........................ខែ.....................ឆ្នាំ.........................ព.ស២៥.....

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ.................ឆ្នាំ២០......

ស្នាមមេដៃស្តាំ

លេខ:..........................

បានឃើញ និងបញ្ជូនមក

លោកប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម

សំណង់ និងសុរិយោដី រាជធានីភ្នំពេញ

"ដើម្បីពិនិត្យ និងជួយសម្រួលដោយក្តីអនុគ្រោះ"

ថ្ងៃ....................ខែ.................ឆ្នាំ.....................ព.ស២៥......

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ............ឆ្នាំ២០......

**អភិបាលខណ្ឌ**................................

លេខ:..........................

បានឃើញ និងបញ្ជូនមក

លោកអភិបាលខណ្ឌ..........................

"ដើម្បីពិនិត្យ និងជួយសម្រួលដោយក្តីអនុគ្រោះ"

ថ្ងៃ.......................ខែ..............ឆ្នាំ........................ព.ស២៥.....

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ.................ឆ្នាំ២០......

**ចៅសង្កាត់**................................